នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Aug-2011, 14:36
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្តីលើ សំណើរបស់សហព្រះរាជអាជ្ញាសុំអោយកំណត់បទចោទជាថ្មីឡើងវិញក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN

| | |
|---|---|
| លោក ពេជ អង្គ | លោក Victor Koppe |
| Elisabeth SIMONNEAU FORT | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅស៊ាង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវាន |
| | លោក Jacques VERGÈS |

# I. សេចក្តីផ្តើម

១- សហព្រះរាជអាជ្ញា សូមដាក់ជូននូវការឆ្លើយតបរួមរបស់ខ្លួនទៅនឹងចម្លើយតបនានាដែលក្រុមមេធាវីការពារក្តីទាំងបួនបានដាក់តបទៅនឹងសំណើចំនួនបី(០៣) ដែលសហព្រះរាជអាជ្ញាបានដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូងកាលពីខែមិថុនា ឆ្នាំ២០១១ គឺ៖ *សំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ("សំណើស្តីពីជម្លោះប្រដាប់អាវុធ")[១], *សំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជា អំពើអមនុស្សធម៌ ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ("សំណើស្តីពី អំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ")[២] និង *សំណើសុំឱ្យអង្គជំនុំជម្រះ សាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀត* ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ("សំណើស្តីពី JCE III")[៣]"សំណើរួម" ។

២- ចម្លើយតបខាងមេធាវីការពារក្តីទៅនឹងសំណើទាំងនេះ បានលើកឡើងនូវសំអាងតាមនីតិវិធី និងតាមអង្គច្បាប់ជាសារធាតុមានលក្ខណៈជារួម ដែលពាក់ព័ន្ធនឹងការទទួលយកបាន ឬមិនបាន នៃសំណើទាំងនេះ, ពាក់ព័ន្ធនឹងវិសាលភាពនៃអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការអនុញ្ញាតឱ្យមានសំណើទាំងនេះ, ពាក់ព័ន្ធនឹងឋានៈនៃវិធានច្បាប់ប្រពៃណីអន្តរជាតិដែលទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ III "JCE III" នៅក្នុងយុត្តាធិការពេលវេលារបស់ អវតក ព្រមទាំងពាក់ព័ន្ធនឹងវិសាលភាព និងការអនុវត្តនូវគោលការណ៍ស្តីពីនីត្យានុកូលភាព ។ ដូច្នេះ ដើម្បីជាយោជន៍ដល់ចរិការបស់តុលាការ បញ្ហារួមទាំងនេះ ត្រូវលើកឡើងតាមរបៀបការឆ្លើយតបរួមនេះ។

៣- ជាការឆ្លើយតបរួមទៅនឹងបញ្ហានានាតាមនីតិវិធី និងតាមអង្គច្បាប់ជាសារធាតុ ដែលបានលើកឡើងនៅក្នុងសំណើផ្សេងៗខាងការពារក្តី សហព្រះរាជអាជ្ញាសូមដាក់ជូននូវសេចក្តីសន្និដ្ឋានថា ៖

ក. សំណើទាំងនេះមិនមែនជាអញ្ញត្រកម្មបឋម ដូចតាមនិយមន័យនៅក្នុងវិធាន ៨៩.២ ទេ ហើយហេតុដូច្នេះវាមិនត្រូវបានរារាំងដោយសារបញ្ហាពេលវេលានោះឡើយ ។

---

[១] **E95**, សំណើស្តីពីជម្លោះប្រដាប់អាវុធ, ថ្ងៃទី១៥ មិថុនា ២០១១, លេខERN 00716026-37 ។

[២] **E99**, សំណើស្តីពីអំពើរំលោភសេពសន្ថវៈថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី១៦ មិថុនា ២០១១, លេខERN 00708301-15 ។

[៣] **E100**, សំណើស្តីពី JCE III, ថ្ងៃទី១៧ មិថុនា ២០១១, លេខERN 00708242-56 ។

ខ. អង្គជំនុំជម្រះសាលាដំបូងមានអំណាចអនុញ្ញាតឲ្យមានសំណើទាំងនេះ ដោយអនុលោមតាមវិធាន ៩៨.២ និង គោលការណ៍ជាមូលដ្ឋានស្តីពី *iura novit curia* ។

គ. ក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អវតក, ច្បាប់តាមប្រពៃណីអន្តរជាតិ មិនតម្រូវឲ្យមានទំនាក់ទំនងគ្នារវាង ជម្លោះប្រដាប់អាវុធ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ។

ឃ. ក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អវតក ច្បាប់តាមប្រពៃណីអន្តរជាតិ បានទទួលស្គាល់ អំពើរំលោភសេពសន្ថវៈ ថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ង. ក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អវតក ច្បាប់តាមប្រពៃណីអន្តរជាតិ បានទទួលស្គាល់ JCE III ថាជា ទម្រង់នៃការទទួលខុសត្រូវមួយ ចំពោះឧក្រិដ្ឋកម្មអន្តរជាតិនានា ។ និង

ច. ការអនុញ្ញាតឲ្យមានសំណើទាំងនេះ មិនបំពានលើគោលការណ៍ស្តីពីនីត្យានុកូលភាពទេ ។

៤- អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា សូមស្នើអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើ ហើយអនុញ្ញាតទៅតាមអង្គសេចក្តីទាំងនេះ ។ បន្ថែមលើនេះ សហព្រះរាជអាជ្ញា សូមស្នើអង្គជំនុំជម្រះ ធ្វើការកំណត់យកសំណើទាំងនេះដោយផ្អែកមូលដ្ឋាននៅលើ សារណានានាតែប៉ុណ្ណោះ ព្រមទាំងធ្វើការជូនដំណឹងដល់ភាគីនានាពីការកំណត់យកនេះនៅមុនពេលមានការចាប់ផ្តើមធ្វើសវនាការ ។ ការធ្វើសវនាការដោយផ្ទាល់មាត់ ដូចដែលក្រុមមេធាវីការពារក្តីរបស់ អៀង សារី និង នួន ជា បានស្នើឡើង មិនតម្រូវចំពោះបញ្ហាទាំងនេះទេ ។

## II. **អំពីប្រវត្តិនីតិវិធី**

៥- ការរៀបរាប់អំពីប្រវត្តិនីតិវិធីពាក់ព័ន្ធ គឺបានចែងនៅក្នុងសំណើនានាដំបូង[4] ។ បន្ទាប់ពីបានដាក់សំណើទាំងនោះមក អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីនានា តាមរយៈអ៊ីមែលថាខ្លួននឹងអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីធ្វើចម្លើយតបទៅនឹងសំណើ ទាំងនោះរហូតដល់ថ្ងៃទី២២ ខែ

[4] **E95**, សំណើស្តីពីជម្លោះប្រដាប់អាវុធ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌទី ៤-៥ ។ **E99**, សំណើស្តីពីអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌទី ២-៤ ។ **E100**, សំណើស្តីពី JCE III, កំណត់សម្គាល់*ខាងលើ* លេខ៣ ត្រង់កថាខណ្ឌទី ៥-៧ ។

កក្កដា ឆ្នាំ២០១១ ហើយអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា ចំនួនដប់(១០)ថ្ងៃ ដើម្បីធ្វើការឆ្លើយតប[៥] ។ ការណ៍នេះត្រូវបានបញ្ជាក់អះអាងជាថ្មីម្តងទៀតនៅក្នុងសេចក្តីសម្រេចជាផ្លូវការមួយ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១ ដែលបានថែងថា សហព្រះរាជអាជ្ញាដាក់ការឆ្លើយតប គឺនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១១[៦] ។

៦- នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ អៀង សារី បានដាក់សំណើមួយស្នើសុំឲ្យមានសេចក្តីសម្រេចជាបន្ទាន់ទាក់ទងទៅនឹងភាពអាចទទួលយកបាននូវសំណើទាំងនេះ[៧] ។ នៅមិនទាន់មានចេញសេចក្តីសម្រេចណាមួយលើសំណើនេះនៅឡើយទេ ។ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ចម្លើយ តបនានាទៅនឹងសំណើនីមួយៗត្រូវបានដាក់ក្នុងនាម អៀង ធីរិទ្ធ[៨] អៀង សារី[៩] និង ខៀវ សំផន[១០]

[៥] អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ Susan Lamb ជូនទៅភាគីនានា, ការស្នើកែប្រែកាលបរិច្ឆេទកំណត់របស់អង្គជំនុំជម្រះសាលាដំបូង ដែលពាក់ព័ន្ធទៅនឹងការរកឃើញថ្មីៗចំនួនបីរបស់អយ្យការ ។ ការជូនដំណឹងជាមុនអំពីកាលបរិច្ឆេទកំណត់សម្រាប់ដាក់បញ្ជីឯកសារ/ភស្តុតាងបន្ថែម (សម្រាប់ដំណាក់កាលដំបូងនានានៃសវនាការ) ថ្ងៃទី២០ មិថុនា ២០១១ ។

[៦] **E107**, សេចក្តីសម្រេចលើសំណើសុំពន្យារពេល, ថ្ងៃទី៧ កក្កដា ២០១១, លេខERN 00711953-4 ។

[៧] **E103**, សំណើរបស់ អៀង សារី សុំឲ្យមានសេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថា តើសហព្រះរាជអាជ្ញាអាចស្នើសុំឲ្យផ្លាស់ប្តូរការកំណត់បទចោទនៅដំណាក់កាលនេះនៃដំណើការនីតិវិធី ដែរ ឬ អត់ និងសំណើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសំណើសុំនានាទាំងនេះ បើសិនជាចម្លើយតបជាការចាំបាច់, ថ្ងៃទី២៤ មិថុនា ២០១១, លេខERN 00710070-80 ។

[៨] **E95/2**, ចម្លើយតបរបស់មេធាវីទៅនឹង “សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូងកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00714797-809 (បានជូនដំណឹងជាភាសាខ្មែរ និងអង់គ្លេស នៅថ្ងៃទី២៥ កក្កដា ២០១១) (“ចម្លើយតបរបស់ អៀង ធីរិទ្ធ អំពីជម្លោះប្រដាប់អាវុធ”) ។ **E99/2**, ចម្លើយតបរបស់មេធាវីទៅនឹង “សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មីទាក់ទងទៅនឹងអង្គហេតុដែលបង្កើតបានជាអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងថាជា អំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅវិញ”, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00716118-32 (បានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៥ កក្កដា ២០១១, ជាភាសាខ្មែរនៅថ្ងៃទី៣ សីហា ២០១១) (“ចម្លើយតបរបស់ អៀង ធីរិទ្ធ អំពីអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”) ។ **E100/1**, ចម្លើយតបរបស់មេធាវីទៅនឹង “សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់ទីបីនៃសហកម្មឧក្រិដ្ឋកម្មរួម (JCE III) ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត”, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00714810-22 (បានជូនដំណឹងជាភាសាខ្មែរ និងអង់គ្លេស នៅថ្ងៃទី២៥ កក្កដា ២០១១) (“ចម្លើយតបរបស់ អៀង ធីរិទ្ធ អំពី JCE III”) ។

[៩] **E95/4**, ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសំណើសុំឲ្យមានសវនាការផ្ទាល់មាត់, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00716010-25 (បានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៦ កក្កដា ២០១១, ភាសាខ្មែរនៅថ្ងៃទី២៨ កក្កដា ២០១១) (“ចម្លើយតបរបស់ អៀង សារី អំពីជម្លោះប្រដាប់អាវុធ”) ។ **E99/4**, ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មីទាក់ទងទៅនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត និងសំណើសុំឲ្យមានសវនាការផ្ទាល់មាត់, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00716026-37 (បានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៦ កក្កដា ២០១១, ជាភាសាខ្មែរនៅថ្ងៃទី២៨ កក្កដា ២០១១) (“ចម្លើយតបរបស់

ហើយចម្លើយតបទៅនឹងសំណើស្តីពីជម្លោះប្រដាប់អាវុធ និង សំណើស្តីពី JCE III ត្រូវបានដាក់ក្នុងនាម នួន ជា[១១] ។ ចម្លើយតបផ្សេងៗទាំងនេះត្រូវបានជូនដំណឹងនៅថ្ងៃទី២៥ និង ២៦ ខែកក្កដា ឆ្នាំ២០១១ ទោះបីជាសំណៅជាភាសាខ្មែរនៃចម្លើយតបដាក់លាក់មួយចំនួនមិនត្រូវបានជូនដំណឹង ទេ រហូតដល់ពេលក្រោយមកទើបបានជូនដំណឹង ។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីក៏បានដាក់ចម្លើយតបគាំទ្រសំណើនីមួយៗនៃសំណើទាំងបីនេះផងដែរ[១២]។

៧- ដោយសារមានការពន្យារនៅក្នុងការជូនដំណឹងចម្លើយតបនានាខាងការពារក្តី ទាំងជាភាសាផ្លូវការ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំថា កាលបរិច្ឆេទកំណត់សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបរបស់ខ្លួនត្រូវពន្យារពេលចំនួនដប់(១០)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការ

---

អៀង សារី អំពីអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ") ។ **E100/2**, ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ជាទម្រង់មួយទៀតនៃការទទួលខុសត្រូវ និង សំណើសុំឱ្យមានសវនាការផ្ទាល់មាត់ដើម្បីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00719826-41 (បានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៦ កក្កដា ២០១១, ភាសាខ្មែរនៅថ្ងៃទី២៨ កក្កដា ២០១១) ("ចម្លើយតបរបស់ អៀង សារី អំពី JCE III") ។

[១០] **E95/3**, ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងលុបចោលនូវលក្ខណៈវិនិច្ឆ័យ ដែលដាក់បញ្ចូលជម្លោះប្រដាប់អាវុធទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00716550-60 (បានជូនដំណឹងជាភាសាខ្មែរ និងបារាំង នៅថ្ងៃទី២៦ កក្កដា ២០១១) ("ចម្លើយតបរបស់ ខៀវ សំផន អំពីជម្លោះប្រដាប់អាវុធ") ។ **E99/3**, ចម្លើយទៅនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងការកំណត់បទចោទសាជាថ្មី ទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00718662-71 (បានជូនដំណឹងជាភាសាខ្មែរ និងបារាំង នៅថ្ងៃទី២៦ កក្កដា ២០១១) ("ចម្លើយតបរបស់ ខៀវ សំផន អំពីអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ") ។ **E100/3**, ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00716541-9 (បានជូនដំណឹងជាភាសាខ្មែរ និងបារាំង នៅថ្ងៃទី២៦ កក្កដា ២០១១) ("ចម្លើយតបរបស់ ខៀវ សំផន អំពី JCE III") ។

[១១] **E95/5**, ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00717406-14 ("ចម្លើយតបរបស់ នួណ ជា អំពីជម្លោះប្រដាប់អាវុធ") ។ **E100/5**, សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចាត់ទុក JCE III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសមួយផ្សេងទៀត, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00717650-7 ("ចម្លើយតបរបស់ នួន ជា អំពី JCE III") ។

[១២] **E95/1**, សារណាឆ្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី១៧ មិថុនា ២០១១, លេខERN 00707942-6 ។ **E99/1**, ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី២១ កក្កដា ២០១១, លេខERN 00716455-69 ។ **E100/4**, សារណាគាំទ្រដល់សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដោយហេតុថាជនជាប់ចោទបានចូលរួមនៅក្នុងទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00716981-5 ។

ជូនដំណឹង ពី ចម្លើយតបរបស់មេធាវីការពារក្ដីជាភាសាអង់គ្លេស និងភាសាខ្មែរ[១៣] ។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់សហព្រះរាជអាជ្ញាដោយអ៊ីមែល នៅថ្ងៃតែមួយដែលសំណើនោះត្រូវបានយល់ព្រមអនុញ្ញាត[១៤] ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចជាផ្លូវការនៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១១ ដោយបានអនុញ្ញាតឱ្យមានការពន្យារពេលសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានពីការឆ្លើយតបនេះ ក្នុងរយៈពេលចំនួនដប់(១០)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទជូនដំណឹងពីចម្លើយតបរបស់មេធាវីការពារក្ដីចុងក្រោយជាភាសាខ្មែរ[១៥] ។ ចម្លើយតបចុងក្រោយជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១[១៦] ដោយបានកំណត់ថ្ងៃចុងក្រោយសម្រាប់ការឆ្លើយតបនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ ។

## III. **អំពីច្បាប់ជាធរមាន**

៨- ច្បាប់ពាក់ព័ន្ធជាធរមាន រួមមានបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀង, ច្បាប់ អវតក, វិធានផ្ទៃក្នុង (“វិធាន”) និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងការអនុវត្តនៅកម្ពុជា ។ មាត្រា ៩ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ (“កិច្ចព្រមព្រៀង”) ចែងថា៖

> *យុត្តាធិការលើរឿងក្ដីរបស់អង្គជំនុំជម្រះវិសាមញ្ញ រួមមាន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចដែលបានកំណត់ក្នុងអនុសញ្ញា ឆ្នាំ១៩៤៨ ស្ដីពីការបង្ការ និងការផ្ដន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ <u>ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឆ្នាំ១៩៩៨</u> និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មផ្សេងៗទៀត ដូចបានកំណត់ក្នុងជំពូក ២ នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវ*

[១៣] **E107/1**, សំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវីការពារក្ដីស្ដីពីសហឧក្រិដ្ឋកម្មរួម III, អំពើ រំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ, ថ្ងៃទី២៦ កក្កដា ២០១១, លេខERN 00720244-6 ។

[១៤] អ៊ីម៉ែលរបស់ Susan Lamb ជូនទៅ William Smith និងលោក យ៉េត ចរិយា, ចម្លងជូនលោក Andrew Cayley, លោកស្រី ជា លាង, Kolvuthy Se “យោង៖ **ឯកសារថ្មី៖** សំណុំរឿងលេខ ០០២ - ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណុំរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួម III ជាជម្រើសមួយទៀតនៃទម្រង់នៃការទទួលខុសត្រូវ និងសំណើសុំឱ្យមានសវនាការជាសាធារណៈ:”, ថ្ងៃទី២៦ កក្កដា ២០១១, ម៉ោង៣ និង ៥៩នាទី រសៀល ។

[១៥] **E107/3**, សេចក្ដីសម្រេចលើសំណើសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា, ថ្ងៃទី២ សីហា ២០១១, លេខERN 00721799-801 ។

[១៦] **D99/2**, ចម្លើយតបរបស់ អៀង ធីរិទ្ធ អំពីអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, *កំណត់សម្គាល់ខាងលើ* ទី៨ ។

*បានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ។* (សង្កត់ន័យបន្ថែមដោយគូសបន្ទាត់ពីក្រោម) ។

៩- មាត្រា ១២ នៃកិច្ចព្រមព្រៀងអនុញ្ញាតឲ្យស្វែងរកដំណោះស្រាយពីវិធាននីតិវិធីអន្តរជាតិ ដែលបានចែងនៅក្នុងផ្នែកពាក់ព័ន្ធ៖

*នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា ។ នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។*

១០- មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ (ដូចដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤) ("ច្បាប់ អវតក") បានឲ្យនិយមន័យ និងផ្តល់យុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឲ្យដល់អង្គជំនុំជម្រះនេះ៖

*"អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ ៦ ខែមករា ឆ្នាំ១៩៧៩ ។*

*ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មាន អាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំ ប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ណាមួយ ដូចជា៖*

*ការធ្វើមនុស្សឃាត*
*ការសម្លាប់រង្គាល*
*ការធ្វើឲ្យទៅជាទាសករ*
*ការនិរទេស*
*ការដាក់ក្នុងមន្ទីរឃុំឃាំង*
*ការធ្វើទារុណកម្ម*
*ការរំលោភលើផ្លូវភេទ*
*ការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ ពូជសាសន៍ ឬ សាសនា*
*អំពើអមនុស្សធម៌ផ្សេងៗទៀត ។*

១១- មាត្រា២៩ នៃច្បាប់ អវតក ដែលក្នុងនោះមានបញ្ញត្តិស្តីពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលចែងថា៖

*ជនសង្ស័យណាមួយដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា៣, ៤, ៥, ៦, ៧, និងមាត្រា៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ។*

*តួនាទីឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ។*

*ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងនៅក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧, និងមាត្រា៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះមិនអាចជួយឲ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់មានបញ្ជា ឬមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាចនិងការត្រួតពិនិត្យទៅលើអ្នកក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថា អ្នកក្រោមបង្គាប់ ប្រព្រឹត្តឬបានប្រព្រឹត្ត នូវសកម្មភាពបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តនេះ។ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្របដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះ។*

*ប្រការដែលថា ជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយឲ្យជនសង្ស័យនេះរួចផុតពីការទទួលខុសត្រូវជាបុគ្គលចំពោះបទឧក្រិដ្ឋនេះបានឡើយ។*

១២- មាត្រា៣៣ថ្មី នៃច្បាប់ អវតក ដែលអនុញ្ញាតឲ្យស្វែងរកឧបាស្រ័យនៅក្នុងវិធានស្តីពីនីតិវិធីរបស់អន្តរជាតិ បានចែងអំពីផ្នែកដែលពាក់ព័ន្ធ ដូចខាងក្រោមនេះ៖

*អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ បើជាការចាំបាច់ ហើយនីតិវិធីដែលនៅជាធរមាននោះមានការខ្វះចន្លោះ គេអាចស្វែងរកការណែនាំនៅក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកំរិតអន្តរជាតិ។*

១៣- វិធាន៨៩ (១) នៃវិធានផ្ទៃក្នុង ដែលទាក់ទងនឹងអញ្ញត្រកម្មបឋម បានចែងថា៖
*អញ្ញត្រកម្មបឋមទាក់ទងនឹង៖*

*ក- យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង។*

*ខ- ការរលត់បណ្តឹងអាជ្ញា។*

*គ- មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ*

*ត្រូវលើកឡើងយ៉ាងយូរសាមសិប (៣០)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេអញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ។*

១៤- វិធាន៩៨ (២) នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យកំណត់បទចោទជាថ្មីឡើងវិញចំពោះឧក្រិដ្ឋកម្មដែលបានរៀបរាប់លំអិតនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ វិធាននេះចែងក្នុងផ្នែកពាក់ពន្ធ័ថា៖

*សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ។*

១៥- នៅក្នុងមាត្រា៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ("CCPC") ក៏មានបញ្ញត្តិដែលចែងអំពីការអនុញ្ញាតឲ្យកំណត់បទចោទជាថ្មីឡើងវិញចំពោះឧក្រិដ្ឋកម្មនានាបានដែរ៖

*តុលាការអាចសម្រេចសេចក្តីបានតែលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាបញ្ជូន ដីកាកោះហៅទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម។*

*ក្នុងករណីដែលតុលាការសម្រេចរួមជាក្រុម ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះបង្កើតបានជាបទមជ្ឈិម ឬបទលហុ តុលាការនោះនៅតែមានសមត្ថកិច្ចដើម្បីជម្រះសេចក្តីដដែល។*

*ក្នុងករណីដែលតុលាការសម្រេចដោយចៅក្រមតែម្នាក់គត់ ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះបង្កើតបានជាបទឧក្រិដ្ឋ តុលាការនោះបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ។*

## IV. **ឧទ្ទិករណ៍**

### ក. **សំណើអាចទទួលយកបាន**

*i. សំណើរបស់សហព្រះរាជអាជ្ញាមិនទាក់ទងនឹង "យុត្តាធិការរបស់អង្គជំនុំជម្រះ" ដូចអត្ថន័យដែលមានចែងនៅក្នុងវិធាន ៨៩ ឡើយ*

១៦- នៅក្នុងចម្លើយតបទាំងឡាយរបស់ខ្លួន អៀង សារី[១៧], អៀង ធីរិទ្ធ[១៨], និងខៀវ សំផន[១៩], បានធ្វើការជំទាស់ចំពោះភាពអាចទទួលយកបាននៃសំណើនានា ដោយសារមូលហេតុថា នៅក្នុងសំណើទាំងនេះមាន "អញ្ញត្រកម្មបឋមទៅនឹងយុត្តាធិការ" ដែលហេតុដូចនេះ គួរតែត្រូវបានលើកឡើងនៅក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរ គិតចាប់តាំងពីថ្ងៃចេញដីកាដំណោះស្រាយ អនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញា មិនយល់ព្រមទេ។ អញ្ញត្រកម្មបឋមទៅនឹងយុត្តាធិការតាមខ្លឹមសារដូចដែលមានចែងនៅក្នុងវិធាន៨៩ គឺសំដៅចំពោះអញ្ញត្រកម្មទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងដូចដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វិធាន៨៩ មិនបានកំរិតលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងមិនឲ្យធ្វើការពិនិត្យពិចារណា លើបញ្ហាទាំងឡាយដែលទាក់ទងនឹងយុត្តាធិការ តាមន័យទូលំទូលាយជាងនេះឡើយ ក្នុងបរិបទនៃការកំណត់បទចោទជាថ្មី។

១៧- នៅក្នុងករណីចំពោះមុខនេះ សហព្រះរាជអាជ្ញាមិនមានការជំទាស់ទៅនឹងយុត្តាធិការដូចដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយនោះឡើយ។ ដីកាដំណោះស្រាយដូចមានបច្ចុប្បន្ននេះ មិនបានដាក់បញ្ចូលក្នុងនេះដោយជាក់លាក់នូវបទចោទប្រកាន់ពីបទរំលោភសេពសន្ថវៈដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬជាសហកម្មឧក្រិដ្ឋកម្មរួមទី៣ (JCE III) ដែលជាទម្រង់នៃការទទួលខុសត្រូវមួយដែលជាជំនួសនោះឡើយ។ ហេតុដូចនេះ សំណើសុំអំពីបទរំលោភសេពសន្ថវៈថាជា ឧក្រិដ្ឋកម្ម

[១៧] ឯកសារលេខ E100/2, ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួមទី៣, *ដូចខាងលើ* កំណត់សំគាល់លេខ៩, ត្រង់កថាខណ្ឌពីទី ៣-៤ ។ ឯកសារលេខ E99/4, ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងបទរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ, *ដូចខាងលើ* កំណត់សំគាល់លេខ៩, ត្រង់កថាខណ្ឌពីទី៩-១០ ។ ឯកសារលេខ E95/4, ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងជម្លោះប្រដាប់អាវុធ, *ដូចខាងលើ* កំណត់សំគាល់លេខ៩, ត្រង់កថាខណ្ឌពីទី១៦-១៧ ។

[១៨] ឯកសារលេខ E100/1, ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួមទី៣, *ដូចខាងលើ* កំណត់សំគាល់លេខ៨, ត្រង់កថាខណ្ឌពីទី៧-១០ ។ ឯកសារលេខ E99/2, ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងបទរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ, *ដូចខាងលើ* កំណត់សំគាល់លេខ៨, ត្រង់កថាខណ្ឌពីទី៦-៩ ។ ឯកសារលេខ E95/2, ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងជម្លោះប្រដាប់អាវុធ, *ដូចខាងលើ* កំណត់សំគាល់លេខ៨, ត្រង់កថាខណ្ឌពីទី៣-៧ ។

[១៩] ឯកសារលេខ E100/3, ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួមទី៣, *ដូចខាងលើ* កំណត់សំគាល់លេខ១០, ត្រង់កថាខណ្ឌទី១០ និង២២។ ឯកសារលេខ E99/3, ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងបទរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ, *ដូចខាងលើ* កំណត់សំគាល់លេខ១០, ត្រង់កថាខណ្ឌទី៦ និង១៧ ។ ឯកសារលេខ E95/3, ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងជម្លោះប្រដាប់អាវុធ, *ដូចខាងលើ* កំណត់សំគាល់លេខ១០, ត្រង់កថាខណ្ឌពីទី១៤-១៥ ។

ប្រឆាំងនឹងមនុស្សជាតិមួយ និងសំណើសុំអំពីសហកម្មឧក្រិដ្ឋកម្មរួមទី៣មិនអាចកំណត់ថាជាអញ្ញត្រកម្មទៅនឹងយុត្តាធិការ ដូចដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបានឡើយ។ ផ្ទុយទៅវិញ សំណើទាំងពីរនេះ បំភ្លឺពីអង្គហេតុនានាមួយចំនួនដែលត្រូវបង្ហាញសក្ខីកម្មនៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ គឺមានលក្ខណៈស្របគ្នាយ៉ាងខ្លាំងបំផុតជាមួយនឹងការកំណត់បទចោទពីបទរំលោភសេពសន្ថវៈដែលជាឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិមួយ ហើយថាទម្រង់នៃការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មនេះ ក៏អាចត្រូវបានរៀបរាប់តាមរយៈទម្រង់នៃការទទួលខុសត្រូវ JCE III ផងដែរ។ ហេតុនេះ អ្វីដែលកំពុងតែស្នើសុំនេះគឺជាការបន្ថែមពីលើឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដែលមិនបានចែងនៅក្នុងអត្ថបទបច្ចុប្បន្ននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

១៨- ដូចគ្នានេះដែរ សំណើអំពីជម្លោះប្រដាប់អាវុធ មិនមានជាការជំទាស់ទៅនឹងសេចក្តីចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អំពីកម្មវត្ថុស្តីពីយុត្តាធិការទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងស្រុងនោះឡើយ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញា កំពុងតែស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើវិសោធនកម្មនិយមន័យនៃបរិបទស្តីពីធាតុផ្សំនានានៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលបានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

១៩- ជាទីបញ្ចប់ សហព្រះរាជអាជ្ញាសង្កេតឃើញថា នៅក្នុងអម្លុងពេលនៃសវនាការបឋម មេធាវីការពារក្តីឱ្យ អៀង សារី នៅពេលកំពុងកំណត់លក្ខណៈនៃ “ពាក្យសុំស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”ថាជា “បញ្ហាទាក់ទងនឹងយុត្តាធិការ” ដែលស្ថិតនៅក្នុងវិសាលភាពនៃវិធាន ៨៩ បានទទួលស្គាល់ថា បញ្ហាស្តីពីថាតើ “ឧក្រិដ្ឋកម្មទាំងនេះនឹងត្រូវយកមកអនុវត្តត្រឹមកំរិតណានោះ” គឺ “មិនចាំបាច់” ជាបញ្ហាទាក់ទងនឹងយុត្តាធិការនោះទេ[២០]។

*ii. វិធានផ្ទៃក្នុងបានបែងចែកដាច់ពីគ្នា រវាងអញ្ញត្រកម្មបឋម និងការកំណត់បទចោទជាថ្មីឡើងវិញ*

២០- វិធានផ្ទៃក្នុងបានចែងនូវបញ្ញត្តិជាក់លាក់សម្រាប់ការកំណត់បទចោទឡើងវិញ និងអញ្ញត្រកម្មបឋមស្តីពីយុត្តាធិការ។ ប្រសិនបើរាល់សំណើសុំឱ្យកំណត់បទចោទឡើងវិញទាំងអស់ត្រូវបានចាត់ទុកថាជាអញ្ញត្រកម្មបឋមស្តីពីយុត្តាធិការនោះ វិធាន៩៨(២)នៃវិធានផ្ទៃក្នុងដែលអនុញ្ញាតឱ្យកំណត់បទចោទឡើងវិញ មុខជានឹងគ្មានន័យទៅហើយ។ ប្រការដែលនៅក្នុងវិធានផ្ទៃក្នុងចែងទាំងអំពីការកំណត់បទចោទឡើងវិញផង និងទាំងអំពីអញ្ញត្រកម្មបឋមស្តីពីយុត្តាធិការផង គឺជាការធ្វើឱ្យឃើញយ៉ាងច្បាស់ថា ទាំងនេះគឺសុទ្ធតែជាយន្តការផ្នែកនីតិវិធីដែលដាច់ដោយឡែកផ្សេងពីគ្នា។

---

[២០] ឯកសារលេខ E1/7.1, ប្រតិចារិក ត្រង់លេខ ERN 00713808, បន្ទាត់លេខ ១៤-១៨។

២១- អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយនៅក្នុងករណីរបស់ *ឌុច* [២១] ថា សំណើទាំងឡាយដែលសុំឱ្យកំណត់បទចោទឡើងវិញគឺវាមិនមែនជា *"អញ្ញត្រកម្មបឋម"* ដែលស្ថិតក្រោមវិធាន៨៩ នោះឡើយ។ ដូចដែលបានលើកឡើងនៅក្នុងការដាក់ឯកសារពីមុនៗរួចហើយថា ការសម្រេចដូចនេះគឺជាការបកស្រាយមួយត្រឹមត្រូវនូវវិធានផ្ទៃក្នុង ហើយដែលគួរតែយកមកអនុវត្តតាម នៅក្នុងករណីបច្ចុប្បន្ននេះ[២២]។

២២- លើសពីនេះ ទោះបីជាសំណើនានារបស់សហព្រះរាជអាជ្ញា អាចត្រូវបានដាក់ក្នុងនាមជាអញ្ញត្រកម្មបឋមអនុលោមតាមវិធាន៨៩ (១) នោះក៏ដោយក៏ នេះមិនមែនជាការច្រានចោលជាមុនមិនឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិនិត្យពិចារណាទៅលើសំណើទាំងនោះដែរ។ គឺវាមិនដូចគ្នានឹងអញ្ញត្រកម្មបឋម ដែលត្រូវតែធ្វើការសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងអនុលោមតាមវិធាន៨៩.៣ និងវិធាន៨០*ស្ទួន*.៣ នៃវិធានផ្ទៃក្នុងនោះឡើយ សំណើទាំងឡាយត្រូវបានដាក់ជូនដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិនិត្យនិងសម្រេចថាតើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាវាសក្តិសមនឹងធ្វើដូច្នេះដែរ ឬទេ?។

### *iii. សំណើទាំងឡាយគឺវាមិនអាចស្មើនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះឡើយ*

២៣- ទឡ្ហីករណ៍មួយទៀត ដែលបញ្ជូនមកដោយចម្លើយតបនានារបស់មេធាវីការពារក្តីមួយចំនួននោះសំខាន់បំផុតគឺថា សំណើទាំងនោះមានលក្ខណៈស្មើនឹងបណ្តឹងឧទ្ធរណ៍ណាមួយរបស់សហព្រះរាជអាជ្ញាដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ[២៣] និងលើការអនុវត្ត JCE III នៅ អវតក ដែរ[២៤]។ ខៀវ សំផន បានចង្អុលបង្ហាញពីសំណើរបស់សហព្រះរាជអាជ្ញាដែលសុំទៅអង្គជំនុំជម្រះសាលាដំបូងឱ្យធ្វើការ *"កែតម្រូវ"* និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានចែងនៅក្នុងដីកាដំណោះ

[២១] ឯកសារលេខ E188, សាលក្រម, ត្រង់កថាខណ្ឌទី ១៤ (*"ឌុច"*) ។

[២២] ឯកសារលេខ E9/30/2, ចម្លើយតបរបស់ សហព្រះរាជអាជ្ញា ទៅនឹងសេចក្តីសង្កេតរបស់ អៀង សារី , ចុះថ្ងៃទី១៨ ឧសភា ២០១១, លេខ ERN 00694582-85, ត្រង់កថាខណ្ឌទី៦។

[២៣] ឯកសារលេខ E427/2/15, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, ERN 00644462-571, ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់នួន ជា និង អៀង ធីរិទ្ធ ") ។ ឯកសារលេខ E427/1/30, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១១ មេសា ២០១១, ERN 00661785-994, ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ អៀង សារី") ។

[២៤] ឯកសារលេខ E97/14/15, សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម (JCE), ចុះថ្ងៃទី២០ ឧសភា ២០១០, ERN 00496521-89 ។

ស្រាយដែលត្រូវបានកែប្រែរួច ហើយបានផ្តល់អនុសាសន៍ថាពាក្យពេចន៍ដូចនេះគឺជាសញ្ញាមួយដែលបង្ហាញអំពីការព្យាយាម "លាក់បាំង" នៅពេលប្តឹងឧទ្ធរណ៍ (a disguise attempt at an appeal)[២៥]។ មេធាវី អៀង ធីរិទ្ធ បានរំលឹកឡើងវិញអំពីដីកាសន្និដ្ឋានកាលពីមុនរបស់សហព្រះរាជអាជ្ញាផ្ទាល់ នៅក្នុងពេលធ្វើសវនាការមួយនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅក្នុងខែមករា ឆ្នាំ ២០១១ថា ដីកាសម្រេច ទាំងឡាយរបស់អង្គបុរេជំនុំជម្រះគឺជាដីកាសម្រេចស្ថាពរ។ ចាប់តាំងពីពេលនោះមក គេបានធ្វើសេចក្តីសន្និដ្ឋានថា វិធីតែមួយគត់ដែលសហព្រះរាជអាជ្ញាអាចលើកឡើងបានអំពីអញ្ញត្រកម្មណាមួយជំទាស់ទៅនឹងនិយមន័យនៃឧក្រិដ្ឋកម្មនានានៅក្នុងដីកាដំណោះស្រាយកែប្រែរួចដែលត្រូវបានអនុម័តដោយអង្គបុរេជំនុំជម្រះហើយនោះ គឺមានតែតាមរយៈអញ្ញត្រកម្មបឋមប៉ុណ្ណោះ[២៦]។

២៤- សហព្រះរាជអាជ្ញា មិនប្រកែកតវ៉ាអំពីថា ដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះគឺជាដីកាសម្រេចស្ថាពរ និងបិទផ្លូវតវ៉ានោះទេ ។ ប៉ុន្តែសហព្រះរាជអាជ្ញា ច្រានចោលនូវអនុសាសន៍ ដោយការដាក់សំណើនានា ដែលពួកគេកំពុងតែព្យាយាមរកផ្លូវជៀសវាងពីវិធានផ្ទៃក្នុងហើយ *"ប្តឹងឧទ្ធរណ៍"* ប្រឆាំងនឹងដីកាពីមុនៗរបស់អង្គបុរេជំនុំជម្រះ។ ដោយការដាក់សំណើនានា សហព្រះរាជអាជ្ញាគ្រាន់តែសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យលើបញ្ហាខាងអង្គច្បាប់នានាដែលស្ថិតនៅក្នុងវង្វង់សិទ្ធអំណាចដើម្បីកំណត់សម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចែងជាក់លាក់ច្បាស់លាស់ ឬដោយបង្កប់ន័យ។ កង្វះខាតយន្តការសំរាប់បណ្តឹងឧទ្ធរណ៍មិនអាចឲ្យធ្វើការបកស្រាយថា ជាការកំរិតមិនឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ដើម្បីពិនិត្យពិចារណាលើបញ្ហាអង្គច្បាប់មួយចំនួន ដែលកាលពីមុនអង្គបុរេជំនុំជម្រះធ្លាប់បានលើកមកពិភាក្សានោះឡើយ។ ទោះបីជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបិទផ្លូវប្តឹងឧទ្ធរណ៍ក៏ដោយ ក៏សេចក្តីសម្រេចទាំងនោះមិនអាចឲ្យអង្គជំនុំជម្រះសាលាដំបូងជាប់កាតព្វកិច្ចត្រូវអនុវត្តតាមនោះបានដែរ។

## ខ. អង្គជំនុំជម្រះសាលាដំបូង មានអំណាចក្នុងការផ្តល់ការអនុញ្ញាតតាមសំណើ

### *i. វិធាន៩៨(២) អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង ផ្លាស់ប្តូរការកំណត់បទចោទចំពោះបទឧក្រិដ្ឋនានា (រួមទាំងទម្រង់នៃការទទួលខុសត្រូវ) ដូចបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ*

[២៥] ឯកសារលេខ E95/3, ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងជម្លោះប្រដាប់អាវុធ, *ដូចខាងលើ* កំណត់សំគាល់លេខ១០ , ត្រង់កថាខណ្ឌទី១៧។ ឯកសារលេខ E95/3, ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងបទរំលោភសេពសន្ថវៈដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ, *ដូចខាងលើ* កំណត់សំគាល់លេខ១០ , ត្រង់កថាខណ្ឌទី១៨ (" បណ្តឹងឧទ្ធរណ៍មួយដែលមានការលាក់បាំង") ។

[២៦] ឯកសារលេខ E95/2, ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងជម្លោះប្រដាប់អាវុធ, *ដូចខាងលើ* កំណត់សំគាល់លេខ៨ , ត្រង់កថាខណ្ឌទី១៧។ ឯកសារលេខ E100/1, ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួមទី៣, *ដូចខាងលើ* កំណត់សំគាល់លេខ៨ , ត្រង់កថាខណ្ឌទី៩ ។ ឯកសារលេខ E99/2, ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងបទរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ, *ដូចខាងលើ* កំណត់សំគាល់លេខ៨ , ត្រង់កថាខណ្ឌទី៨ ។

២៥- វិធាន៩៨(២) យោងច្បាស់លាស់ទៅលើអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្លាស់ប្តូរ "ការកំណត់បទចោទដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ។ នៅខណៈដែលវិធាន ៩៨(២) មិនសំដៅជាពិសេសទៅលើការកំណត់អង្គហេតុសមស្រប ដើម្បីធ្វើការផ្លាស់ប្តូរនូវទម្រង់នៃការទទួលខុសត្រូវ អំណាចដែលមានជាប់មកជាមួយស្រាប់របស់អង្គជំនុំជម្រះសាលាដំបូង ដូចបានបញ្ជាក់ជាក់ស្តែងនៅក្នុងវិធាន៩៨(២) ពិតជាពង្រីករហូតដល់ការផ្លាស់ប្តូរទៅលើការកំណត់អង្គហេតុដែលពាក់ព័ន្ធនឹងទម្រង់នៃចូលរួមប្រព្រឹត្តរបស់ជនជាប់ចោទ ចំពោះបទល្មើសជាសារវ័ន្តណាមួយ ។ អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តការបកស្រាយយ៉ាងដូច្នេះយ៉ាងច្បាស់ក្រឡែតក្នុងករណី *ឌុច*[២៧] ។

២៦- កន្លងមក អៀង សារី ធ្លាប់បានសារភាពថា សិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្លាស់ប្តូរការកំណត់បទចោទ អាចបញ្ចូលការផ្លាស់ប្តូរទៅក្នុងទម្រង់នៃការទទួលខុសត្រូវជាធរមានផងដែរ ជាពិសេស សហកម្មឧក្រិដ្ឋកម្មរួម (JCE)[២៨] ។ ក្នុងពេលជាមួយគ្នានេះ គាត់បានអះអាងថា ច្បាប់ជាធរមានរបស់កម្ពុជា "មិនអនុញ្ញាត" ឲ្យមានការកំណត់បទចោទឡើងវិញចំពោះទម្រង់នៃការទទួលខុសត្រូវទេ[២៩] ។ ចម្លើយតបថ្មីបំផុតរបស់គាត់មិនបាននិយាយអ្វីទាំងអស់ពីបញ្ហានេះ ។អៀង ធីរិទ្ធ អះអាងថាការកំណត់ឡើងវិញនៃ "អង្គហេតុ" ត្រូវបានអនុញ្ញាត ប៉ុន្តែការណ៍នេះគឺខុសគ្នានឹងការកំណត់ "បទចោទ"[៣០] ។ ទាក់ទិននឹងចំណុចនេះ ការអះអាងទាំងនេះ គឺជាការយល់ខុសចំពោះតួនាទីដ៏ត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងប្រព័ន្ធ អ.វ.ត.ក និងក្នុងច្បាប់កម្ពុជាដែលពឹងផ្អែកជាបឋមលើប្រពៃណីនៃច្បាប់ស៊ីវិល។

២៧- វិសាលភាពនៃអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់បទចោទឡើងវិញ ត្រូវបានកំណត់យ៉ាងច្បាស់ និងយ៉ាងត្រឹមត្រូវនៅក្នុងចម្លើយតបធ្វើឡើងដោយ ខៀវ សំផន ដែលគាត់បានពោលថា:

---

[២៧] ឯកសារលេខ **E188** ឌុច កំណត់សំគាល់ខាងដើមលេខ២១ ត្រង់កថាខ័ណ្ឌទី៤៩៣ ។

[២៨] ឯកសារលេខ **D94/14/14** សារណាតបរបស់ អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ១៨ មីនា ២០១០, ERN 00485345-75, ត្រង់កថាខ័ណ្ឌទី១២ ។

[២៩] ឯកសារលេខ **E9/30/1** សេចក្តីសង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបញ្ហាច្បាប់ដែលសហព្រះរាជអាជ្ញាមានបំណងលើកនៅសវនាការបឋម, ៣ ឧសភា ២០១១, ERN 00686131-38, ត្រង់កថាខ័ណ្ឌទី១០ ។

[៣០] ឯកសារលេខ **E100/1** ចម្លើយតបរបស់ អៀង ធីរិទ្ធិ ពាក់ព័ន្ធនឹង JCE III, កំណត់សំគាល់ខាងដើមលេខ៨ ត្រង់កថាខ័ណ្ឌទី១២; ឯកសារលេខ **E99/2** ចម្លើយតបរបស់ អៀង ធីរិទ្ធិ ពាក់ព័ន្ធនឹងបទរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, កំណត់សំគាល់ខាងដើមលេខ៨ ត្រង់កថាខ័ណ្ឌទី១២ ។

*ការកំណត់អង្គហេតុឡើងវិញ គឺជាដំណើរការដែលចៅក្រមបង្កើតឡើងវិញ នៃការកំណត់អំពីអំពើ ឬ អង្គហេតុ ណាមួយឲ្យបានច្បាស់... តាមរយៈការពិនិត្យលើភស្តុតាងនានា ដើម្បីធានាចំពោះភាពស៊ីសង្វាក់គ្នានៃអង្គហេតុជាមួយនឹងការកំណត់បទចោទដែលសមស្របបំផុត នៅក្នុងយុត្តាធិការនៃតុលាការណាមួយ*[៣១] ។

ការបកស្រាយចំពោះវិធាន៩៨(២) នេះ គឺជាការស្របគ្នាបំផុតជាមួយនឹងវិធាន៦៧(២) ដែលតម្រូវឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវ "កំណត់" អង្គហេតុពិតជាក់ស្តែង និង "លក្ខណៈនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ" ។ សហព្រះរាជអាជ្ញាសូមធ្វើការបញ្ជាក់អះអាងថា ការកំណត់សកម្មភាពរបស់ជនជាប់ចោទដែលសមស្របបំផុត គឺការបញ្ជាក់យ៉ាងហោចណាស់ឲ្យបាននូវឧក្រិដ្ឋកម្មជាសារវន្តមួយ និងយ៉ាងហោចណាស់ពីទម្រង់នៃការទទួលខុសត្រូវមួយ ។ បើគេពុំមានការកំណត់ឲ្យបានពេញលេញនូវ "លក្ខណៈនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ" របស់ជនជាប់ចោទតាមមធ្យោបាយដែលគ្របដណ្តប់ទាំងឧក្រិដ្ឋកម្មនានា និងទម្រង់នៃការទទួលខុសត្រូវដូចនេះទេ ម្ល៉េះដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងត្រូវបានទុកជាមោឃៈជាមិនខានដោយសារតែវិការៈនៃនីតិវិធី ក្រោមវិធាន៦៧(២) ហើយក៏មិនអាចដំណើរការទៅដល់សវនាការជំនុំជម្រះបានដែរ ។ តាមរយៈសំណើសុំឲ្យកំណត់បទរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងសំណើសុំទាក់ទងនឹង JCE III នេះ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបញ្ចូលឧក្រិដ្ឋកម្មមួយនេះ និងទម្រង់នៃការទទួលខុសត្រូវជាជម្រើសម្យ៉ាងទៀតដ៏សមស្របមួយ អោយស្ថិតក្នុងយុត្តាធិការរបស់តុលាការយ៉ាងត្រឹមត្រូវ ដែលពុំមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបច្ចុប្បន្ន ។

២៨- ដូចបានកត់សំគាល់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី*ឌុច* ច្បាប់ CCPC មិនបានសំដៅជាក់លាក់លើការកំណត់ឡើងវិញនៃទម្រង់នៃការទទួលខុសត្រូវទេ[៣២] ។ ដោយអវត្តមាននៃសេចក្តីអធិប្បាយជាលាយល័ក្ខណ៍អក្សរដែលបង្រួបបង្រួមនូវទម្លាប់នៃការអនុវត្តដោយតុលាការនៅក្រោមច្បាប់ CCPC នោះសហព្រះរាជអាជ្ញាបានដឹងថា តុលាការកម្ពុជាដែល*សម្រេចរួមជាក្រុម* តែងធ្វើការកែសម្រួលទៅលើការកំណត់ទម្រង់នៃការទទួលខុសត្រូវ អាចអនុវត្តបានចំពោះបទឧក្រិដ្ឋដោយ

---

[៣១] ឯកសារលេខ **E95/3** ចម្លើយតបរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ, កំណត់សំគាល់ខាងដើមលេខ១០ ត្រង់កថាខ័ណ្ឌទី១០ (ការកំណត់បទចោទឡើងវិញ ដោយយោងទៅលើការពិនិត្យភស្តុតាង ដើម្បីឲ្យត្រូវគ្នា នឹងអង្គហេតុនានាជាមួយនឹងការកំណត់ដ៏សមស្របបំផុត ដែលគេបាននិងកំពុងតែយល់ថា ជាការពិតការកំណត់បទចោទដ៏សមស្របបំផុតនោះ គឺបញ្ហាច្បាប់ និងស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ ។) ក្នុងករណីផ្សេងពីនេះ អង្គជំនុំជម្រះត្រូវតែប្រកាសយ៉ាងសាមញ្ញថាខ្លួនគ្មានយុត្តាធិការទៅលើរឿងនេះឡើយ") (សង្កត់ន័យតាមពាក្យដើម) ។ សូមអានផងដែរ ឯកសារលេខ **E99/3** ចម្លើយតបរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងបទរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, កំណត់សំគាល់ខាងដើមលេខ១០ ត្រង់កថាខ័ណ្ឌទី១០-១១ ។ ឯកសារលេខ **E100/3** ចម្លើយតបរបស់ ខៀវ សំផន ពាក់ព័ន្ធនឹង JCE III, កំណត់សំគាល់ខាងដើមលេខ១០ ត្រង់កថាខ័ណ្ឌទី១៤-១៥ ។

[៣២] ឯកសារលេខ **E188** *ឌុច* កំណត់សំគាល់ខាងដើមលេខ២១ ត្រង់កថាខ័ណ្ឌទី៤៩៣ ដោយលើកយោងបទប្បញ្ញត្តិ៥៥ នៃ*បទប្បញ្ញត្តិរបស់តុលាការអន្តរជាតិ,* ICC-BD/01-01-4 (ចូលជាធរមាននៅថ្ងៃទី២៦ ឧសភា ២០០៤) ។

ពុំចាំបាច់បញ្ជូនសំណុំរឿងត្រឡប់ទៅព្រះរាជអាជ្ញាវិញទេ ហើយការធ្វើដូច្នេះ គឺដោយផ្អែកទៅលើមាត្រា៣៤៨ នៃច្បាប់ CCPC ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងអាចចាប់យកសច្ចទស្សន៍តុលាការអំពីទម្លាប់នៃការអនុវត្តជាទៀងទាត់ដូច្នេះពីតុលាការកម្ពុជា ដើម្បីធ្វើជា "អង្គហេតុនៃចំណេះដឹងរួមមួយ"[៣៣]។

២៩- សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាថា មិនដូចគ្នានឹងយុទ្ធសាស្ត្រនៃប្រព័ន្ធច្បាប់ Common Law ក្នុងការស្វែងរកការពិត ដែលផ្អែកលើការប្រឈមមុខ នៃការសួរដេញដោលអំពីអង្គហេតុ និងច្បាប់ដែលបានផ្តល់ដោយរដ្ឋ និងចុងចោទនោះទេ ប្រព័ន្ធច្បាប់ស៊ីវិល គឺមានចរិតលក្ខណៈស្វែងរកការពិតតាមផ្លូវតុលាការ និងមិនមានទំនោរពឹងផ្អែកលើយន្តការនានាដូចជា ការកែប្រែជាផ្លូវការណ៍លើបទចោទ ឬធ្វើឧបាស្រ័យដើម្បីបន្ថយបទល្មើសដែលបានដាក់បញ្ចូលរួចហើយ ដើម្បីដោះស្រាយការបែងចែកដាច់ពីគ្នារវាងអង្គហេតុដែលបានចោទប្រកាន់ និងច្បាប់ជាធរមាននោះឡើយ ។ ដូចអ្នកពន្យល់ និងបកស្រាយច្បាប់មួយរូបធ្វើការសង្កេត ដោយយោងទៅលើច្បាប់នីតិវិធីរបស់តំណាងប្រព័ន្ធច្បាប់ស៊ីវិលចំនួនប្រាំបី យ៉ាងដូច្នេះថា៖

*នៅក្នុងយុត្តាធិការនៃច្បាប់ស៊ីវិលទាំងនេះ ចៅក្រមមានទាំងសិទ្ធិ និងថែមទាំងតម្រូវឱ្យកំណត់អំពីច្បាប់... ។ គោលគំនិតដ៏សកម្មនៃតួនាទីរបស់ចៅក្រមនេះ មានការជាប់ជំពាក់ទៅនឹងការប្រព្រឹត្តចំពោះធាតុផ្សំនៃច្បាប់ចំពោះបទល្មើសដែលបានចោទប្រកាន់ ។ យុត្តាធិការនៃច្បាប់ស៊ីវិលតែងតែបង្កលទ្ធភាពឱ្យចៅក្រមផ្តល់គុណវុឌ្ឍិលើអង្គហេតុនានាដែលបានដាក់ជូនដោយការិយាយអយ្យការក្នុងទម្រង់ខុសគ្នាមួយដែលស្របច្បាប់ ជាងឯកសារដែលមានផ្ទុកនូវបទចោទនោះ ដោយពុំចាំបាច់តម្រូវឱ្យមានការកែប្រែនូវបទចោទ ។ យុទ្ធសាស្ត្រដូច្នេះ គឺត្រូវបានពឹងផ្អែកជាមូលដ្ឋានតាមការយល់ថា ការកំណត់បទចោទដោយអយ្យការ គឺគ្រាន់តែជាអនុសាសន៍មួយប៉ុណ្ណោះ នៅខណៈដែលចៅក្រមមានការទទួលខុសត្រូវក្នុងការកំណត់សម្រេចនៅលើខ្លឹមសារជាសារវ័ន្ត អំពីសវនាការជំនុំជម្រះដោយឈរលើមូលដ្ឋាននៃអង្គហេតុនានាដែលបានដាក់ជូនដោយគូភាគី*[៣៤] ។

៣០- ទន្ទឹមនេះ សហព្រះរាជអាជ្ញាសូមសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង ដែលមានចរិតលក្ខណៈអាចប្រៀបធៀបបានសមស្របបំផុតទៅនឹង*ការសម្រេចរួមជាក្រុមរបស់* តុលាការ នៅក្នុងប្រព័ន្ធយុត្តិធម៌

---

[៣៣] អំណាចដែលមានជាប់មកជាមួយក្នុងការចាប់យកសច្ចទស្សន៍តុលាការនៃអង្គហេតុពាក់ព័ន្ធនឹងចំណេះដឹងជាធម្មតា នៅខណៈដែលមិនបានចែងច្បាស់លាស់នៅក្នុងវិធាននានាត្រូវបានយកមកសំអាងដោយអង្គបុរេជំនុំជម្រះនៅក្នុងឯកសារលេខ C9/4/7 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តឋិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ៤ ឧសភា ២០០៩, ERN 00303454-70, ត្រង់កថាខ័ណ្ឌទី៤២ ។

[៣៤] Carsten Stahn, "ការកែតម្រូវលើការកំណត់អង្គហេតុនៅក្នុងប្រព័ន្ធតុលាការ ICC: ជារូបភាពបង្ហាញមួយនៃបទប្បញ្ញត្តិ៥៥" (២០០៥) ១៦ ទេទិការស្តីពីច្បាប់ព្រហ្មទណ្ឌ 1-31 ត្រង់ទំព័រទី៥ ។

របស់កម្ពុជា អាចកំណត់អង្គហេតុយ៉ាងត្រឹមត្រូវនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីផ្ទុះបញ្ចាំងនូវឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវសមស្របទៅនឹងអង្គហេតុទាំងនោះ ។

*ii. អង្គជំនុំជម្រះសាលាដំបូង មានអំណាចកែប្រែនិយមន័យច្បាប់ទាក់ទងនឹងបទឧក្រិដ្ឋ ដែលបានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ*

៣១- មេធាវីការពារក្តី អៀង ធីរិទ្ធ, អៀង សារី និង ខៀវ សំផន តវ៉ានៅក្នុងចម្លើយតបរបស់ខ្លួនថា សំណើពាក់ព័ន្ធជម្លោះប្រដាប់អាវុធ ស្នើឱ្យមានការកែប្រែលើនិយមនៃច្បាប់ជាធរមាន ជាជាងស្នើឱ្យធ្វើការកំណត់បទចោទឡើងវិញ ។ ដូច្នេះ ពួកគេអះអាងថា សំណើនេះមិនធ្លាក់ក្នុងវិសាលភាពនៃវិធាន៩៨(២)ទេ និងមិនអាចអនុញ្ញាតដោយអង្គជំនុំជម្រះសាលាដំបូងឡើយ[៣៥]។ ជាការឆ្លើយតបសហព្រះរាជអាជ្ញាបំភ្លឺថា សំណើពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ មិនអះអាងថាជាសំណើសុំឱ្យធ្វើការកំណត់បទចោទឡើងវិញផ្អែកតាម វិធាន៩៨(២) ទេ ។ ផ្ទុយទៅវិញ វាជាសំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធានាចំពោះភាពត្រឹមត្រូវនៃច្បាប់ដែលបានអនុវត្តនៅ អ.វ.ត.ក ស្របតាមគោលការណ៍ *iura novit curia* ដ៏ទូលំទូលាយ ។

៣២- វិធាន៩៨(២) បានចារិកទុកនូវចំណុចមួយនៃគោលការណ៍ *iura novit curia* នេះ ដែលគេឱ្យឈ្មោះថា អំណាចរបស់តុលាការដើម្បីកំណត់បទចោទឡើងវិញដោយឈរលើមូលដ្ឋាននៃអង្គហេតុនានាដែលបានបង្ហាញនៅចំពោះមុខតុលាការនេះ ។ ប៉ុន្តែ វិធាន៩៨(២) នេះ មិនបានចារិកទុកនូវគោលការណ៍ *iura novit curia* ទាំងមូលទេ ដែលរួមមានទាំងការកំណត់និយមន័យឱ្យបានត្រឹមត្រូវចំពោះច្បាប់ជាធរមានផង ។

៣៣- ដោយសារគ្មានគោលការណ៍ណែនាំនៅ អ.វ.ត.ក ឬ ប្រភពច្បាប់កម្ពុជា វាជាការសមស្របដែលត្រូវក្រឡេកមើលគោលការណ៍ណែនាំស្តីពីវិសាលភាពនិងការអនុវត្តគោលការណ៍ *iura novit curia* ដ៏មានសំខាន់នៅក្នុងករណីយុត្តិសាស្ត្រអន្តរជាតិ ។ តុលាការយុត្តិធម៌អន្តរជាតិ បានបញ្ជាក់អះអាងនៅក្នុងឱកាសមួយចំនួនថា វាជាតួនាទីរបស់តុលាការដើម្បីកំណត់សម្រេចនៅលើច្បាប់ជាធរមានទៅតាមករណីនោះ ។ ក្នុងករណីរឿងក្តី *យុត្តាធិការជលផល(Fisheries Jurisdiction)*, តុលាការបានសម្រេចថា៖

[៣៥] ឯកសារលេខ E95/2 ចម្លើយតបរបស់ អៀង ធីរិទ្ធ ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ, កំណត់សំគាល់ខាងដើមលេខ៨ ត្រង់កថាខ័ណ្ឌទី៨ និងកថាខ័ណ្ឌទី១០-១១ ។ ឯកសារលេខ E95/3 ចម្លើយតបរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ, កំណត់សំគាល់ខាងដើមលេខ១០ ត្រង់កថាខ័ណ្ឌទី១១-១៣ ។

> *តុលាការ... ហាក់ដូចជាបានយកសច្ចទស្សន៍តុលាការតាមច្បាប់អន្តរជាតិ តម្រូវឲ្យ... ពិចារណាដោយឥស្សរចិត្តទៅលើវិធាននៃច្បាប់អន្តរជាតិទាំងអស់ដែលអាចនឹងពាក់ព័ន្ធទៅនឹងដំណោះស្រាយនៃជម្លោះ ។ វាជាភារកិច្ចរបស់តុលាការខ្លួនឯង ដើម្បីធ្វើឲ្យប្រាកដ និងដើម្បីអនុវត្តច្បាប់ដែលពាក់ព័ន្ធទៅតាមកាលៈទេសៈនៃរឿងក្ដី ដែលនោះជាបន្ទុកក្នុងការកំណត់ឬ ផ្ដល់ការបញ្ជាក់ចំពោះវិធាននៃច្បាប់អន្តរជាតិដែលថា មិនអាចអនុវត្តបានចំពោះភាគីណាមួយ,ចំពោះច្បាប់ដែលស្ថិតនៅក្នុងចំណេះដឹងរបស់តុលាការ*[៣៦] ។

៣៤- តុលាការយុត្តិធម៌អឺរ៉ុប ក៏បានធ្វើសេចក្ដីប្រកាសស្រដៀងគ្នានេះដែរ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់តុលាការនៅក្នុងការកំណត់សម្រេចអំពីអត្ថន័យដែលត្រឹមត្រូវនៃច្បាប់ជាធរមាន ដោយថ្លែងយ៉ាងដូច្នេះថា៖

> *យោងតាមគោលការណ៍ iura novit curia ការកំណត់សម្រេចអំពីអត្ថន័យនៃច្បាប់ មិនស្ថិតនៅក្នុងវិសាលភាពនៃការអនុវត្តគោលការណ៍ណាមួយ ដែលអនុញ្ញាតឲ្យគូភាគីកំណត់សម្រេចដោយសេរីលើវិសាលភាពនៃករណីទេ និងថាបើដូច្នេះ តុលាការសហគមន៍ (Community Court) មិនជាប់កាតព្វកិច្ចក្នុងការជូនដំណឹងដល់គូភាគីអំពីការបកស្រាយដែលខ្លួនមានបំណងផ្ដល់ជូន ដើម្បីបង្កលក្ខណៈឲ្យពួកគេសម្របគោលជំហរទៅតាមកម្មវត្ថុនោះឡើយ*[៣៧] ។

៣៥- ទោះបីមិនមានចែងច្បាស់នៅក្នុងវិធាននានាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងអាចមានការពឹងផ្អែកទៅលើគោលការណ៍ *iura novit curia* ដ៏ទូលំទូលាយដើម្បីឲ្យប្រាកដប្រជា និងដើម្បីអនុវត្តច្បាប់ត្រឹមត្រូវដែលជាផ្នែកនៃការប្រើប្រាស់សិទ្ធិអំណាចដែលមានជាប់មកជាមួយរបស់ខ្លួន ។ ជាការពិតណាស់ នេះជាអភិក្រមដែលត្រូវបានចាប់យកដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី *ឌុច* ពាក់ព័ន្ធនឹងបទចោទចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ទោះបីនិយមន័យនៃបទឧក្រិដ្ឋដូចមានចែងនៅក្នុងច្បាប់ អ.វ.ត.ក មិនត្រូវបានតវ៉ាដោយមេធាវីការពារក្ដីក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ខ្លួនមានការទទួលខុសត្រូវដោយឯករាជ្យដើម្បីអះអាងថា ឧក្រិដ្ឋកម្មគឺពិតជាបានឆ្លុះបញ្ចាំងទៅនឹងច្បាប់ទម្លាប់អន្តរជាតិនៅក្នុងសម័យកាលដែលពាក់ព័ន្ធ ដោយបានថ្លែងយ៉ាងដូច្នេះថា៖

---

[៣៦] យុត្តាធិការជលផល (សាធារណសហព័ន្ធអាល្លឺម៉ង់ ទល់នឹងអ៊ីស្លង់), អង្គសេចក្ដី, សាលក្រម, I.C.J. របាយការណ៍ 1974, ទំព័រ 175 ត្រង់កថាខ័ណ្ឌទី 181; យុត្តាធិការជលផលចក្រភពអង់គ្លេស ទល់នឹង Iceland ), អង្គសេចក្ដី, សាលក្រម, I.C.J. របាយការណ៍ 1974, ទំព័រ 3 កថាខ័ណ្ឌទី 9; សូមអានផងដែរ សកម្មភាពយោធា និងយោធាប្រតិព័ទ្ធ នៅក្នុង និងប្រឆាំងនឹងនីការ៉ាហ្គ័រ (នីការ៉ាហ្គ័រ ទល់នឹងសហរដ្ឋអាមេរិក), អង្គសេចក្ដី, សាលក្រម, ២៧ មិថុនា ១៩៨៦, I.C.J. របាយការណ៍ 1986, ទំព័រ 14 ត្រង់កថាខ័ណ្ឌទី 24-25 ។

[៣៧] *គណៈកម្មការ ទល់នឹង Roodhuijzen*, សំណុំរឿងលេខ T-58/08 P, សាលក្រមរបស់សាលាដំបូង, ៥ តុលា ២០០៩ ។

*ដោយពុំគិតពីបញ្ហាយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះកម្មវត្ថុនោះ បទឧក្រិដ្ឋដែលបានចោទប្រកាន់ និងទម្រង់នៃការទទួលខុសត្រូវនិមួយៗ ត្រូវតែអនុលោមទៅនឹងគោលការណ៍នីត្យានុកូលភាព*[៣៨] ។

៣៦- ជាទម្លាប់នៃការអនុវត្តជាធម្មតាផងដែរនៅតាមបណ្តាតុលាការព្រហ្មទណ្ឌអន្តរជាតិ និងអន្តរជាតូបនីយកម្មដទៃទៀត ចំពោះតុលាការត្រូវកំណត់សម្រេចដោយឯករាជ្យថា ខ្លួនកំពង់តែអនុវត្តច្បាប់ដែលត្រឹមត្រូវ ។ ដូចបានបញ្ជាក់ដោយតុលាការអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) ក្នុងរឿងក្តី *Vasilijević* ថា "អង្គជំនុំជម្រះសាលាដំបូងនិមួយៗ ត្រូវមានកាតព្វកិច្ចធានាឲ្យប្រាកដថា ច្បាប់ដែលខ្លួនអនុវត្តចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ ពិតជាស្រ័បទៅតាមទម្លាប់"[៣៩] ។

*៣៧*- នៅក្នុងបរិបទខុសគ្នាមួយ ក្នុងករណីរឿងក្តី *Tadić* នៅចំពោះតុលាការ ICTY ផ្តល់នូវការបង្ហាញដ៏មានសារប្រយោជន៍មួយផ្សេងទៀតអំពីការអនុវត្តទ្រឹស្តីនៃអំណាចដែលមានជាប់មកជាមួយ ដើម្បីកំណត់សម្រេចពីបញ្ហាច្បាប់ដែលមិនបានបញ្ជាក់ច្បាស់លាស់ដោយឯកសារសំខាន់ៗ ដែលបង្កើតតុលាការ។ ក្នុងករណីនោះ ICTY បានពឹងផ្អែកលើទ្រឹស្តីនៃអំណាចដែលមានជាប់មកជាមួយ ដើម្បីធ្វើការសន្និដ្ឋានចុងក្រោយថា ខ្លួនមានយុត្តាធិការដើម្បីសួរនាំអំពីនីត្យានុកូលភាពនៃការបង្កើតរបស់ខ្លួនឯងផ្ទាល់ ។ តុលាការនេះបានរៀបរាប់ពីអំណាចដែលមានជាប់មកមួយរបស់ខ្លួនក្នុងការអនុវត្តការណ៍នេះដូច្នេះថាជា *"ទាញយកដោយស្វ័យប្រវត្តិពីការអនុវត្តមុខងារតុលាការ"*[៤០] ហើយបានរកឃើញថាអំណាចដូច្នេះ *"មិនចាំបាច់មានចែងច្បាស់លាស់ក្នុងឯកសារសំខាន់ដែលបង្កើត [សាលាជម្រះតុលាការ ឬសាលាក្តីមជ្ឈត្តការណាមួយទេ]"*[៤១] ។

៣៨- សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងច្បាស់ណាស់ថាមានអំណាចដូច្នេះ ជាការពិតគឺមានការទទួលខុសត្រូវដូច្នេះ ក្នុងការកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីធានាដល់ការឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវពិតប្រាកដចំពោះច្បាប់ជាធរមាន ។

## គ. នៅក្នុងអំឡុងពេលពាក់ព័ន្ធ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនតម្រូវឲ្យមានទំនាក់ទំនង

---

[៣៨] ឯកសារលេខ E188 *ខុច* កំណត់សំគាល់ខាងដើមលេខ២៣ ត្រង់កថាខ័ណ្ឌទី២៦ ។

[៣៩] *រដ្ឋអាជ្ញា ទល់នឹង Mitar Vasiljević*, IT-98-32-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២៩ កញ្ញា ២០០២, ត្រង់កថាខ័ណ្ឌទី១៩៨ ។

[៤០] *រដ្ឋអាជ្ញា ទល់នឹង Duško Tadić*, IT-94-1-A, សាលដីកាលើញត្តិរបស់មេធាវីការពារក្តី សុំធ្វើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំអំពីយុត្តាធិការ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY), ២ តុលា ១៩៩៥, ត្រង់កថាខ័ណ្ឌទី១៤ ។

[៤១] *ក្នុងឯកសារដដែលដូចខាងលើ*, ត្រង់កថាខ័ណ្ឌទី១៨ ។

# ជាមួយនឹងជម្លោះប្រដាប់អាវុធសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ

៣៩- សំណើទាក់ទងនឹងជម្លោះប្រដាប់អាវុធបានស្នើសុំ អង្គជំនុំជម្រះសាលាដំបូងសម្រេចដកចេញនូវលក្ខខណ្ឌកំណត់អំពីទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធនៅក្នុងដីកាដំណោះស្រាយដែលត្រូវបានកែប្រែ។ ប្រសិនត្រូវបានអនុញ្ញាត ការកែប្រែនេះនឹងធ្វើឱ្យមានការអនុវត្តឡើងវិញនូវនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងនៅក្នុង មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលមិនរាប់បញ្ចូលអំពីភាពទាក់ទងគ្នានឹងជម្លោះប្រដាប់អាវុធនោះទេ។ បន្ថែមពីលើបញ្ហានីតិវិធីដែលបានលើកឡើងខាងលើ ចម្លើយតបរបស់សហមេធាវីការពារក្តីបានជំទាស់ទៅនឹងសំណើទាក់ទងនឹងជម្លោះប្រដាប់អាវុធលើផ្នែកអង្គសេចក្តី។

៤០- ចម្លើយតបទាក់ទងនឹងជម្លោះប្រដាប់អាវុធរបស់ ខៀវ សំផន បង្ហាញទឡ្ហីករណ៍ថ្មីថា ទោះបីជាភាពទាក់ទងគ្នានឹងជម្លោះប្រដាប់អាវុធមិនត្រូវបានរួមបញ្ចូលឱ្យបានច្បាស់លាស់នៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏ដោយ ក៏ជម្លោះប្រដាប់អាវុធនៅតែជាលក្ខខណ្ឌកំណត់មួយ។ ការបកស្រាយនេះ បានផ្អែកលើមូលដ្ឋានស្តីពីលក្ខខណ្ឌកំណត់ដូចបានលើកឡើង នៅក្នុងផ្នែកដែលមានចំណងជើងថាការវាយប្រហារត្រូវកំណត់ធ្វើឡើងទៅលើ "ប្រជាជនស៊ីវិល"។ ខៀវ សំផន លើកឡើងថា ក្នុងករណីអវត្តមាននៃជម្លោះប្រដាប់អាវុធ ការសំដៅទៅលើប្រជាជនស៊ីវិលនឹង "មានលក្ខណៈស្រពិចស្រពិលជាខ្លាំង"[៤២]។ ទឡ្ហីករណ៍នេះគឺគ្មានមូលដ្ឋានទេ។ ទីមួយ សូម្បីតែនៅក្នុងពេលមានសន្តិភាពក៏ដោយ បុគ្គលិកយោធាត្រូវបានបែងចែកខុសពីជនស៊ីវិល និងអាចត្រូវបានកំណត់គោលដៅសម្រាប់ការវាយប្រហារ។ ទីពីរ ការសំដៅលើប្រជាជនស៊ីវិលត្រូវបានចែងនៅក្នុងលិខិតូបករណ៍អន្តរជាតិផ្សេងទៀត រួមទាំង*ច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា* ("ច្បាប់លក្ខន្តិកៈ ICTR")[៤៣] និង *ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ*

[៤២] ឯកសារលេខ **E95/3** ចម្លើយតបរបស់លោក ខៀវ សំផន ទាក់ទិននឹងជម្លោះប្រដាប់អាវុធ *ដូចជើងទំព័រ* លេខ១០ កថាខណ្ឌ២៣។

[៤៣] លក្ខន្តិកៈតុលាការ ICTR ឧបសម្ព័ន្ធរបស់សេចក្តីសម្រេចចិត្តលេខ ៩៥៥ របស់ក្រុមប្រឹក្សាសន្តិសុខ ឯកសារអង្គការសហប្រជាជាតិលេខ S/RES/955 (ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤) មាត្រា៣។ *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម សំណុំរឿងលេខ ICTR-96-4-T (អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTR) ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨

("ច្បាប់លក្ខន្តិកៈ ICC")[៤៤] នៅពេលដែលគ្មានលក្ខខណ្ឌកំណត់ដោយមិនអាចប្រកែកបានថា ការវាយប្រហារមានការទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ។

៤១- ក្រៅពីការលើកឡើងខាងលើ ការគាំទ្ររួមទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្ដីទៅនឹងសំណើទាក់ទងនឹងជម្លោះប្រដាប់អាវុធគឺថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិតម្រូវឲ្យមានជារិដ្ឋមាននូវទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងអំឡុងពេលពាក់ព័ន្ធ ឬមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់អំពីចំណុចនេះ ដើម្បីធ្វើយុត្តិកម្មការមិនបញ្ចូលទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។

៤២- ឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពាក់ព័ន្ធនឹងលក្ខខណ្ឌកំណត់អំពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងរួចហើយ នៅក្នុងរឿងក្ដី *ឌុច*[៤៥] និងដោយអង្គបុរេជំនុំជម្រះនៅក្នុងសាលដីកាលើបណ្ដឹងឧទ្ធរណ៍ ដែលធ្វើឡើងដោយជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ[៤៦]។ ឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិពាក់ព័ន្ធនឹងលក្ខខណ្ឌកំណត់អំពី

---

កថាខណ្ឌ៥៦៥ (*រកឃើញថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ...ត្រូវបានហាមប្រាម ដោយមិនគិតថាតើឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តក្នុងជម្លោះប្រដាប់អាវុធ មានចរិតលក្ខណៈជាអន្តរជាតិ ឬផ្ទៃក្នុង*")។

[៤៤] លក្ខន្តិកៈតុលាការ ICC ឯកសារអង្គការសហប្រជាជាតិលេខ A/CONF.183/9 ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ មាត្រា៧។ ក៏សូមមើល ធាតុផ្សំនៃបទឧក្រិដ្ឋ (តុលាការ ICC ឆ្នាំ២០១១) នៅទំព័រទី៥ (ចែងថា ការវាយប្រហារទៅលើប្រជាជនស៊ីវិល "*មិនចាំបាច់តែជាការវាយប្រហារផ្នែកយោធាប៉ុណ្ណោះនោះទេ*")។

[៤៥] អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ការមិនរាប់បញ្ចូលទំនាក់ទំនងជម្លោះប្រដាប់អាវុធក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងមាត្រា៥នៃច្បាប់អ.វ.ត.ក ធ្វើឡើងស្របនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងពេលវេលាពាក់ព័ន្ធ។ សេចក្ដីសម្រេចនេះធ្វើឡើងដោយពឹងផ្អែកទៅលើការពិនិត្យឡើងវិញនូវការអនុវត្តរបស់រដ្ឋនៅសហសម័យ យុត្តិសាស្ត្រនានានៅកម្រិតតំបន់ និងកម្រិតអន្តរជាតិ និងរបាយការណ៍នៃក្រុមអ្នកជំនាញគូសបញ្ជាក់អំពីការបង្កើតអ.វ.ត.ក។ ឯកសារលេខ **E188** *សាលក្រមក្នុងសំណុំរឿង ឌុច* ដូចជើងទំព័រ២១ កថាខណ្ឌ២៩១-២៩៦។

[៤៦] អង្គបុរេជំនុំជម្រះបានធ្វើសេចក្ដីសន្និដ្ឋានដ៏ចម្រូងចម្រាសមួយទៅលើសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ពុំមានការអនុវត្តរបស់រដ្ឋច្បាស់លាស់ និងសច្ចធារណ៍ធម្មានុរូប" ទាក់ទិននឹងលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងជម្លោះប្រដាប់អាវុធក្នុងអំឡុងពេលពាក់ព័ន្ធ។ ឯកសារលេខ **D427/1/30** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ដូចជើងទំព័រលេខ ៩ កថាខណ្ឌ៣១០។ ឯកសារលេខ **D427/2/15** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធារិទ្ធិ ដូចជើងទំព័រ

ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ក៏ជាប្រធានបទនៃសារណាជាលាយលក្ខណ៍អក្សរដ៏ធំទូលាយដែលធ្វើឡើងដោយគ្រប់ភាគីទាំងអស់ផងដែរ។ ជាពិសេស សហព្រះរាជអាជ្ញាធ្វើការចង្អុលបង្ហាញ និងអនុម័តតាមរយៈការយោងនូវសារណានានាកាលពីមុនរបស់ខ្លួន ដើម្បីគាំទ្រទឡ្ហីករណ៍ដែលថានៅក្នុងអំឡុងពេលពាក់ព័ន្ធច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនតម្រូវឱ្យមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនោះទេ[៤៧]។

៤៣- តាមការយល់ឃើញពីលក្ខណៈធំទូលាយនៃសារណានានាកាលពីមុន សារណាតបនេះគ្រាន់តែលើកឡើងពីទឡ្ហីករណ៍ដែលត្រូវបានលើកឡើងផ្ទាល់ដោយក្រុមមេធាវីការពារក្តី ដែលមាននៅក្នុងចម្លើយតបថ្មីៗបំផុតរបស់ខ្លួន ឬបញ្ហាផ្សេងទៀតដែលតម្រូវឱ្យមានការបំភ្លឺថែមទៀតប៉ុណ្ណោះ។

*i. ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ និងគោលការណ៍ Nuremberg មិនចាំបាច់ធ្វើការផ្ទុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិពាក់ព័ន្ធ ទៅនឹងលក្ខខណ្ឌកំណត់អំពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ*

៤៤- នៅក្នុងចម្លើយតបទាក់ទងនឹងជម្លោះប្រដាប់អាវុធ អៀង សារី លើកឡើងម្តងទៀតអំពីការអះអាងកាលពីមុនរបស់ខ្លួនថា ទាំងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ទាំងគោលការណ៍Nuremberg ដែលតម្រូវឱ្យមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ គួរតែត្រូវបានចែងថាបានផ្តល់នូវនិយមន័យដែលយកជាការបានស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩[៤៨]។ ចម្លើយតបលើកឡើងថា អង្គបុរេជំនុំជម្រះបានយល់ឃើញថា អ្នកធ្វើសេចក្តីព្រាង

លេខ២៣ កថាខណ្ឌ១៤៤។ សាលដីការបស់អង្គបុរេជំនុំជម្រះគឺពឹងផ្អែកទៅលើការពិនិត្យឡើងវិញភាគច្រើន ប៉ុន្តែមិនមែនលើប្រភព ដូចគ្នាទាំងអស់នោះទេ ខណៈដែលអង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកទៅលើសំណុំរឿង *ឌុច*។

[៤៧] ឯកសារលេខ **D427/1/17** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់នួន ជា, អៀង សារី និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១០ ឯកសារលេខ ERN 00626531-623 កថាខណ្ឌ១៧២-១៨៥។ និង ឯកសារលេខ **E95** សំណើទាក់ទិននឹងជម្លោះប្រដាប់អាវុធ ដូចជើងទំព័រលេខ១ កថាខណ្ឌ១៤- ២៣។

[៤៨] ឯកសារលេខ **E95/4** ចម្លើយតបទាក់ទិននឹងជម្លោះប្រដាប់អាវុធរបស់លោក អៀង សារី ដូចជើងទំព័រលេខ៩ កថាខណ្ឌ២១-២២ (សំដៅទៅលើ ឯកសារលេខ **D427/1/23** សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹង

ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ បានធានាឱ្យមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធ "ដើម្បីបញ្ចៀសការចោទប្រកាន់ថា ការវិនិច្ឆ័យទោសចេញឆ្ងាយពីអ្វីដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ" និងថា សហព្រះរាជអាជ្ញា "មិនបានយកចិត្តទុកដាក់លើការសម្រេចនេះទេ" [៤៩]។ ចម្លើយតបទាក់ទងនឹងជម្លោះប្រដាប់អាវុធរបស់ អៀង ធីរិទ្ធ បានលើកឡើងថែមទៀតថា នៅក្នុងការអនុវត្តជាក់ស្តែង "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានច្របាច់បញ្ចូលគ្នា" នៅចំពោះមុខតុលាការយោធាអន្តរជាតិ[៥០]។ ចំពោះបញ្ហាដែល អៀង ធីរិទ្ធ ធ្វើការលើកឡើងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនអាចជាប្រភេទបទឧក្រិដ្ឋផ្សេងនៅឆ្នាំ ១៩៤៥ នោះ សហព្រះ-រាជអាជ្ញាសូមឆ្លើយតបថា ការអះអាងនេះគឺគ្មានមូលដ្ឋាន និងមិនត្រូវបានគាំទ្រដោយឯកសារសំអាងផ្លូវច្បាប់ណាមួយឡើយ។

៤៥- ដើម្បីឆ្លើយតបទៅនឹង អៀង សារី សហព្រះរាជអាជ្ញាសូមបំភ្លឺថា ខ្លួនមិនមែន "មិនបានយកចិត្តទុកដាក់" លើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះនោះទេ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាមិនបានពិចារណាឃើញថា ការយល់ឃើញនោះជាការសម្រេចចុងក្រោយពាក់ព័ន្ធនឹងឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលពាក់ព័ន្ធនោះឡើយ។ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា សេចក្តីថ្លែង-ការណ៍របស់អង្គបុរេជំនុំជម្រះធ្វើឡើងផ្អែកលើសេចក្តីថ្លែងការណ៍ ដែលបានធ្វើឡើងនៅក្នុងឯកសាររបស់សាស្ត្រាចារ្យ Cherif Bassiouni *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*[៥១]។ នៅពេលពិនិត្យមើលបរិបទ វាបង្ហាញឱ្យឃើញថា សេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ Bassiouni ស្នើសុំឱ្យមានការពន្យល់ពីអ្វីដែលបណ្តាលឱ្យមានការបញ្ចូលទំនាក់ទំនង

---

បណ្តឹងឧទ្ធរណ៍របស់នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ២០១០ ឯកសារលេខ ERN 00629968-3043 កថាខណ្ឌ៨៧។

[៤៩] ឯកសារលេខ **E95/4** ចម្លើយតបទាក់ទិននឹងជម្លោះប្រដាប់អាវុធរបស់លោក អៀង សារី *ដូចជើងទំព័រ*លេខ៩ កថាខណ្ឌ២១។

[៥០] ឯកសារលេខ **E95/2** ចម្លើយតបទាក់ទិននឹងជម្លោះប្រដាប់អាវុធរបស់លោកស្រី អៀង ធីរិទ្ធ *ដូចជើងទំព័រ*លេខ៨ កថាខណ្ឌ២៧។

[៥១] M. Cherif Bassiouni *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងច្បាប់អន្តរជាតិ* Kluwer Law International (ឆ្នាំ១៩៩៩) នៅទំព័រ ២៣-២៥, ២៩-៣០, ៤៣ (លើកឡើងក្នុង ឯកសារលេខ **D427/2/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់នួន ជា និងអៀង ធីរិទ្ធ ដូចជើងទំព័រលេខ២៣ កថាខណ្ឌ១៣៩ និង ឯកសារលេខ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ដូចជើងទំព័រលេខ ២៣ កថាខណ្ឌ៣០៨)។

ជាមួយជម្លោះប្រដាប់អាវុធ នៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ។ សាស្ត្រាចារ្យ Bassiouni មិនបានធ្វើការសន្និដ្ឋានថា នៅពេលដំណាលគ្នានឹងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធជាចាំបាច់នោះទេ។ ជាការពិត នៅក្នុងឯកសាររបស់គាត់ ក្រោយមកទៀត គាត់បានពណ៌នាអំពីវិធីសាស្ត្រ ដែលបានធ្វើឡើងដោយអ្នកធ្វើសេចក្តីព្រាងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិថាជា "ការប្រុងប្រយ័ត្នជាមុន... ក្នុងការជៀសវាងទឡ្ហីករណ៍ដែលថា [សេចក្តីថ្លែងការណ៍ទាំងនោះ] បានរំលោភលើ 'គោលការណ៍នីត្យានុកូលភាព'"[៥២]។

៤៦- សហព្រះរាជអាជ្ញាយល់ឃើញថា មានការជឿជាក់ជាងទៅលើមតិយោបល់របស់គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់សហរដ្ឋអាមេរិក (UNWCC) ដែលត្រូវបានតាក់តែងឡើងនៅឆ្នាំ ១៩៤៨ ដែលបានលើកឡើងថា ច្បាប់អន្តរជាតិអាចដាក់ទោសបុគ្គលទាំងឡាយចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តឡើង "មិនត្រឹមតែក្នុងអំឡុងពេលសង្គ្រាមប៉ុណ្ណោះទេ តែថែមទាំងនៅក្នុងកាលៈទេសៈមួយចំនួន ក្នុងពេលមានសន្តិភាពផងដែរ" និងថាការបញ្ចូលទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ នៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ "បានកម្រិតវិសាលភាពនៃទស្សនាទាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[៥៣]។

៤៧- ពាក់ព័ន្ធទៅនឹងគោលការណ៍ Nuremberg សហព្រះរាជអាជ្ញាលើកឡើងថា ខ្លួនមិនចម្លែកចិត្តទេ ដែលថា គោលការណ៍ទាំងនេះបានលើកឡើងម្តងទៀតពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមទាំងទំនាក់ទនងជាមួយនឹងជម្លោះប្រដាប់អាវុធ ដូចមានចែងនៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ។ គោលការណ៍ Nuremberg គ្មានចេតនាធ្វើការប្រកាសអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌលក្ខណៈបុគ្គល និងរបស់ចៅហ្វាយនាយចំពោះឧក្រិដ្ឋកម្មអន្តរជាតិ សំខាន់ៗនៅត្រឹមកាលបរិច្ឆេទនៃការអនុម័តគោលការណ៍ទាំងនេះ។ ផ្ទុយទៅវិញ គោល-ការណ៍ទាំងនេះមានចេតនាធ្វើការប្រកាសពីច្បាប់ ដែលបានអនុវត្តដោយតុលាការយោធាអន្តរជាតិ។

[៥២] Bassiouni *ដូចជើងទំព័រខាងលើ* ទំព័រ៨០។

[៥៣] គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមសហប្រជាជាតិ, ប្រវត្តិនៃគណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាម និងការវិវឌ្ឍនៃច្បាប់ស្តីពីសង្គ្រាម (ឆ្នាំ១៩៤៨) នៅទំព័រទី១៩២ -១៩៣។

ចំណុចនេះបង្ហាញច្បាស់លាស់ដោយពាក្យពេចន៍នៃសេចក្តីសម្រេច ១៧៧ (II) របស់មហា សន្និបាត អង្គការសហប្រជាជាតិដែលបានណែនាំគណៈកម្មការច្បាប់អន្តរជាតិ ("ILC") ឲ្យ "រៀបចំគោល-ការណ៍ច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់នៅក្នុងធម្មនុញ្ញរបស់តុលាការ Nuremberg និង សាលក្រមរបស់តុលាការនេះ"[៥៤]។ បទបញ្ញានេះត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់ដោយគណៈកម្មការ ច្បាប់អន្តរជាតិដែលនៅដើមដំបូងនៃការងាររបស់ខ្លួន បានកំណត់ថា ភារកិច្ចរបស់គណៈកម្មការ ច្បាប់អន្តរជាតិ "មិនមែន...ដើម្បីពិនិត្យថាតើគោលការណ៍ទាំងអស់នេះគឺជា ឬមិន មែនជាគោល-ការណ៍ច្បាប់អន្តរជាតិ ឬទេនោះឡើយ...[ប៉ុន្តែ] គ្រាន់តែដើម្បីរៀបចំគោលការណ៍ ទាំងនោះ ប៉ុណ្ណោះ"[៥៥]។ ដូច្នេះគោលការណ៍ Nuremberg មិនអាចយកធ្វើជាសំអាងថា ជាការគាំទ្របន្ថែម សម្រាប់ការលើកឡើងដែលថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ គឺចាំបាច់សម្រាប់ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ ១៩៤៥ នោះឡើយ។

*ii. ការវិវឌ្ឍបន្ទាប់ពីមានធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ បង្ហាញជាចុងក្រោយថា ពុំមានលក្ខខណ្ឌកំណត់អំពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធត្រឹមឆ្នាំ ១៩៧៥ នោះទេ*

៤៨- នៅក្នុងសំណើទាក់ទងនឹងជម្លោះប្រដាប់អាវុធ សហព្រះរាជអាជ្ញាលើកឡើងថា ការវិវឌ្ឍសំខាន់ៗនៅ កម្រិតអន្តរជាតិ និងកម្រិតជាតិបន្ទាប់ពីធម្មនុញ្ញតុលាការយោធាអន្តរជាតិ បង្ហាញជាចុងក្រោយថា ពុំមានទំនាក់ទនងជាមួយនឹងជម្លោះប្រដាប់អាវុធសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ ត្រឹមឆ្នាំ ១៩៧៥[៥៦]។ ចម្លើយតបរបស់មេធាវីការពារក្តីបដិសេធទឡ្ហីករណ៍នេះ និងបន្តអះអាងថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅតែចាំបាច់នៅក្នុងអំឡុងពេលយុត្តាធិការក្នុងពេលវេលា របស់ អ.វ.ត.ក។

៤៩- ទាំងចម្លើយតបរបស់ ខៀវ សំផន ទាំងចម្លើយតបរបស់ អៀង សារី លើកឡើងថា ទំនាក់ទំនង ជាមួយនឹងជម្លោះប្រដាប់អាវុធអាចនឹងមិនតឹងរ៉ឹងនោះទេ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ រហូត

[៥៤] សេចក្តីសម្រេចរបស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិលេខ ១១៧ (II), អនុម័តនៅថ្ងៃទី ២១ វិច្ឆិកា ១៩៤៧។

[៥៥] សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ: ឆ្នាំ១៩៥០ លេខទី II (A/CN.4/22) កថាខណ្ឌ៣៦។

[៥៦] ឯកសារលេខ E95 សំណើទាក់ទិននឹងជម្លោះប្រដាប់អាវុធ ដូចជើងទំព័រលេខ១ កថាខណ្ឌ២០-២៣។

ដល់ក្រោយពេលអនុម័តច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ដើម្បីគាំទ្រដល់ទឡ្ហីករណ៍នេះ ចម្លើយតបទាំងនេះបានយោងលើកំណត់ហេតុមួយចំនួនពាក់ព័ន្ធនឹងការចរចាអំពីច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលបង្ហាញថា បញ្ហានៃទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ គឺជាប្រធានបទនៃកិច្ចពិភាក្សាមួយចំនួន[៥៧]។ នៅក្នុងសារណាតប សហព្រះរាជអាជ្ញាលើកឡើងថា អង្គហេតុដែលថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធត្រូវបានពិភាក្សា នៅក្នុងពេលចរចារអំពីច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងថាគណៈប្រតិភូមួយចំនួនអាចបង្ហាញពីទស្សនៈខុសៗគ្នានោះ មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការធ្វើឲ្យមានបញ្ហាអំពីឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិលើបញ្ហានេះទេ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិផ្អែកលើភាពស៊ីសង្វាក់គ្នាជាជាងផ្អែកលើភាពដូចគ្នាដាច់ខាត នៃការអនុវត្តជាក់ស្តែងរបស់រដ្ឋសម្រាប់ការអភិវឌ្ឍរបស់ខ្លួន។ អំណះអំណាងរបស់មេធាវីការពារក្តីក៏ផ្ទុយទៅនឹងច្បាប់យុត្តិសាស្ត្រ របស់អង្គជំនុំជម្រះសាលាដំបូង និងរបស់តុលាការ ICTY ផងដែរ ដែលតុលាការទាំងពីរនេះ បានសន្និដ្ឋានថា នៅពេលដែលលក្ខខណ្ឌកំណត់អំពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធកាលពីមុនមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមានលក្ខណៈតឹងរ៉ឹងណាស់ មុនពេលអនុម័តច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ[៥៨]។

---

[៥៧] ឯកសារលេខ **E95/3** KHIEU ចម្លើបតបរបស់លោក ខៀវ សំផន ទាក់ទិននឹងជម្លោះប្រដាប់អាវុធ ដូចជើងទំព័រលេខ១០ កថាខណ្ឌ២១-២២។ ឯកសារលេខ **E95/4** ចម្លើបតបរបស់លោក អៀង សារី ទាក់ទិននឹងជម្លោះប្រដាប់អាវុធ ដូចជើងទំព័រលេខ៩ កថាខណ្ឌ៤៦។

[៥៨] ឯកសារលេខ **E188** សាលក្រម *ឌុច ដូចជើងទំព័រ*លេខ២១ កថាខណ្ឌ២៩២ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* ដូចជើងទំព័រលេខ៤០ កថាខណ្ឌ១៤០។ អង្គបុរេជំនុំជម្រះក៏បានឲ្យយោបល់ថា ទំនាក់ទំនងជម្លោះប្រដាប់អាវុធអាចមិនត្រូវបានតម្រូវឲ្យមានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅមុនលក្ខន្តិកៈតុលាការ ICC។ *សូមមើល* ឯកសារលេខ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ដូចជើងទំព័រលេខ២៣ កថាខណ្ឌ៣១០ (ដោយសារមិនមានទម្លាប់អនុវត្តរបស់រដ្ឋច្បាស់លាស់ និង*សច្ចធារណ៍ធម្មានុរូប* នៅចន្លោះពីឆ្នាំ១៩០៨ រហូតដល់ឆ្នាំ១៩៨៤) និង ឯកសារលេខ **D427/2/15,** សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយនួន ជា និងអៀង ធីរិទ្ធ ដូចជើងទំព័រលេខ២៣ កថាខណ្ឌ១៣៧(ដោយថែងអំពីរឿងក្តី Tadić របស់តុលាការ ICTY និងថែងថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ "អាច"មិនតម្រូវទំនាក់ទំនងត្រឹមឆ្នាំ១៩៩៥)។ ប៉ុន្តែ សូមមើល សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ *ដូចជើងទំព័រ* លេខ២៣ កថាខណ្ឌ ១៤៣ (ដែលចែងថា "*ការខ្វែងយោបល់គ្នាទៅលើលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធនៅមានរហូតដល់មានសន្និសីទដើម្បីបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ*")។

៥០- ចម្លើយតបរបស់មេធាវីការពារក្តី ក៏បានជំទាស់នឹងឯកសារសំអាងផ្លូវច្បាប់ស្តីពីប្រភពផ្ទាល់ខ្លួន មួយចំនួនដែលសហព្រះរាជអាជ្ញាបានយកធ្វើជាសំអាងនៅក្នុងសំណើទាក់ទងនឹងជម្លោះប្រដាប់អាវុធ នៅក្នុងការកំណត់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានជាធរមាន នៅឆ្នាំ ១៩៧៥ ផងដែរ។

## <u>ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ</u>

៥១- អៀង ធីរិទ្ធ និង អៀង សារី ជំទាស់ទៅនឹងការសំអាងរបស់សហព្រះរាជអាជ្ញាលើច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ("CCL 10") [៥៩] និងច្បាប់យុត្តិសាស្ត្របន្ទាប់មកទៀតរបស់តុលាការយោធាដែលបានបង្កើតឡើងក្រោមច្បាប់នេះ។

៥២- ដោយបានដកស្រង់អត្ថបទមួយរបស់ Egon Schwelb អៀង ធីរិទ្ធ លើកឡើងថា ការមិនបញ្ចូលពាក្យថា "*មុនពេល ឬក្នុងអំឡុងពេលសង្គ្រាម*" ជាក់ស្តែងពុំមានសារៈសំខាន់នោះទេ ពីព្រោះបទបញ្ញត្តិផ្សេងទៀតនៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យចែងច្បាស់ថា ច្បាប់នេះអនុវត្តចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងទាំងមុនពេល និងក្នុងអំឡុងពេលសង្គ្រាម។ ចំពោះសេចក្តីនៃអត្ថបទនេះ ការសំអាងរបស់ អៀង ធីរិទ្ធ លើផ្នែកនេះនៃអត្ថបទរបស់ Schwelb ហាក់ បីដូចជាលើកឡើងខុសកន្លែង និងមិនបង្ហាញពីទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលថា ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យមិនបញ្ចូលទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។ ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាមិនរិះគន់ លើការមិនបញ្ចូលពាក្យថា "*មុនពេល ឬក្នុងអំឡុងពេលសង្គ្រាម*" នោះទេ ប៉ុន្តែរិះគន់លើការ មិនបញ្ចូលទៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យនូវទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មផ្សេងទៀតដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការយោធាអន្តរជាតិ ដែលជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព។ លើសពីនេះទៀត ដូចដែលបានកត់សម្គាល់នៅក្នុងសំណើទាក់ទងនឹងជម្លោះប្រដាប់អាវុធ

---

[៥៩] ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ស្តីពីការដាក់ទណ្ឌកម្មទៅលើពិរុទ្ធជនពីបទឧក្រិដ្ឋកម្មសង្គ្រាម បទឧក្រិដ្ឋប្រឆាំងនឹងសន្តិភាព និងមនុស្សជាតិ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ មាត្រា II(១)( គ) *បោះពុម្ពឡើងវិញក្នុង ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា* Nuremberg *ក្រោមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ (លេខទី១) ទំព័រ១៦-១៧* ("CCL 10")។

Schwelb បានអះអាងនៅត្រង់កន្លែងផ្សេងទៀតថា ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យមិនរួមបញ្ចូលទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនោះទេ[៦០]។

៥៣- អៀង សារី ជំទាស់ទៅនឹងការសំអាងរបស់សហព្រះរាជអាជ្ញាលើសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយតុលាការយោធាសហរដ្ឋអាមេរិកនៅក្នុងរឿងក្តី *Einsatzgruppen* និងរឿងក្តី *Justice* ដោយលើកឡើងថា សេចក្តីថ្លែងការណ៍ទាំងអស់នេះ *គឺជាមតិយោបល់ដែលមិនទាក់ទងនឹងបញ្ហាចោទ*[៦១] *(obiter )*។ អៀង សារី អះអាងថា រឿងក្តី *Flick* ដែលក្នុងនោះតុលាការបានបដិសេធទឡ្ហីករណ៍ដែលថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធមិនមែនជាការចាំបាច់ទេនៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យនោះ គួរតែត្រូវបានធ្វើការពិចារណាថាយកជាការបានជាងរឿងក្តី *Einsatzgruppen* និងរឿងក្តី *Justice* ពីព្រោះបញ្ហានេះមានលក្ខណៈដាច់ខាតចំពោះសំអាងហេតុនៃសេចក្តីសម្រេចពីមុន (*ratio decidendi*)។ អៀង សារី ក៏បានអះអាងផងដែរថា តុលាការដែលបានបង្កើតឡើងក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យគួរត្រូវបានពិចារណាឃើញថាប្រើប្រាស់ច្បាប់ជាតិ ជាជាងប្រើប្រាស់ច្បាប់អន្តរជាតិ។

៥៤- សហព្រះរាជអាជ្ញាមិនជំទាស់ទេថា សេចក្តីថ្លែងការណ៍នៅក្នុងរឿងក្តី *Einsatzgruppen* និងរឿងក្តី *Justice* គឺជា*មតិយោបល់ដែលមិនទាក់ទងនឹងបញ្ហាចោទ* (*obiter dicta*) ឬថា ការដែលគ្មានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ មានលក្ខណៈដាច់ខាតចំពោះការលើកលែងការចោទប្រកាន់នៅក្នុងរឿងក្តី *Flick* ។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចនេះមិនបន្ថយនូវសារៈសំខាន់នៃសេចក្តីថ្លែងការណ៍នានាដែលបានធ្វើឡើងនៅក្នុងរឿងក្តី *Einsatzgruppen* និងរឿងក្តី *Justice* ថាជាការបកស្រាយដែលយកជាការបាននៃឯកសារបង្កើតឡើងផ្ទាល់របស់តុលាការ។ តុលាការលើកឡើងយ៉ាងច្បាស់លាស់នៅក្នុងរឿងក្តី *Einsatzgruppen* និងបញ្ជាក់នៅក្នុងរឿងក្តី *Justice* ថាពុំចាំបាច់មានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

[៦០] ឯកសារលេខ **E95** សំណើទាក់ទិននឹងជម្លោះប្រដាប់អាវុធ ដូចជើងទំព័រលេខ១ កថាខណ្ឌ២០ (លើកឡើងអំពីសេចក្តីថ្លែងការណ៍របស់ Egon Schwelb ករណីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុង 23 British Yearbook of International Law 178 (ឆ្នាំ១៩៤៦) នៅទំព័រ២១៨ថា "*យុត្តិសាស្ត្រទាំងស្រុងបានវិវឌ្ឍក្នុងដំណើរការនីតិវិធីតុលាការ* Nuremberg *ជាមួយនឹងទស្សនៈមួយក្នុងការដាក់កម្រិតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះអ្នកដែលពាក់ព័ន្ធនឹងសង្គ្រាម បែរទៅជាមិនពាក់ព័ន្ធនៅតុលាការដែលដោះស្រាយ ឬនឹងដោះស្រាយរឿងក្តីពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [ក្រោមច្បាប់ CCL 10]*")។

[៦១] ឯកសារលេខ **E95/4** ចម្លើយតបរបស់ អៀង សារី ទាក់ទិននឹងជម្លោះប្រដាប់អាវុធ *ដូចជើងទំព័រលេខ៩* កថាខណ្ឌ២៣។

នោះទេ។ អង្គជំនុំជម្រះសាលាដំបូងអាចគិតអំពីរឿងក្តីទាំងអស់នេះយ៉ាងត្រឹមត្រូវនៅក្នុងការវាយតម្លៃរបស់ខ្លួន។

៥៥- ពាក់ព័ន្ធទៅនឹងច្បាប់ដែលបានអនុវត្តដោយតុលាការបង្កើតឡើងតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ សហព្រះរាជអាជ្ញាយោងលើទឡ្ហីករណ៍កាលពីមុនរបស់ខ្លួនស្តីពីចំណុចនេះ និងនៅតែរក្សាការអះអាងថា ច្បាប់ដែលបានអនុវត្តគឺជាច្បាប់អន្តរជាតិ[៦២]។ សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ផងដែរថា នៅក្នុងរឿងក្តី *Flick* តុលាការបានហៅខ្លួនឯងថាជា "តុលាការអន្តរជាតិ" ដែល "ប្រើប្រាស់ច្បាប់អន្តរជាតិ"[៦៣]។

<u>សេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ</u>

៥៦- អៀង សារី អះអាងថា សហព្រះរាជអាជ្ញា "មិនបានយកចិត្តទុកដាក់" លើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះថា សេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ ("សេចក្តីព្រាងក្រម") មិនត្រូវបានមហាសន្និបាត អ.ស.ប ទទួលស្គាល់ឡើយ[៦៤]។

៥៧- សហព្រះរាជអាជ្ញាសូមបញ្ជាក់ថា សហព្រះរាជអាជ្ញាបានពិចារណាលើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញានៅតែសូមសន្និដ្ឋានថា ទោះបីជាពុំទទួលស្គាល់ក៏ដោយ ក៏សេចក្តីព្រាងក្រមនេះផ្តល់ជាភស្តុតាងដ៏មានតម្លៃនៃទស្សនៈ ដែលត្រូវបានពិចារណាជាសមូហភាពរបស់អ្នកនិពន្ធដ៏មានគុណវុឌ្ឍិ លើការអនុវត្តរបស់រដ្ឋ និងសច្ចធារណ៍ធម្មនុរូប ពាក់ព័ន្ធនឹងបញ្ហាទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ។ កំណត់ហេតុរបស់ អ.ស.ប បង្ហាញច្បាស់ថា ហេតុផលដែលសេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ពុំត្រូវបានអនុម័តនោះ ពុំទាក់ទងនឹងអវត្តមាននៃទំនាក់ទំនង

---

[៦២] ឯកសារលេខ **E95** សំណើទាក់ទិននឹងជម្លោះប្រដាប់អាវុធ *ដូចជើងទំព័រ*លេខ១ កថាខណ្ឌ២១។

[៦៣] សហរដ្ឋអាមេរិក *តទល់នឹង Flick*, រឿងក្តីលេខ៤៨ ថ្ងៃទី២០ ខែមេសា ដល់ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៤៧ ក្នុងរបាយការណ៍ច្បាប់នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម ច្បាប់ XII (UNWCC ឆ្នាំ១៩៤៩) ទំព័រ១៤។

[៦៤] E95/4 ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងជម្លោះប្រដាប់អាវុធ *ដូចខាងលើ* កំណត់សម្គាល់លេខ ៩ កថាខណ្ឌ ២៧។

ជាមួយនឹងជម្លោះប្រដាប់អាវុធចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ក៏ប៉ុន្តែ វាពាក់ព័ន្ធនឹងនិយមន័យនៃការឈ្លានពានទៅវិញទេ[៦៥]។

៥៨- ម្យ៉ាងវិញទៀត ទោះបីជាពុំដែលធ្លាប់ត្រូវបានអនុម័តក៏ដោយ ក៏សេចក្តីព្រាងក្រមនេះ ជាធម្មតា ត្រូវបានគេយកមកធ្វើជាប្រភពដ៏សំខាន់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ រួមទាំង ច្បាប់ទំនៀមទម្លាប់ពាក់ព័ន្ធនឹងទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ឧទាហរណ៍ យោងតាមរបាយការណ៍ឆ្នាំ ១៩៨៩ លើការបង្កើតសេចក្តីព្រាងក្រមមួយច្បាប់ទៀតស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ អ្នករាយការណ៍ពិសេសនៃគណៈកម្មការនីតិកម្មអន្តរជាតិបានយកសេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ (បន្ថែមលើអនុសញ្ញាប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍) មកធ្វើជាមូលដ្ឋានគាំទ្រលើការអះអាងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំទាមទារលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ។ គណៈកម្មការនីតិកម្មអន្តរជាតិបានលើកឡើងថា៖

> *ទស្សនទាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានគេចាត់ទុកជាបណ្តើរៗថាជាទស្សនទានស្វយ័ត ហើយក្នុងពេលបច្ចុប្បន្ន មានលក្ខណៈដាច់ដោយឡែកពីទស្សនទាននៃឧក្រិដ្ឋកម្មសង្គ្រាម។ ហេតុដូច្នេះ ទាំងសេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ទាំងអនុសញ្ញា (ស្តីពីអំពើប្រល័យពូជសាសន៍ និងការប្រកាន់ពូជសាសន៍) ដែលបានចូលជាធរមាន ពុំភ្ជាប់ទស្សនទាននោះទៅនឹងស្ថានភាពសង្គ្រាមទៀតឡើយ*[៦៦]។

៥៩- សហព្រះរាជអាជ្ញានៅតែសូមសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងទំនងជាអាចធ្វើការវិភាគយ៉ាងសមស្របលើសេចក្តីព្រាងក្រមនេះ។

**<u>អនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍</u>**

[៦៥] មហាសន្និបាត សម័យប្រជុំលើកទី ៩ កិច្ចប្រជុំពេញអង្គលើកទី ៥០៤ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៥៤ កថាខណ្ឌ ៨៩៧។

[៦៦] សៀវភៅប្រចាំឆ្នាំ ១៩៨៩ នៃគណៈកម្មការនីតិកម្មអន្តរជាតិ Volume II ផ្នែកទី ១ ទំព័រទី ៨៦ កថាខណ្ឌ ៣៨។

៦០- ទាំង ខៀវ សំផន ទាំង អៀង សារី បានតវ៉ាចំពោះការសំអាងរបស់សហព្រះរាជអាជ្ញាលើអនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍។ ខៀវ សំផន បានអះអាងថា គណៈកម្មការនីតិកម្មអន្តរជាតិ "បានបកស្រាយនៅក្នុងឆ្នាំ ១៩៩៣ ថា មានតែឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍អាប៉ាថេត និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់អន្តរជាតិ"។ ដោយសារមូលហេតុនេះហើយទើប "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងពីរនេះបង្កើតបានជាឧក្រិដ្ឋកម្មអន្តរជាតិ ហើយពុំមែនឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយអាចត្រូវបានប្រព្រឹត្តនៅក្នុងសម័យកាលសន្តិភាពនោះទេ"[៦៧]។

៦១- ទឡ្ហីករណ៍នេះ គឺជាការភ័ន្តច្រឡំ និងមិនត្រឹមត្រូវទាល់តែសោះ។ ផ្ទុយពីការអះអាងរបស់ ខៀវ សំផន គណៈកម្មការនីតិកម្មអន្តរជាតិពុំបាន (ហើយក៏ពុំធ្លាប់បាន) បកស្រាយនៅក្នុងឆ្នាំ ១៩៩៣ ថា "មានតែឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍អាប៉ាថេត និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្របតាមច្បាប់អន្តរជាតិ"។ ខៀវ សំផន ផ្អែកការអះអាងនេះលើសេចក្តីព្រាងការងារបឋមនៃលក្ខន្តិកៈរបស់តុលាការ ICC ដែលត្រូវបានក្រុមការងាររបស់គណៈកម្មការនីតិកម្មរៀបចំឡើងនៅចន្លោះខែ ឧសភា និង ខែ កក្កដា ឆ្នាំ ១៩៩៣។ នៅក្នុងចំណោមបទល្មើសនានា សេចក្តីព្រាងនេះរួមបញ្ចូលអំពើប្រល័យពូជសាសន៍ (ដូចបានកំណត់ដោយអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍) និងការប្រកាន់ពូជសាសន៍ (ដូចបានកំណត់ដោយអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍) ថាជាបទល្មើសនៅក្រោមយុត្តាធិការនៃតុលាការនាពេលអនាគត។ ដូចអត្ថាធិប្បាយរបស់ក្រុមការងារបានបញ្ជាក់ច្បាស់ហើយ សេចក្តីព្រាងបានរួមបញ្ចូលតែបទល្មើសទាំងឡាយណា ដែលកំណត់ដោយសន្ធិសញ្ញា និងដែលសន្ធិសញ្ញាបានចែងអំពីយន្តការអនុវត្តន៍តែប៉ុណ្ណោះ[៦៨]។ សេចក្តីព្រាង និងអត្ថាធិប្បាយរបស់ក្រុមការងារនៃគណៈកម្មការនីតិកម្មអន្តរជាតិមិនអាចនាំឲ្យមានការសន្និដ្ឋានថា មានតែអំពើប្រល័យពូជសាសន៍ និងការប្រកាន់ពូជសាសន៍តែ

---

[៦៧] E95/3 ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងជម្លោះប្រដាប់អាវុធ *ដូចខាងលើ* កំណត់សម្គាល់លេខ ១០ កថាខណ្ឌ ២២។

[៦៨] របាយការណ៍ដែលត្រូវបានកែប្រែនៃក្រុមការងារលើសេចក្តីព្រាងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានបោះពុម្ពសារជាថ្មីនៅក្នុងឯកសារ A/48/10 ឧបសម្ព័ន្ធ ទំព័រទី ១០៧ (ដកស្រង់នៅក្នុង E95/3 ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងជម្លោះប្រដាប់អាវុធ *ដូចខាងលើ* កំណត់សម្គាល់លេខ ១០ កថាខណ្ឌ ២២)។

ប៉ុណ្ណោះទេ ដែលបានបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

៦២- ការជំទាស់របស់ អៀង សារី គឺបានផ្អែកលើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះថា អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ "ពិតជាបានងាកចេញយ៉ាងច្បាស់លាស់ពីនិយមន័យដើមរបស់វា ដែលមានចែងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយតម្រូវឲ្យមាន "ចេតនាជាក់លាក់" ហើយអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ "មកត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មានប្រទេសត្រឹមតែ ២៥ ប៉ុណ្ណោះ ដែលបានចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬ ចូលជាភាគី និងមានប្រទេសចំនួន ៣២ បន្ថែមទៀត ដែលបានចុះហត្ថលេខាក្នុងអំឡុងពេលយុត្តាធិការពេលវេលា របស់ អ.វ.ត.ក..."[៦៩]។

៦៣- សហព្រះរាជអាជ្ញាសូមសន្និដ្ឋានជូនអង្គបុរេជំនុំជម្រះដោយគោរពថា ការយល់ឃើញទាំងនេះគ្មានអ្វីគួរឲ្យជឿជាក់ឡើយ។ ទាំងអង្គបុរេជំនុំជម្រះ ទាំង អៀង សារី ពុំបានពន្យល់គ្រប់គ្រាន់អំពីហេតុផលថាហេតុអ្វីការបញ្ចូលធាតុចេតនាពិសេស បន្ថែមទៅក្នុងនិយមន័យនៃអំពើប្រល័យពូជសាសន៍នៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មានន័យថា អំពើប្រល័យពូជសាសន៍ ពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៀតឡើយ។ ទោះបីជាមានរដ្ឋមួយចំនួនតិចចូលជាភាគីនៃអនុសញ្ញាក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ក៏ដោយ ពោលគឺ ដើម្បីគោលបំណងនៃការកំណត់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក៏ចំនួនរដ្ឋដែលបានចូលជាភាគីនៃអនុសញ្ញា នៅក្នុងពេលណាក៏ដោយ គឺមិនមែន ឬពុំជាកត្តាសំខាន់បំផុតតែមួយគត់នោះទេ។ ការអនុវត្តរបស់រដ្ឋនៅក្នុងអំឡុងពេលចរចា ក្នុងអំឡុងពេលបោះឆ្នោតអនុម័តដោយមហាសន្និបាត និងហេតុផលនៃការបោះឆ្នោតត្រូវយកមកពិចារណាទាំងអស់។

**<u>អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីអាជ្ញាយុកាល</u>**

[៦៩] D427/1/30 សាលដីកាលើបណ្តឹងឧទរណ៍របស់ អៀង សារី *ដូចខាងលើ* កំណត់សម្គាល់លេខ ២៣ កថាខណ្ឌ ៣០៩។ D427/2/12 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ *ដូចខាងលើ* កំណត់សម្គាល់លេខ ២៣ កថាខណ្ឌ ១៤២។

៦៤- ដោយផ្អែកលើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ អៀង សារី បានលើកឡើងថា អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីអាជ្ញាយុកាល[៧០] ពុំមែនជាភស្តុតាងបញ្ជាក់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ដោយហេតុថាអនុសញ្ញានេះមានរដ្ឋសមាជិក អ.ស.ប ចំនួនត្រឹមតែ ១៨ប្រទេសប៉ុណ្ណោះ ដែលបានផ្តល់សច្ចាប័ន ក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[៧១]។ សហព្រះរាជអាជ្ញានៅតែសូមលើកឡើងដដែលៗថា ចំនួនរដ្ឋភាគី ដែលចូលជាភាគីអនុសញ្ញាក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ពុំប៉ះពាល់ដល់តម្លៃនៃអនុសញ្ញានេះ ដែលជាប្រភពសំខាន់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ ជាពិសេស ជាការចាំបាច់ដើម្បីកត់សម្គាល់ថា គ្មានការលើកឡើងណាមួយថា កង្វះនៃការគាំទ្រចំពោះអនុសញ្ញានេះ ត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់គោលបំណងស្តីពីអត្ថិភាពនៃទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនោះទេ។ ជាការពិត កំណត់ហេតុនៃការចរចា និងការអនុម័តអាចទំនងបង្ហាញថា ការជំទាស់ជាចំបងគឺថា អនុសញ្ញានេះពុំមែនជាយន្តការសមស្របមួយ ក្នុងការពង្រីកប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ជាជាងលុបចោលនូវលក្ខខណ្ឌនៃទំនាក់ទំនងនេះ[៧២]។

## យុត្តិសាស្ត្រ និងច្បាប់ក្នុងស្រុក

៦៥- អៀង សារី បានកត់សម្គាល់លើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះថា "មានឧទាហរណ៍មួយចំនួនតូចនៅក្នុងច្បាប់ជាតិ ដែលកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំចាំបាច់មានលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនេះ" ហើយបានបន្តលើកឡើងទៀតថា ឧទាហរណ៍ "តែមួយគត់" ក្រៅពីប្រទេសអាល្លឺម៉ង់តាមរយៈច្បាប់លេខ ១០ គឺច្បាប់ឆ្នាំ ១៩៥០ ស្តីពី (ការផ្តន្ទាទោស)

[៧០] អនុសញ្ញាស្តីពីភាពមិនអាចអនុវត្តទៅបាននៃអាជ្ញាយុកាលលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧបសម្ព័ន្ធភ្ជាប់ទៅនឹងសេចក្តីសម្រេចរបស់មហាសន្និបាត ២៣៩១ (XXIII) ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៦៨ មាត្រា I(ខ)។

[៧១] E95/4 ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងជម្លោះប្រដាប់អាវុធ *ដូចខាងលើ* កំណត់សម្គាល់លេខ ៩ កថាខណ្ឌ ២៨( ដកស្រង់នៅក្នុង D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី *ដូចខាងលើ* កំណត់សម្គាល់លេខ ២៣ កថាខណ្ឌ ៣០៩។

[៧២] Robert H. Miller អនុសញ្ញាស្តីពីភាពមិនអាចអនុវត្តទៅបាននៃអាជ្ញាយុកាលលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទនានុប្បវត្តិអាមេរិកលេខ ៦៥ នៃនីតិអន្តរជាតិ ៤៧៦, ៤៩១ (១៩៧១)។

របបណាស៊ីអ៊ីស្រាអែល និងសហការីទាំងឡាយនៃរបបណាស៊ី[៧៣]។ ទោះបីជាសហព្រះរាជអាជ្ញាពុំតវ៉ាថា មានច្បាប់ក្នុងស្រុកមួយចំនួនតូចប៉ុណ្ណោះ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏ការលើកឡើងរបស់ អៀង សារី គឺពុំត្រឹមត្រូវឡើយ។ ដូចបានកត់សម្គាល់នៅក្នុងសំណើទាក់ទងនឹងជម្លោះប្រដាប់អាវុធ *ក្រមបទល្មើសអន្តរជាតិ (សាលាក្តី)* ឆ្នាំ ១៩៧៣ របស់ប្រទេសបង់ក្លាដេស បានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំបានយោងលើធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ ឬ ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ[៧៤]។

៦៦- ម៉្យាងវិញទៀត វាជាការមិនត្រឹមត្រូវនៅពេលសន្និដ្ឋានពីភាពកម្រនៃច្បាប់ក្នុងស្រុក ក្នុងការកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ថា និយមន័យបែបនេះមិនមានការគាំទ្រពីរដ្ឋ។ ជាការពិត មុនឆ្នាំ ១៩៧៥ មានរដ្ឋមួយចំនួនតូចតែប៉ុណ្ណោះ បានអនុម័តច្បាប់ក្នុងស្រុករបស់ខ្លួនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ករណីនេះមិនប៉ះពាល់ដល់អត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ហើយ វាក៏ពុំរារាំងតុលាការក្នុងស្រុក មិនឲ្យផ្អែកលើច្បាប់ទំនៀមទម្លាប់ព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងការអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ។ ទោះបីជាយ៉ាងណាក្តី ដូចមតិភាគច្រើននៃអយ្យការក្នុងស្រុកនានា ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងសតវត្សរ៍ទី២០ គឺទាក់ទងនឹងការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មនានាក្នុងសង្គ្រាមលោកលើកទី២ ដែលបញ្ហាចោទថាតើភាពទាក់ទងគ្នាជាមួយជម្លោះប្រដាប់អាវុធ គឺ ជាលក្ខខណ្ឌធម្មតាមួយនៅក្រោមច្បាប់ទំនៀមទំលាប់អន្តរជាតិ មិនបានកើតឡើងក្នុងករណីទាំងនេះទេ។

## <u>ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង</u>

---

[៧៣] E95/4 ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងជម្លោះប្រដាប់អាវុធ *ដូចខាងលើ* កំណត់សម្គាល់លេខ ៩ កថាខណ្ឌ ២៩ (ដកស្រង់នៅក្នុង D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី *ដូចខាងលើ* កំណត់សម្គាល់លេខ ២៣ កថាខណ្ឌ ៣០៩។

[៧៤] ច្បាប់លេខ XIX ក្នុងឆ្នាំ ១៩៧៣ ("ច្បាប់ឆ្នាំ ១៩៧៣ ស្តីពីឧក្រិដ្ឋកម្មអន្តរជាតិ (សាលាក្តី))"។ សូមមើល E95 សំណើទាក់ទងនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ១ កថាខណ្ឌ ២៣ កំណត់សម្គាល់លេខ ៤២។

៦៧- សហព្រះរាជអាជ្ញាសង្កេតឃើញថា ទាំងសារណាតបរបស់ក្រុមមេធាវីការពារក្តី ទាំងការពិភាក្សាមុនៗរបស់អង្គបុរេជំនុំជម្រះ ពុំបានពិចារណាលើឋានៈនៃកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក នៅក្នុងការវិភាគរបស់ខ្លួនលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលពាក់ព័ន្ធនោះទេ។

៦៨- យុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក បានចែងជាដំបូងនៅក្នុងកិច្ចព្រមព្រៀង ដែលជាសន្ធិសញ្ញាចងកាតព្វកិច្ចរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា អំពី"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចបានកំណត់នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ ១៩៩៨ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ" ។ លក្ខន្តិកៈទីក្រុងរ៉ូមគឺជាមូលដ្ឋានរួមសម្រាប់ភាគី ដែលថាលក្ខន្តិកៈនេះពុំបានបញ្ចូលទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ខប្បញ្ញត្តិនៃកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងយុត្តាធិការលើរឿងក្តី បានផ្អែកមួយផ្នែកធំលើការងាររបស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជាដែលត្រូវបានតែងតាំងឡើង ស្របតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥ ដោយបានសន្និដ្ឋានថា "ចំណងពាក់ព័ន្ធរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធហាក់ដូចជាត្រូវបានកាត់ផ្តាច់មកត្រឹមឆ្នាំ ១៩៧៥"[៧៥]។ កិច្ចព្រមព្រៀងត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងខែ ឧសភា ឆ្នាំ ២០០៣ ហើយបានចុះហត្ថលេខាដោយភាគីទាំងសងខាងនៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣[៧៦]។ ច្បាប់ អ.វ.ត.ក ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅក្នុងឆ្នាំ ២០០១ និងធ្វើវិសោធនកម្មនៅក្នុងឆ្នាំ ២០០៤ ដើម្បីផ្តល់អានុភាពដល់កិច្ចព្រមព្រៀងនោះ បានដកលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធចេញពីក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៦៩- ជាការពិត របាយការណ៍របស់ក្រុមអ្នកជំនាញ អត្ថបទកិច្ចព្រមព្រៀង និងអត្ថបទច្បាប់ អ.វ.ត.ក ពុំមែនជាលិខិតុបករណ៍ជាក់លាក់ ដូចច្បាប់ធរមាននៅក្នុងអំឡុងពេលដែលពាក់ព័ន្ធឡើយ ហើយវាចងកាតព្វកិច្ចឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចដោយខ្លួនឯងថា បទល្មើសអន្តរជាតិដែលខ្លួនមានយុត្តាធិការ ជាការពិត បង្កើតជាបទល្មើសក្រោមច្បាប់អន្តរជាតិនៅពេលនោះ។ ទោះបីជាយ៉ាងនេះក្តី

[៧៥] D366/7.1.156 របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលត្រូវបានបង្កើតឡើងស្របតាមសេចក្តីសម្រេចរបស់មហាសន្និបាត 52/135 ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ERN 00078333-428 កថាខណ្ឌ ៧១។

[៧៦] សេចក្តីសម្រេចរបស់មហាសន្និបាត 57/228B អនុម័តនៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៣ (ដោយមិនមានការបោះឆ្នោត)។

ឯកសារ និងលិខិតុបករណ៍ទាំងនេះ ផ្តល់ជាភស្តុតាងយ៉ាងពាក់ព័ន្ធអំពីការយល់ឃើញបច្ចុប្បន្នរបស់រដ្ឋសមាជិកអង្គការសហប្រជាជាតិ រួមទាំងប្រទេសកម្ពុជាផងដែរ និងរបស់អ្នកស្រាវជ្រាវដែលបានផ្តោតការសិក្សាស្រាវជ្រាវរបស់ខ្លួនលើបញ្ហានៃលក្ខខណ្ឌជាមួយនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ។

## *V. ការផ្អែកលើគោលការណ៍ វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ* (Favor rei) *មិនមែនជាលក្ខខណ្ឌតម្រូវឡើយ នៅក្នុងកាលៈទេសៈបច្ចុប្បន្ន*

៧០- ចម្លើយតបរបស់ក្រុមមេធាវីការពារក្តីបានតវ៉ាលើការអះអាងរបស់សហព្រះរាជអាជ្ញាថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអាចផ្តល់ជាយុត្តិកម្មចំពោះការដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ[៧៧]។ សហព្រះរាជអាជ្ញាសូមបញ្ជាក់ថា នៅពេលយកមកប្រើប្រាស់ក្នុងន័យផ្លូវការ គោលការណ៍ *វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ* អនុវត្តចំពោះតែវិមតិសង្ស័យទាំងឡាយណា ដែលកើតចេញពីការវិភាគលើការវាយតម្លៃភស្តុតាងតែប៉ុណ្ណោះ[៧៨]។ សហព្រះរាជអាជ្ញាសូមបញ្ជាក់បំភ្លឺថា ទោះបីជាទទួលស្គាល់ថាគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តក្នុងលក្ខណៈទូលាយជាងនេះ ចំពោះវិមតិសង្ស័យលើអង្គច្បាប់ក៏ដោយ ក៏ជំហររបស់សហព្រះរាជអាជ្ញាគឺថា កាលៈទេសៈបច្ចុប្បន្នពុំទាមទារឲ្យអនុវត្តដូច្នេះឡើយ។ ដូចបានលើកឡើងនៅក្នុងផ្នែកមុនៗរួចមកហើយ ច្បាប់ទំនៀមទម្លាប់អន្តរជាតិគឺមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ មិនមែនជាលក្ខខណ្ឌតម្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនោះឡើយ។ ដោយសារពុំមានវិមតិសង្ស័យបង្ហាញ

[៧៧] E95/2 ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងជម្លោះប្រដាប់អាវុធ *ដូចខាងលើ* កំណត់សម្គាល់លេខ ៨ កថាខណ្ឌ ១៨-២៤។ E95/4 ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងជម្លោះប្រដាប់អាវុធ *ដូចខាងលើ* កំណត់សម្គាល់លេខ ៩ កថាខណ្ឌ ៣២-៣៤។ E95/5 ចម្លើយតបរបស់ នួន ជា ទាក់ទងនឹងជម្លោះប្រដាប់អាវុធ *ដូចខាងលើ* កំណត់សម្គាល់លេខ ១១ កថាខណ្ឌ ៦-២១។

[៧៨] Antonio Cassese *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (២០០៣) ទំព័រទី ១៥៧។

ឱ្យឃើញនោះ ការងាកទៅរកគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទនេះ*ពុំមែនជាលក្ខខណ្ឌតម្រូវនោះទេ។

## ឃ. ក្នុងអំឡុងពេលដែលពាក់ព័ន្ធ ច្បាប់ទំនៀមទម្លាប់អន្តរជាតិទទួលស្គាល់ថា អំពើរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៧១- អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា ការរំលោភសេពសន្ថវៈត្រូវបានផ្តន្ទាទោស ស្របទៅតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ចាប់តាំងពីសតវត្សរ៍ទី ១៩ មកម្ល៉េះ[៧៩]។ ស្ទើរតែគ្រប់ផ្នែកទាំងអស់ នេះគឺជាមូលដ្ឋានរួមរវាងក្រុមមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា[៨០]។

៧២- មានតែ អៀង សារី ប៉ុណ្ណោះ ដែលអះអាងថា ការរំលោភសេពសន្ថវៈពុំខុសច្បាប់ឡើយ ប៉ុន្តែគ្រាន់តែ "ជាការឱ្យរងទ្រាំដែលចាំបាច់សម្រាប់អ្នកធ្វើសង្គ្រាម"ប៉ុណ្ណោះ យោងតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិរហូតមកដល់ទសវត្សរ៍ឆ្នាំ ១៩៩០[៨១]។ អៀង សារី បានអះអាងថា ការកំណត់អំពើរំលោភសេពសន្ថវៈជាបទល្មើសព្រហ្មទណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រូវបានកំណត់ រហូតដល់ទសវត្សរ៍ក្រោយសង្គ្រាមត្រជាក់ ដែលនៅពេលនោះ "ជាលើកដំបូងបង្អស់ហើយ ដែលមានជំហាននានាក្នុងការទទួលស្គាល់ស្ត្រី ជាកម្មវត្ថុពេញលេញនៃសិទ្ធិមនុស្ស និងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិនោះ"[៨២]។

---

[៧៩] D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ *ដូចខាងលើ* កំណត់សម្គាល់លេខ ២៣ កថាខណ្ឌ ១៥១។

[៨០] E99/2 ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ៨ កថាខណ្ឌ ១៩-២០។ E99/3 ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ១០ កថាខណ្ឌ ២១-៣៤ (ដោយមិនមានការតវ៉ា។

[៨១] E99/4 ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ៩ កថាខណ្ឌ ១៤។

[៨២] *ដូចខាងលើ* កថាខណ្ឌ ១៦ កំណត់សម្គាល់ ៤៧។

៧៣- ករណីនេះ បានធ្វើឱ្យការទទួលស្គាល់លក្ខណៈព្រហ្មទណ្ឌនៃអំពើរំលោភសេពសន្ថវៈនៅក្នុងច្បាប់អន្តរជាតិ នៅក្នុងដំណាក់ការក្រោយៗតែប៉ុណ្ណោះ។ ដើម្បីជាការគាំទ្រចំពោះអំណះអំណាងនេះ អៀង សារី បានដកស្រង់សំដីថា៖

> អំពើសាហាវយង់ឃ្នងនានានៃអំពើហិង្សាផ្លូវភេទ ដែលបានប្រព្រឹត្តលើក្មេងស្រី និងស្ត្រីវ័យក្មេងរាប់ពាន់នាក់ ដែលមិនមែនជាជនជាតិជប៉ុនមកពីប្រទេសជប៉ុន ដែលបានកាន់កាប់ដែនដីជាច្រើនក្នុងអំឡុងសង្គ្រាមលោកលើកទី២ [មិនត្រូវបាន]តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា "យកចិត្តទុកដាក់នោះទេ"[៨៣]។

៧៤- ទោះបីជាយ៉ាងនេះក្តី នេះជាការលើកឡើងហួសពីជំហរដែលបានលើកឡើងដោយសាលាក្តីក្រោយសង្គ្រាមលោកលើកទី II ចំពោះអំពើរំលោភសេពសន្ថវៈ។ ជាឧទាហរណ៍ នៅក្នុងការសម្រេចឱ្យរដ្ឋមន្ត្រីការបរទេសជប៉ុនមួយរូប គឺលោក Koki Hirota ឱ្យជាប់ទោស តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា បានទទួលស្គាល់ថា អំពើទាំងឡាយ ដែលបង្កើតជាអំពើរំលោភសេពសន្ថវៈគឺជាបទល្មើសព្រហ្មទណ្ឌ៖

> តុលាការយល់ឃើញថា Hirota មានការធ្វេសប្រហែសនៅក្នុងភារកិច្ចរបស់ខ្លួន ដោយមិនបានទទូចនៅចំពោះមុខគណរដ្ឋមន្ត្រី សុំឱ្យចាត់វិធានការភ្លាមៗ ដើម្បីបញ្ឈប់អំពើសាហាវយង់ឃ្នង ហើយខកខានមិនបានចាត់វិធានការដទៃទៀត ដែលខ្លួនអាចធ្វើទៅបាន ដើម្បីទទួលបានលទ្ធផលដូចគ្នា។ ជនរូបនេះមានការពេញចិត្តនឹងការផ្អែកលើការសំអាង ដែលខ្លួនបានដឹងនៅពេលមិនបានអនុវត្តវិធានការនេះ ខណៈពេលដែលការកាប់សម្លាប់មនុស្សរាប់រយនាក់ ការរំលោភបំពានលើស្ត្រីភេទ និងអំពើឃោរឃៅដទៃទៀត ត្រូវបានប្រព្រឹត្តឡើងជារៀងរាល់ថ្ងៃ។ អំពើអកម្មរបស់ជននេះបង្កើតជាការធ្វេសប្រហែសផ្នែកព្រហ្មទណ្ឌ[៨៤]។

៧៥- ដូចដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់រួចមកហើយ ដោយមិនមានការជំទាស់តវ៉ាពីខាងក្រុមមេធាវីការពារក្តី "ភស្តុតាងនៃការរំលោភសេពសន្ថវៈត្រូវបានអានដោយរដ្ឋអាជ្ញាបារាំង និងសូវៀត

---

[៨៣] *ដូចខាងលើ* កថាខណ្ឌ ១៥។

[៨៤] ប្រតិចារឹកទាំងមូលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា បានបោះពុម្ពសារជាថ្មីនៅក្នុង R. John Pritchard និង Sonia Magbanua Zaide (eds) *ការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមនៅតូក្យូ* Vol. 20 (១៩៨១) ទំព័រទី ៥៩, ៧៩១ (គូសបញ្ជាក់បន្ថែម)

ដើម្បីបញ្ចូលក្នុងកំណត់ហេតុនៅតុលាការយោធាអន្តរជាតិ” ទោះបីជា នៅពេលចុងក្រោយ មិនមានការសម្រេចឲ្យជាប់ទោសលើបទចោទនេះក៏ដោយ[៨៥]។ ទោះក្នុងករណីណាក៏ដោយ ការអះអាងថា អំពើរំលោភសេពសន្ថវៈ មិនត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌមួយនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិរហូតដល់ពេលការបង្កើតសាលាក្តី *មិនអចិន្ត្រៃយ៍* ការអះអាងនេះជាការមិនគោរពលើអំណាចយុត្តិសាស្ត្រដែលបានបង្កើតឡើងជាយូរមកហើយនេះ[៨៦]។ ទោះបីរហូតមកដល់ទសវត្សរ៍ឆ្នាំ ១៩៩០ ទើបមាន “ការវិវឌ្ឍក្នុងការទទួលស្គាល់ស្ត្រី ជាកម្មវត្ថុពេញលេញនៃសិទ្ធិមនុស្ស”ក៏ដោយ ក៏អំពើរំលោភសេពសន្ថវៈមិនមែនជាអំពើអនីត្យានុកូលមួយក្នុងចំណោមអំពើផ្សេងៗទៀតឡើយ។

៧៦- ចម្លើយតបរបស់ អៀង ធីរិទ្ធ និង ខៀវ សំផន បានទទួលយកជំហរសមស្របជាង ដោយលើកឡើងថា ប្រភពនៃច្បាប់មុនសម័យសង្គ្រាមលោកលើកទី II ទាំងនេះបានបង្ហាញនូវការដាក់បញ្ចូលអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មសង្គ្រាម មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[៨៧]។ ទោះជាយ៉ាងនេះក៏ដោយ ប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រូវបានកំណត់ឡើងឲ្យបានជាក់លាក់ រហូតដល់ពេលមានធម្មនុញ្ញតុលាការយោធាអន្តរជាតិ នាថ្ងៃទី ៨ ខែ សីហា ឆ្នាំ

---

[៨៥] D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ *ដូចខាងលើ* កំណត់សម្គាល់លេខ ២៣ កថាខណ្ឌ ១៥២។

[៨៦] សេចក្តីបង្គាប់ដល់រដ្ឋាភិបាលយោធាសហរដ្ឋអាមេរិកនៅក្នុងសមរភូមិ (ក្រម Lieber) ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៨៦៣ មាត្រា ៤៤។ *ច្បាប់សង្គ្រាមលើដីគោក* ត្រូវបានអនុម័តដោយស្ថាប័នច្បាប់អន្តរជាតិ Oxford ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៨៨០ មាត្រា ៤៩។ *បទប្បញ្ញត្តិទីក្រុងឡាអេពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើដីគោក ដាក់ភ្ជាប់ទៅនឹងអនុសញ្ញា (II) ទាក់ទងនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើដីគោក* ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ មាត្រា ៤៦។ *បទប្បញ្ញត្តិទីក្រុងឡាអេពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើដីគោក ដាក់ភ្ជាប់ទៅនឹងអនុសញ្ញា (IV) ទាក់ទងនឹងច្បាប់ និងទំនៀមទម្លាប់ សង្គ្រាមលើដីគោក* ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ មាត្រា ៤៦។ ឧទាហរណ៍ *រដ្ឋអាជ្ញា ទល់នឹង Zejnil Delalić* រឿងក្តីលេខ IT-96-21-T សាលក្រម (អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTY) ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៤៧៦ (នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីពិនិត្យអំណះអំណាងផ្លូវច្បាប់ទាំងនេះបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ និងពិធីសារបន្ថែម បានសន្និដ្ឋានថា “វាមិនអាចមានអ្វីសង្ស័យឡើយថា ការរំលោភសេពសន្ថវៈ និងទម្រង់ផ្សេងៗទៀតនៃការបៀតបៀនផ្លូវភេទត្រូវបានហាមឃាត់យ៉ាងជាក់លាក់នៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិ”)។

[៨៧] E99/2 ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ៨ កថាខណ្ឌ ២០។ E99/3 ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ១០ កថាខណ្ឌ ២២។

១៩៤៥[៨៨]។ នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ អំពើរំលោភសេពសន្ថវៈ ត្រូវបានដាក់បញ្ចូលជាបទល្មើសមួយដាច់ដោយឡែក នៅក្នុងបទល្មើសទាំងឡាយដូចបានរៀបរាប់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងច្បាប់លេខ ១០[៨៩] បាននិយថា អំពើរំលោភសេពសន្ថវៈត្រូវបានដាក់បញ្ចូលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងរយៈពេលតែប៉ុន្មានខែក្នុងពេលបង្កើតគោលការណ៍ច្បាប់ឱ្យមានភាពស៊ីសង្វាក់នឹងគ្នា និងនាពេលថ្មីៗបំផុតនោះ គឺនៅក្នុងលក្ខន្តិកៈបង្កើតសាលាក្តីព្រហ្មទណ្ឌអន្តរជាតួបនីយកម្មនៅមុនសម័យកម្ពុជាប្រជាធិបតេយ្យ។

៧៧- ទោះបីជា ខៀវ សំផន បានសង្កេតឃើញថា ការអនុវត្តរបស់រដ្ឋ និង*សច្ចធារណ៍ធម្មានុរូប* មិនអាចកើតចេញពីច្បាប់លេខ ១០[៩០] តែមួយគត់នោះទេក៏ដោយ ក៏យុត្តិសាស្រ្ត និងការអនុវត្តរបស់រដ្ឋនាពេលក្រោយៗមកទៀតនោះ បង្ហាញថា អំពើរំលោភសេពសន្ថវៈត្រូវបានពិចារណាឃើញថាបានក្លាយទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលនោះ ឬក្រោយពីពេលនោះភ្លាមៗមករហូត។ កត្តាចំនួនពីរដែលចង្អុលបញ្ជាក់លើការសន្និដ្ឋានបែបនេះ។

៧៨- កត្តាទីមួយ ការវិវឌ្ឍសំខាន់ៗពុំឃើញកើតមានឡើងនៅក្នុងនិយាមនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលពាក់ព័ន្ធនឹងការកំណត់អំពើរំលោភសេពសន្ថវៈ ជាបទល្មើសព្រហ្មទណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅចន្លោះពេលចាប់ផ្តើមសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការបង្កើតសាលាក្តី*មិនអចិន្ត្រៃយ៍*នោះទេ។ សាស្ត្រាចារ្យ Gerhard Werle លើកឡើងថា ទោះបីជា “មូលដ្ឋានគតិយុត្តនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ភាគច្រើនមានលក្ខណៈរឹងមាំ” មកត្រឹមដើមទសវត្សរ៍ឆ្នាំ ១៩៩០ ហើយ

---

[៨៨] Gerhard Werle *គោលការណ៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (២០០៥) ទំព័រទី ២១៦៖ “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្កើតឡើងយ៉ាងជាក់លាក់ជាលើកដំបូងជាប្រភេទនៃបទល្មើសនៅក្នុងមាត្រា ៦(គ)នៃធម្មនុញ្ញ Nuremberg” (“Werle”)។

[៨៩] ច្បាប់លេខ ១០ *ដូចខាងលើ* កំណត់សម្គាល់លេខ ៥៩៖ “អំពើឃោរឃៅ និងបទល្មើស ដែលរួមមាន ដោយមិនកំណត់ត្រឹមមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការនិរទេស ការដាក់ឱ្យជាប់ពន្ធនាគារ ទារុណកម្ម រំលោភសេពសន្ថវៈ ឬ អំពើអមនុស្សធម៌ដទៃៗទៀត ដែលត្រូវបានប្រព្រឹត្តមកលើប្រជាជនស៊ីវិល ឬ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា មិនថាបានរំលោភលើច្បាប់ក្នុងស្រុករបស់ប្រទេស ដែលបទល្មើសបានកើតឡើងក៏ដោយ”។

[៩០] E99/3 ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ១០ កថាខណ្ឌ ២៥៖ “ការអនុវត្តទូទៅនៃរដ្ឋទាំងឡាយ និងទស្សនៈច្បាប់ មិនអាចមានប្រភព... មកពីច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យឡើយ”។

ក៏ដោយ "ក៏បណ្តារដ្ឋ និងសហគមន៍ប្រជាជាតិទាំងឡាយ ខ្វះឆន្ទៈ និងលទ្ធភាពក្នុងការអនុវត្ត គោលការណ៍ទាំងនេះ" មុនទសវត្សរ៍ឆ្នាំ ១៩៩០[៩១]។ ចំណុចនេះ គាំទ្រដល់ការសន្និដ្ឋានរបស់លោក សាស្ត្រាចារ្យអំពីហេតុផល ដែលនាំឲ្យការកម្រិតលើការចោទប្រកាន់លើបទល្មើសអន្តរជាតិចំបងៗ រហូតដល់ពេលបញ្ចប់សង្គ្រាមត្រជាក់៖

> *ក្នុងអំឡុងពេលនៃសង្គ្រាមត្រជាក់... កង្វះនៃឆន្ទៈនយោបាយនឹងបង្កជាការរារាំងចំពោះការប្រើប្រាស់ការដាក់ទណ្ឌកម្មព្រហ្មទណ្ឌលើអំពើឃោរឃៅយង់ឃ្នងដែលគាំទ្រដោយរដ្ឋ។ រហូតដល់ពេលបញ្ចប់សង្គ្រាមត្រជាក់ ទើបអង្គការសហប្រជាជាតិ ដែលជំរុញដោយបទល្មើសគួរឲ្យព្រឺក្បាលទាំងឡាយ នៅក្នុងអតីតប្រទេសយូហ្គោស្លាវី និងរវ៉ាន់ដា បង្ហាញនូវឆន្ទៈនយោបាយរបស់ខ្លួនសារជាថ្មី...*[៩២] ។

៧៩- អត្ថិភាពនៃវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលបានកំណត់អំពើរំលោភសេពសន្ថវៈជាបទល្មើសព្រហ្មទណ្ឌ គឺមានទស្សនាទានខុសពីឆន្ទៈនយោបាយ ដែលចាំបាច់នៅក្នុងការចោទប្រកាន់បទល្មើសអន្តរជាតិចំបងៗ ឬ នៅក្នុងការផ្តល់អាទិភាពចាំបាច់ចំពោះការចោទប្រកាន់បទល្មើសទាំងឡាយដែលយកស្ត្រីភេទជាគោលដៅចំបង។ ដោយហេតុថា អំពើរំលោភសេពសន្ថវៈត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាយូរមកហើយ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ វាគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេថា ការបង្ហាញ "ឆន្ទៈនយោបាយសារជាថ្មី" រដ្ឋទាំងឡាយដែលឯកភាពលើលក្ខន្តិកៈរបស់សាលាក្តី ICTY និងសាលាក្តី ICTR បានកំណត់អំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំមានការចម្រូងចម្រាស ឬ ការជំទាស់ណាមួយឡើយ ហើយសាលាក្តីទាំងនេះ បានធ្វើការសម្រេចដាក់ទោសដោយឯករាជ្យលើបទរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៩៣]។

៨០- ផ្ទុយពីជំហររបស់ អៀង សារី អំពើរំលោភសេពសន្ថវៈដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌឡើយ នៅក្រោយពេលសង្គ្រាមត្រជាក់បានបញ្ចប់ ដើម្បីជាផ្នែក

[៩១] ("Werle") *ដូចខាងលើ* កំណត់សម្គាល់លេខ ៨៨ ទំព័រទី ១៥។

[៩២] ("Werle") *ដូចខាងលើ* កំណត់សម្គាល់លេខ ៨៨ ទំព័រទី ៣។

[៩៣] E99 សំណើទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ២ កថាខណ្ឌ ១៦-១៧។

មួយនៃ"វង្វង់សមាហារណកម្មយេនឌ័រ"[៥៤]។ ការយោងរបស់ អៀង សារី លើសេចក្តីប្រកាសទីក្រុងវៀន( Vienna)ឆ្នាំ ១៩៩៣ និងកម្មវិធីសកម្មភាព ថាជាការវិវឌ្ឍជាក់ស្តែងមួយពាក់ព័ន្ធចំពោះការកំណត់អំពើរំលោភសេពសន្ថវៈថាជាបទល្មើសព្រហ្មទណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាការយោងមួយដោយមិនត្រឹមត្រូវ[៥៥] ពោលគឺ សន្និសីទសកលលោកស្តីពីសិទ្ធិមនុស្ស ខកខានពុំបានអនុម័តសន្ធិសញ្ញាចងកាតព្វកិច្ចឡើយ តែបែរជាអនុម័តសេចក្តីប្រកាសមិនចងកាតព្វកិច្ចមួយទៀតវិញ ហើយទោះក្នុងករណីណាក៏ដោយ សន្និសីទនេះបានរៀបចំឡើងក្រោយពេលដែលសាលាក្តី ICTY បានរកឃើញថា អំពើរំលោភសេពសន្ថវៈត្រូវបានគេចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ហួសពីវិមតិសង្ស័យ"។

៨១- ជាពិសេស ចម្លើយតបរបស់ អៀង ធីរិទ្ធ និង ខៀវ សំផន ច្រានចោលសេចក្តីយោងលើសាលាក្តី *មិនអចិន្ត្រៃយ៍* ដោយផ្អែកលើមូលដ្ឋានថា យុត្តាធិការពេលវេលារបស់សាលាក្តីទាំងនោះ គឺជាយុត្តាធិការពេលវេលាកើតឡើងក្រោយសាលាក្តីមួយនេះ[៥៦]។ ទោះបីជាយ៉ាងនេះក្តី ការលើកឡើងដូច្នេះ គឺមិនត្រឹមត្រូវឡើយ។ ដូចដែលបានលើកឡើងដោយចម្លើយតបទាំងពីរនេះ សហព្រះរាជអាជ្ញាសូមមិនយកយុត្តិសាស្ត្ររបស់សាលាក្តីដែលមានយុត្តាធិការពេលវេលា នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ មកធ្វើជាប្រភពច្បាប់ដើម្បីអនុវត្តចំពោះទសវត្សរ៍ឆ្នាំ ១៩៧០ ឡើយ[៥៧]។ ក៏ប៉ុន្តែ យុត្តិសាស្ត្រនេះមានសារ-ប្រយោជន៍នៅក្នុងការកំណត់បរិបទ និងឋានៈនៃអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងពេលក្រោយសង្គ្រាមលោកលើកទី II ភ្លាមៗ[៥៨]។ ខៀវ សំផន មិនបានលើកឡើងបញ្ហានេះ

[៥៤] E99/4 ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ៩ កថាខណ្ឌ ១៨។

[៥៥] *ដូចខាងលើ* កថាខណ្ឌ ១៦។

[៥៦] E99/2 ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ៨ កថាខណ្ឌ ២២-២៤។ E99/3 ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ១០ កថាខណ្ឌ ៣១-៣២។

[៥៧] E99/2 ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កថាខណ្ឌ ២៤។ E99/3 ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កថាខណ្ឌ ៣១។

[៥៨] E99 សំណើទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ២ កថាខណ្ឌ ១៨-២១។

ចំណែក អៀង ធីរិទ្ធ បានលើកឡើងតែករណីដែលថា "មេធាវីការពារក្តីសូមលើកឡើងថា ការអះអាងបែបនេះ គឺមិនត្រឹមត្រូវទេ" ហើយ "គួរត្រូវបានច្រានចោល ដោយមូលហេតុថា ទឡ្ហីករណ៍នេះមិនសមហេតុផល ឬ មិនមានភាពត្រឹមត្រូវ"[៩៩]។ ការជំទាស់តែមួយគត់ទៅនឹងទឡ្ហីករណ៍នេះ ដែលបានលើកឡើងដោយ អៀង សារី គឺផ្អែកលើ "តួនាទីបន្ទាប់បន្សំដែលបានរំពឹងទុក សម្រាប់ការកំណត់តាមផ្លូវតុលាការ" អនុលោមតាមមាត្រា ៣៨(១)(ឃ)នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ[១០០]។ ទោះបីជាយ៉ាងនេះក្តី បទប្បញ្ញត្តិនេះជាប់ទាក់ទងទៅនឹងឋានៈនៃសេចក្តីសម្រេចតាមផ្លូវតុលាការនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ តែវាពុំជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការប្រើប្រាស់សេចក្តីសម្រេចរបស់សាលាក្តី ICTY ដោយ អ.វ.ត.ក ព្រមទាំងទៅនឹងការយោងជាលក្ខណៈទូទៅជាងនេះ ទៅរកយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតូបនីយកម្មផងដែរ[១០១]។

៨២- ច្បាប់ដែលសាលាក្តី ICTY យកមកប្រើប្រាស់ដើម្បីដំណើរការ ពុំមែនជាលទ្ធផលកើតចេញពីការសម្របសម្រួលនាពេលថ្មីៗទៅនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ក៏ប៉ុន្តែ ច្បាប់ទាំងនោះត្រូវបានរៀបរៀងដោយប្រុងប្រយ័ត្ន ដើម្បីដាក់បញ្ចូលចំពោះអំពើទាំងឡាយណាដែល "ជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយគ្មានអ្វីសង្ស័យឡើយ"[១០២]។

---

[៩៩] E99/2 ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ៨ កថាខណ្ឌ ២៣។

[១០០] E99/4 ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ៩ កថាខណ្ឌ ១៧។

[១០១] *ដូចខាងលើ*។

[១០២] របាយការណ៍របស់អគ្គលេខាធិការ ជូនមហាសន្និបាត ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៩៣ (S/25704) កថាខណ្ឌ ៣៤។ សូមមើលផងដែរនូវ *រដ្ឋអាជ្ញា ទល់នឹង Duško Tadić*, រឿងក្តីលេខ IT-94-1-T មតិយោបល់ និងសាលក្រម (អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTY) ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦៦២។ *រដ្ឋអាជ្ញា ទល់នឹង Milan Milutinović*, រឿងក្តីលេខ IT-05-87-PT សាលដីកាលើបណ្តឹងរបស់ Ojdanić តវ៉ាលើយុត្តាធិការ៖ សហចារីមិនផ្ទាល់ (អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTY) ថ្ងៃទី២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ១៥។

៨៣- អៀង សារី អះអាងថា ការលើកឡើងនេះមិនគួរយកមកពិចារណាដោយមានន័យថា "បទល្មើសអន្តរជាតិ...ដូចបានរៀបរាប់នៅក្នុងលក្ខន្តិកៈរបស់សាលាក្តី ICTY គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ "ដោយគ្មានអ្វីសង្ស័យ" នោះឡើយ" ប៉ុន្តែ "...សាលាក្តី ICTY បានដំណើរការទៅដោយប្រុងប្រយ័ត្ន ដើម្បីធានាថា មានតែវិធានទាំងនោះ ដែលជាផ្នែកមួយនៃ "ច្បាប់ទំនៀមទម្លាប់អន្តរជាតិ "ដោយគ្មានអ្វីសង្ស័យ" ដែលត្រូវយកមកអនុវត្តដោយសាលាក្តីនេះ"[១០៣]។ ការបែងចែកដូច្នេះមានផលប៉ះពាល់ជាក់ស្តែងតិចតួចប៉ុណ្ណោះគឺ ជនទាំងឡាយដែលត្រូវបានសម្រេចឱ្យជាប់ទោសពីបទរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅសាលាក្តី ICTY ត្រូវបានសម្រេចឱ្យជាប់ទោស ដោយផ្អែកលើនិយមន័យ*ត្រង់ៗ* ដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់សាលាក្តី ICTY[១០៤]។ ទោះបីជា ខៀវ សំផន ដកស្រង់ចំណុចផ្ទុយគ្នានៅក្នុងយុត្តិសាស្ត្ររបស់សាលាក្តី ICTY ត្រង់និយមន័យនៃអំពើរំលោភសេពសន្ថវៈ ដើម្បីយកមកធ្វើជាមូលដ្ឋានគាំទ្រលើការអះអាងរបស់ខ្លួនថា អំពើរំលោភសេពសន្ថវៈត្រូវបានគេចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនាពេលថ្មីៗក៏ដោយ[១០៥] ក៏សេចក្តីសម្រេចទាំងឡាយ ដែលបានដកស្រង់ មានភាពខុសគ្នានៅត្រង់និយមន័យនៃធាតុផ្សំជាក់លាក់មួយចំនួននៃអំពើរំលោភសេពសន្ថវៈ ពុំមែនជាចំណុចវិវាទនៅពេលនេះឡើយ ប៉ុន្តែវាមានភាពស៊ីសង្វាក់យ៉ាងពិតប្រាកដនៅក្នុងការទទួលស្គាល់ឋានៈនៃអំពើនេះថាជាអំពើមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[១០៦]។

---

[១០៣] E99/4 ចម្លើយតបរបស់ អៀង សារី ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ៩ កថាខណ្ឌ ១៥។

[១០៤] សូមមើលឧទាហរណ៍ ការសម្រេចឱ្យជាប់ទោសពីបទរំលោភសេពសន្ថវៈនៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Kunarac រឿងក្តីលេខ IT-96-23-T និង IT-96-23/1-T សាលក្រម (អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTY) ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៤៣៦-៤៦៤។

[១០៥] E99/3 ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ១០ កថាខណ្ឌ ៣០ "ការខ្វែងគំនិតរវាងយុត្តិសាស្ត្រទី១ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីអតីតប្រទេសយូហ្គោស្លាវី និងយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីប្រទេសរវ៉ាន់ដា តុលាការព្រហ្មទណ្ឌអន្តរជាតិស្តីពីវិសាលភាពនៃសញ្ញាណនេះ...ការបញ្ចូលនាពេលថ្មីៗ នូវការចោទប្រកាន់អំពើរំលោភសេពសន្ថវៈ..."។

[១០៦] *រដ្ឋអាជ្ញា ទល់នឹង* Akayesu រឿងក្តីលេខ IT-95-17/1-T សាលក្រម (អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTR) ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨។ *រដ្ឋអាជ្ញា ទល់នឹង* Furundžija រឿងក្តីលេខ IT-95-17/1-T សាលក្រម (អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTR) ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨។ *រដ្ឋអាជ្ញា ទល់នឹង* Kunarac រឿងក្តីលេខ IT-96-23-T និង IT-96-23/1-T សាលក្រម (អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTY) ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១។

៨៤- អៀង ធីរិទ្ធ បានអះអាងថា "សហព្រះរាជអាជ្ញាមិនបានយោងទៅលើសំអាងផ្លូវច្បាប់នានា ដែលអាចបង្ហាញថា បទរំលោភសេពសន្ថវៈមានអត្ថិភាពជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយខ្លួនឯងផ្ទាល់នៅមុនឆ្នាំ ១៩៧៥"[១០៧]។ ខៀវ សំផន នៅតែសន្និដ្ឋានថា សហព្រះរាជអាជ្ញាត្រូវតែផ្អែកលើប្រភពទាំងឡាយណា ដែល*ទំនងជា*គាំទ្រឧក្រិដ្ឋបនីយកម្មនៃអំពើរំលោភសេពសន្ថវៈតាមច្បាប់ទំនៀមទម្លាប់ ថាជាបទល្មើសព្រហ្មទណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមុន ឬ ក្នុងចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩[១០៨]។

៨៥- សហព្រះរាជអាជ្ញាសូមស្នើឡើងថា ចម្លើយតបទាំងនោះបានបំផ្លើសយ៉ាងច្រើនចំពោះលក្ខខណ្ឌសម្រាប់ការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃបទរំលោភផ្លូវភេទ ដោយការអនុវត្តរបស់រដ្ឋមួយចំនួន ដោយមិនមានការជំទាស់ពីរដ្ឋដទៃទៀត អាចបង្កើតបានជាវិធានទំនៀមទម្លាប់នោះ។ នៅក្នុងអត្ថបទមួយដែលត្រូវបានចេញនៅ ក្នុងឆ្នាំ ១៩៧៧ ស្តីពីការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ សាស្ត្រាចារ្យ Michael Akehurst បានកត់សម្គាល់ថា៖

> *មតិយោបល់ទាំងអស់របស់តុលាការនៅក្រៅរឿងក្តី (*judicial dicta*) ដែលតម្រូវឱ្យមានការអនុវត្តយ៉ាងច្រើនរបស់រដ្ឋនោះ ត្រូវបានលើកឡើងក្នុងករណីដែលមានការអនុវត្តផ្ទុយគ្នា [...]អំពើមួយចំនួនតូចដែលទាក់ទងនឹងរដ្ឋពីរបី និងនៅក្នុងអំឡុងពេលវេលាតិចតួចប៉ុណ្ណោះ មានភាពគ្រប់គ្រាន់ដើម្បីបង្កើតបានជាវិធាននៃច្បាប់ទំនៀមទម្លាប់ហើយ ឱ្យតែមិនមានការអនុវត្តខុសគ្នានោះ*[១០៩]។

[១០៧] E99/2 ចម្លើយតបរបស់ អៀង ធីរិទ្ធ ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ៨ កថាខណ្ឌ ២២។

[១០៨] E99/3 ចម្លើយតបរបស់ ខៀវ សំផន ទាក់ទងនឹងការចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ *ដូចខាងលើ* កំណត់សម្គាល់លេខ ១០ កថាខណ្ឌ ២៣ "ដោយសារតែមិនអាចផ្តល់នូវប្រភព ដែលមានទំនោរទៅរកការអះអាងបញ្ជាក់ពីការចោទប្រកាន់តាមទំនៀមទម្លាប់ប្រពៃណីចំពោះអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មុន ឬ ក្នុងចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ សហព្រះរាជអាជ្ញាក៏ភាន់ភាំងក្នុងការប៉ាន់ស្មានរបស់ខ្លួន"។

[១០៩] Michael Akehurst "ទំនៀមទម្លាប់ដែលជាប្រភពនៃច្បាប់អន្តរជាតិ" (១៩៧៤-៥) *British Yearbook of International Law* 1 ទំព័រ ១៨-១៩។

៨៦- ស្រដៀងគ្នានេះដែរ សាស្ត្រាចារ្យ Malcolm Shaw គាំទ្រសំណើដែលថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចត្រូវបានបង្កើតឡើងដោយរដ្ឋតែមួយចំនួនតូចប៉ុណ្ណោះ៖

> *"...... ទំនៀមទម្លាប់អាចត្រូវបានបង្កើតឡើងដោយរដ្ឋតែមួយចំនួនតូចបាន ឲ្យតែរដ្ឋទាំងនោះមានការជាប់ទាក់ទងគ្នាយ៉ាងជិតដិតជាមួយនឹងបញ្ហានៅចំពោះមុខ ទោះបីជាដោយសារទ្រព្យសម្បត្តិ និងអំណាចរបស់ខ្លួនក្តី ឬដោយសារទំនាក់ទំនងពិសេសរបស់ខ្លួនជាមួយនឹងប្រធានបទនៃការអនុវត្តនោះ ..."*[១១០] ។

៨៧- តាមពិតទៅ ការអនុវត្តរបស់រដ្ឋដែលបានគាំទ្រដល់សំណើដែលថា អំពើរំលោភសេពសន្ថវៈ ត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងនៅមុន និងនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីសង្គ្រាមរំដោះជាតិ ដែលប្រទេសប៉ាគីស្ថានខាងកើត បានបំបែកខ្លួនចេញពីប្រទេសប៉ាគីស្ថានខាងលិចក្នុងឆ្នាំ ១៩៧១ អង្គនីតិបញ្ញត្តិនៃប្រទេសបង់ក្លាដែសដែលទើបតែបង្កើតថ្មី បានអនុម័ត *ច្បាប់ស្តីពីឧក្រិដ្ឋកម្ម (តុលាការ) អន្តរជាតិនៅឆ្នាំ ១៩៧៣* ដើម្បីផ្តន្ទាទោសចារីពីការរំលោភសេពសន្ថវៈក្នុងទ្រង់ទ្រាយធំ។ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ប្រទេសបង់ក្លាដែស ត្រូវបានលើកឡើងនៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងបានដាក់បញ្ចូលបទរំលោភសេពសន្ថវៈថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[១១១] ។

៨៨- សេចក្តីសន្និដ្ឋានដូចគ្នានេះអាចទាញបានពីការពិនិត្យទៅលើការវិវត្តន៍នៃវិសាលភាពនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ និយមន័យនីមួយៗត្រូវបានកំណត់ដោយប្រើប្រាស់ពាក្យពេចន៍ស្ទើរតែដូចគ្នាបេះបិទ។ ធម្មនុញ្ញរបស់តុលាការ Nuremberg ចុះខែ សីហា ឆ្នាំ ១៩៤៥ បានផ្តល់នូវការបញ្ជាក់ជាលើកទីមួយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថាជា៖

---

[១១០] Malcolm Shaw "ច្បាប់អន្តរជាតិ" បោះពុម្ពលើកទីប្រាំមួយ ២០០៨, ទំព័រ ៧៩។

[១១១] *ច្បាប់ស្តីពីឧក្រិដ្ឋកម្ម (តុលាការ) អន្តរជាតិឆ្នាំ ១៩៧៣ កំណត់សម្គាល់លេខ ៧៤ ខាងលើ* s. 3(2)(a) ។

*អំពើមនុស្សឃាដ ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការនិរទេសខ្លួន និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលបានប្រព្រឹត្តទៅលើជនស៊ីវិល នៅមុន ឬនៅក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាតិសាសន៍ ឬសាសនា ...*[១១២] ។

៨៩- នៅក្នុងរយៈពេលជាច្រើនខែ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង បានពង្រីកនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះដោយដាក់បញ្ចូល "ការដាក់ក្នុងពន្ធនាគារ ការធ្វើទារុណកម្ម និងការរំលោភសេពសន្ថវៈ"៖

*អំពើសាហាវយង់ឃ្នង និងបទល្មើសជាច្រើនទៀត <u>រួមទាំង តែមិនកំណត់ត្រឹមតែ</u> អំពើមនុស្សឃាដការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការនិរទេសខ្លួន ការធ្វើទារុណកម្ម និង<u>ការរំលោភសេពសន្ថវៈ</u> និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលបានប្រព្រឹត្តទៅលើជនស៊ីវិល ឬការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាតិសាសន៍ ឬសាសនា ...*[១១៣] ។

៩០- រយៈពេល ១៨ ឆ្នាំ ក្រោយមក និងនៅមុនអំឡុងកម្ពុជាប្រជាធិបតេយ្យតែបន្តិចនោះ អង្គនីតិបញ្ញត្តិប្រទេសបង់ក្លាដែស បានដាក់បញ្ចូលនិយមន័យនេះ ដោយបន្ថែម "ការចាប់ជំរិត និងការបង្ខាំងខ្លួន" ថែមទៀត៖

*... អំពើមនុស្សឃាដ ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការនិរទេសខ្លួន ការដាក់ក្នុងពន្ធនាគារ ការចាប់ជំរិត ការបង្ខាំងខ្លួន ការធ្វើទារុណកម្ម និង<u>ការរំលោភសេពសន្ថវៈ</u> និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលបានប្រព្រឹត្តឡើងទៅលើជនស៊ីវិល ឬការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាតិសាសន៍ ជាតិពន្ធុ ឬសាសនា ...*[១១៤] ។

៩១- លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដាក់បញ្ចូលនូវប្រភេទដូចគ្នានៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចគ្នានឹងច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ ដែរ៖

---

[១១២] ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ (១៩៤៥) មាត្រា ៦(គ)។

[១១៣] ច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០, កំណត់សម្គាល់លេខ ៥៩ *ខាងលើ* ។

[១១៤] *ច្បាប់ស្តីពីឧក្រិដ្ឋកម្ម (តុលាការ) អន្តរជាតិឆ្នាំ ១៩៧៣ កំណត់សម្គាល់លេខ ៧៥ ខាងលើ* s. 3(2)(a)។

*... (ក) អំពើមនុស្សឃាដ (ខ) ការសម្លាប់រង្គាល (គ) ការដាក់ឲ្យទៅជាទាសករ (ឃ) ការនិរទេសខ្លួន (ង) ការដាក់ក្នុងពន្ធនាគារ (ច) ការធ្វើទារុណកម្ម (ឆ) ការរំលោភសេពសន្ថវៈ (ជ) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាតិសាសន៍ ឬសាសនា (ឈ) អំពើអមនុស្សធម៌ផ្សេងៗទៀត*[១១៥] ។

៩២- ដោយពិចារណាឃើញថា ច្បាប់ស្ដីពីក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ បានដាក់បញ្ចូលបទរំលោភសេពសន្ថវៈថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាំងពីឆ្នាំ ១៩៤៥ មកម្ល៉េះ ពាក្យពេចន៍ប្រហាក់ប្រហែលគ្នាខ្លាំងនៅគ្រប់ករណីទាំងអស់នៃការអនុវត្តដែលមានការគ្មានភាពផ្ទុយគ្នាជាដំកំភួននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងការណ៍ដែលថា បទរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបញ្ជាក់ដោយតុលាការថាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយ "លើសពីវិមតិសង្ស័យ" នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ សហព្រះរាជអាជ្ញាសូមស្នើឡើងថា បទរំលោភសេពសន្ថវៈ ត្រូវបានបង្កើតឡើងនៅក្នុង*ច្បាប់ដែលមានអត្ថិភាព* (*lex lata*) ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅមុន និងក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។

## ង. នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានទទួលស្គាល់ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III ថាជាទម្រង់មួយនៃការទទួលខុសត្រូវ

៩៣- យុត្តិសាស្ត្រច្បាស់លាស់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានកំណត់យ៉ាងច្បាស់ថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី III គឺជាទម្រង់មួយនៃការទទួលខុសត្រូវដែលត្រូវបានទទួលស្គាល់នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៩២ ដែលជាចំណុចចាប់ផ្ដើមចោទប្រកាន់ និងផ្ដន្ទាទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីទៅលើការប្រព្រឹត្តនេះ។ ចម្លើយតបរបស់មេធាវី ការពារក្ដីបីក្រុម ព្យាយាមបង្ហាញនូវទឡ្ហីករណ៍មួយថា ទម្រង់ទី ៣ នៃការទទួលខុសត្រូវក្នុងសហ ឧក្រិដ្ឋកម្មរួម មិនបានបង្កើតទៅជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិប

[១១៥] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY Statute) មាត្រា ៥ (សង្កត់ន័យបន្ថែម)។

តែយ្យនោះទេ[១១៦]។ ការអះអាងប្រហាក់ប្រហែលគ្នានេះក៏ត្រូវបានលើកឡើងនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ទាក់ទងនឹងស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងដើមទសវត្សរ៍ឆ្នាំ១៩៩០ដែរ។ ជាឧទាហរណ៍ នៅក្នុងករណីរបស់ Joseph Nzirorera ដើមបណ្តឹងឧទ្ធរណ៍បានចោទប្រកាន់ថា៖

> *... តុលាការខ្វះយុត្តាធិការដើម្បីអនុវត្តការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម (JCE) ទម្រង់ទីបី ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយអ្នកចូលរួមនៅក្នុង JCE ដ៏ទូលំទូលាយមួយ ជាពិសេស ចំពោះអ្នកដែលស្ថិតនៅទីឆ្ងាយពីជនជាប់ចោទ ទាំងផ្នែករចនាសម្ព័ន្ធ ឬផ្នែកភូមិសាស្ត្រ ដោយសារ ដើមបណ្តឹងឧទ្ធរណ៍មិនឃើញមានភស្តុតាងដែលបង្ហាញយ៉ាងច្បាស់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ អនុញ្ញាតឲ្យមានការអនុវត្តការទទួលខុសត្រូវលើ JCE ទម្រង់ទីបី ចំពោះឧក្រិដ្ឋកម្មរបស់ខ្លួន នោះទេ*[១១៧]។

៩៤- អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានបដិសេធមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះភ្លាមៗ ដោយសំអាងទៅលើមូលដ្ឋាននៃយុត្តិសាស្ត្រដ៏ច្បាស់លាស់របស់តុលាការ ICTY ដោយលើកឡើងថា "... មិនមានអ្វីដែលគួរឲ្យឆ្ងល់នោះទេថា ការទទួលខុសត្រូវលើ JCE ទម្រង់ទីបី ត្រូវបានទទួលស្គាល់យ៉ាងច្បាស់លាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[១១៨] ហើយបន្ទាប់មកទៀតថា "វាច្បាស់ហើយថា មានមូលដ្ឋាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាំងសម្រាប់ការទទួលខុសត្រូវលើ JCE ទូទៅ និងជាពិសេស ការទទួលខុសត្រូវលើ JCE ទម្រង់ទីបីនេះ"[១១៩]។

---

[១១៦] ឯកសារ **E100/5** សារណាតបរបស់ នួន ជា ទៅនឹង JCE III កំណត់ត្រា*ខាងលើ* **Error! Bookmark not defined** កថាខណ្ឌ ៨។ ឯកសារ **E100/1** ចម្លើយតបរបស់ អៀង ធីរិទ្ធ ទៅនឹង JCE III កំណត់ត្រាលេខ ៨ *ខាងលើ* ពីកថាខណ្ឌ ១៨ ដល់ ១៩។ ឯកសារ **E100/2** ចម្លើយតបរបស់លោក អៀង សារី កំណត់ត្រាលេខ ៩ *ខាងលើ* ពីកថាខណ្ឌ ៩ ដល់ ១៨។

[១១៧] *រដ្ឋអាជ្ញា តទល់នឹង Édouard Karemera និងអ្នកផ្សេងទៀត*។ ICTR-98-44-AR72.5 និង ICTR-98-44-AR72.6 សាលដីកាសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ស្តីពីយុត្តាធិការ៖ សហឧក្រិដ្ឋកម្មរួម (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR ) ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០០៦ កថាខណ្ឌ ១៤។

[១១៨] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ១៣។

[១១៩] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ១៦។

៩៥- សហព្រះរាជអាជ្ញាសូមស្នើឡើងដោយគោរពថា ខ្លួនមិនឃើញមានភស្តុតាងស្តីពីការអភិវឌ្ឍជាដុំកំភួននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ ១៩៧៤ និង ១៩៩១ ដែលគាំទ្រដល់ការកែប្រែណាមួយចំពោះស្ថានភាពច្បាប់ស្តីពីសហឧក្រិដ្ឋកម្មរួម ដែលជាទម្រង់នៃសហចារីកម្មនោះទេ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា JCE ទម្រង់ទី III មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ការយល់ឃើញនេះនឹង បង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជម្រះនានារបស់តុលាការ ICTY និងតុលាការ ICTR មានកំហុសចំពោះការផ្តន្ទាទោសដោយផ្អែកទៅលើមូលដ្ឋាននៃ JCE ទម្រង់ទី III នេះ។

៩៦- ទាំង អៀង ធីរិទ្ធ[១២០] និង អៀង សារី[១២១] បានបដិសេធការយោងរបស់សហព្រះរាជអាជ្ញាចំពោះ JCE ទម្រង់ទី III ជាមួយនឹងកម្មវត្ថុ និងគោលបំណងនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ជាពិសេស អៀង សារី អះអាងថា គោលនយោបាយអន្តរជាតិសាធារណៈដែលទម្រង់នៃការទទួលខុសត្រូវក្នុង JCE III ធ្វើការឆ្លើយតបនោះ "មិនបានផ្តល់យុត្តិកម្មដល់" ការអនុវត្តទម្រង់នៃការទទួលខុសត្រូវក្នុង JCE III បានទេ ត្បិតវាផ្ទុយគ្នានឹង "គោលការណ៍ណែនាំជាមូលដ្ឋានដែលថា ជនជាប់ចោទគួរត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះតែការប្រព្រឹត្តណាមួយដែលខ្លួនគាត់ ម្នាក់ឯងទទួលខុសត្រូវដោយផ្ទាល់តែប៉ុណ្ណោះ"[១២២]។ សហព្រះរាជអាជ្ញាសូមបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង ចំពោះការវាយតម្លៃដូចខាងក្រោម នៅក្នុងការវិភាគថ្មីៗបំផុតទៅលើនីត្យានុកូលភាពនៃការអនុវត្ត JCE III របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសលីបង់៖

> *JCE ប្រភេទទី III ត្រូវបានបដិសេធ ដោយសារខ្លាចក្រែង JCE ប្រភេទទី III នេះអាចរំលោភលើគោលការណ៍នៃការទទួលខុសត្រូវ* (nullum crimen sine culpa) *។ មានអំណះអំណាងដែលលើកឡើងថា នៅក្រោមសហឧក្រិដ្ឋកម្មរួមប្រភេទនេះ ការទទួលខុសត្រូវរបស់ជនសមគំនិត* "secondary offender" *(ដែលបានចូលរួមនៅក្នុងផែនការឧក្រិដ្ឋ ឬការព្រមព្រៀងគ្នា បានប្រព្រឹត្តទៅតាមការព្រមព្រៀងគ្នានេះ និងបានប្រមើលមើលដឹងជាមុនអំពីបទល្មើសបន្ថែមទៀត ប៉ុន្តែមិនបានប្រព្រឹត្តបទល្មើសដែលមិនបានព្រមព្រៀងគ្នា គឺពិតជាមិនដូចគ្នានឹងមេក្លោង* "primary offender"

---

[១២០] ឯកសារ **E100/1** ចម្លើយតបរបស់ អៀង ធីរិទ្ធ ទៅនឹង JCE III ជើងទំព័រលេខ ៨ *ខាងលើ* កថាខណ្ឌ ២២។

[១២១] ឯកសារ **E100/2** ចម្លើយតបរបស់ អៀង សារី ទៅនឹង JCE III ជើងទំព័រលេខ ៩ *ខាងលើ* កថាខណ្ឌ ២៥ ដល់ ២៨។

[១២២] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៥។

*(ដែលប្រព្រឹត្តបទល្មើសដែលបានព្រមព្រៀងគ្នា រួមទាំងបទល្មើសដែលមិនបានព្រមព្រៀងគ្នាថែមទៀតផង)។ មានការជំទាស់តវ៉ាថា តាមមធ្យោបាយនេះគេអាចរកឃើញពិរុទ្ធភាពនៃការសម្លាប់ជនណាម្នាក់ ("ជាជនសមគំនិត" ដែលមិនមានចេតនាសម្លាប់នោះទេ ផ្ទុយទៅវិញ ចេតនានេះត្រូវបានផ្តួចផ្តើមឡើងដោយ "មេក្លោង" ដែលបានប្រព្រឹត្តអំពើឃាតកម្ម [...]។*

*(i) ចំពោះកម្រិតនៃការទទួលខុសត្រូវវិញ បើទោះបីជាខ្លួនមិនមានចេតនា (dolus) ប្រព្រឹត្តបទល្មើសដែលមិនបានព្រមព្រៀងគ្នាក៏ដោយ ក៏ "ជាជនសមគំនិត" គឺជាភាគីមួយដែលមានឆន្ទៈចូលរួមនៅក្នុងសហកម្មមួយ ដើម្បីប្រព្រឹត្តបទល្មើសដែមបានព្រមព្រៀងគ្នារួចមកហើយដែរ ហើយបទល្មើសក្រៅពីនេះ ប្រហែលជាត្រូវបានប្រព្រឹត្តឡើងដោយការចូលរួមរបស់ខ្លួននៅក្នុងសហឧក្រិដ្ឋកម្មនេះ (ដែលត្រូវរាប់បញ្ចូលនូវការចូលរួមចំណែកជាសំខាន់មួយចំពោះការសម្រេចឱ្យបាននូវផែនការសហឧក្រិដ្ឋកម្មនេះ) និងដោយការខកខានរបស់ខ្លួនមិនព្រមបោះបង់ ឬបញ្ឈប់បទល្មើសបន្ថែមទៀតនេះ ខណៈដែលខ្លួនអាចព្យាករណ៍ដឹងជាមុនអំពីបទល្មើសនេះ។*

*(ii) ទាក់ទងទៅនឹងសេចក្តីត្រូវការដើម្បីកំណត់ ឬបង្កើនទណ្ឌកម្ម នោះគេពិតជាទទួលស្គាល់ថាកំហុស និងការទទួលខុសត្រូវរបស់ "ជនសមគំនិត" ស្រាលជាង "មេក្លោង"។ ប៉ុន្តែ កម្រិតទទួលខុសត្រូវស្រាលជាងនេះ គួរត្រូវបានយកមកពិចារណានៅក្នុងដំណាក់កាលផ្តន្ទាទោស។*

*(iii) ទាក់ទងទៅនឹង<u>មូលហេតុចម្បងនៃ JCE III ទម្រង់នៃការទទួលខុសត្រូវនេះត្រូវបានរកឃើញនៅក្នុងការពិចារណាទៅលើគោលនយោបាយសាធារណៈ</u>៖ មានន័យថា សេចក្តីត្រូវការដើម្បីការពារសង្គមប្រឆាំងនឹងជនទាំងឡាយណាដែលប្រមូលផ្តុំគ្នានៅក្នុងសហឧក្រិដ្ឋកម្ម ហើយក្នុងខណៈដែលចូលរួមក្នុងចេតនាឧក្រិដ្ឋរបស់អ្នកចូលរួមទាំងឡាយដែលមានបំណងប្រព្រឹត្តបទល្មើសកាន់តែធ្ងន់ធ្ងរថែមទៀតក្រៅពីសហឧក្រិដ្ឋកម្មរួមនេះ ប៉ុន្តែ ដឹងថា បទល្មើសដែលអាចព្យាករណ៍ទុកជាមុនជាសក្យានុម័តបាននេះ អាចត្រូវបានប្រព្រឹត្តឡើង ហើយមិនបានធ្វើអ្វីមួយដើម្បីទប់ស្កាត់ ឬរារាំងចំពោះបទល្មើសទាំងនោះទេ តែផ្ទុយទៅវិញ នៅតែបន្តសម្រេចឱ្យបានគោលបំណងឧក្រិដ្ឋដទៃទៀតពីសហឧក្រិដ្ឋកម្មនេះ*[១២៣] ។

---

[១២៣] សេចក្តីសម្រេចបន្ទាន់បង្គំស្តីពីច្បាប់ដែលអាចយកមកអនុវត្តបានចំពោះ៖ អំពើភេរវកម្ម ការសមគំនិត អំពើមនុស្សឃាត ការប្រព្រឹត្ត និងការចោទប្រកាន់ត្រួតគ្នា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍), STL-11-01/1 ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៤៤ ដល់ ២៤៥។

៩៧- មិនមានអ្វីដែលគួរឲ្យឆ្ងល់នោះទេថា ទ្រឹស្តីនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល នៅក្រោមច្បាប់អន្តរជាតិ រួមទាំងទម្រង់នៃការទទួលខុសត្រូវ ដែលបានវិវត្តន៍យ៉ាងច្រើន *ក្រោយពី* ការបង្កើតតុលាការ *ចំពោះកិច្ច* មួយចំនួនមក។ សហព្រះរាជអាជ្ញាមិនជំទាស់ទេថា និន្នាការនាពេលបច្ចុប្បន្ននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ កំពុងតែងាកចេញពីទ្រឹស្តីដែលបង្កើតឡូវវិធីជាអត្តនោម័តចំពោះការញែកចេញពីគ្នារវាង ការទទួលខុសត្រូវក្នុងនាមជាមេក្លោង និងការទទួលខុសត្រូវក្នុងនាមជាជនសមគំនិត (ដូចជា សហឧក្រិដ្ឋកម្មរួម) ចំពោះវិធីសាស្ត្រ "ត្រួតពិនិត្យបទល្មើស"ជាសត្យានុម័ត ហើយសហព្រះរាជអាជ្ញាក៏មិនថា និន្នាការនេះ (គឺនិន្នាការដែលសាស្ត្រាចារ្យល្បីៗនាពេលបច្ចុប្បន្នពេញចិត្តយ៉ាងខ្លាំង)[១២៤] បានទទួលការគាំទ្រពីសំណាក់តុលាការព្រហ្មទណ្ឌអន្តរជាតិ[១២៥] និងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ល្បីៗដែរ[១២៦]។ ប៉ុន្តែការពិចារណាទាំងនេះ គឺមិនទាក់ទងនឹងអង្គហេតុនៅចំពោះមុខនេះទេ៖ សហឧក្រិដ្ឋកម្មរួមទាំងបីទម្រង់នេះ បានលើកយ៉ាងច្បាស់លាស់ថាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយអង្គជំនុំជម្រះជាច្រើននៅក្នុងតុលាការអន្តរជាតិ ដែលតុលាការទាំងនោះដំណើរការនៅក្នុងយុត្តាធិការពេលវេលាមុនអំឡុងកម្ពុជាប្រជាធិបតេយ្យតែបន្តិចប៉ុណ្ណោះ។ មូលហេតុសមស្របនៃគោលនយោបាយអន្តរជាតិសាធារណៈ បានគាំទ្រដល់ការអនុវត្តសហឧក្រិដ្ឋកម្មរួមនេះ។ មេធាវីការពារក្តីចង់ឲ្យអង្គជំនុំជម្រះនានា ធ្វើការពិចារណាត្រឡប់ក្រោយ ទាក់ទងនឹងទ្រឹស្តីនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាអន្តរជាតិដោយ ប្រៀបនឹងស្ថានភាពនាពេលបច្ចុប្បន្ន និងដែលកំពុងតែវិវត្តនេះ។ ការធ្វើបែបនេះ មិនស្របនឹងគោលការណ៍នីត្យានុកូលភាព និងសុច្ចរិតភាព នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិនោះឡើយ។

---

[១២៤] Jens David Ohlin "ចេតនារួមគ្នាដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិ" (2011) 11(2) *Chicago Journal of International Law* 693 ទំព័រ ៦៩៣។

[១២៥] *សូមមើល រដ្ឋអាជ្ញា តទល់នឹង* *Thomas Lubanga Dyilo* សេចក្តីសម្រេចលើការបញ្ជាក់អំពីបទចោទនានា តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)- 01/04-01/06។ សេចក្តីសម្រេចលើការបញ្ជាក់អំពីបទចោទនានា (ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០០៧) ពីកថាខណ្ឌ ៣១៧ ដល់ ៣៦៧។ *រដ្ឋអាជ្ញា តទល់នឹង* *Germain Katanga* និង *Mathieu Ngudjolo Chui* តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)- 01/04-01/07។ សេចក្តីសម្រេចលើការបញ្ជាក់អំពីបទចោទនានា ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០០៨ កថាខណ្ឌ ៤៨៩។

[១២៦] បញ្ហានេះត្រូវបានស្រាវជ្រាវយ៉ាងហ្មត់ចត់នៅ Héctor Olásolo៖ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់មេដឹកនាំនយោបាយ និងយោធាជាន់ខ្ពស់ ដែលជាមេក្លោងចំពោះឧក្រិដ្ឋកម្មអន្តរជាតិ (២០០៩) ជាពិសេស ពីជំពូក ៤ ដល់ ៥។

## ច. ការយល់ព្រមតាមសំណើ ក.ស.ព នឹងមិនរំលោភទៅលើគោលការណ៍នីត្យានុកូលភាពទេ

៩៨- តាំងពីដើមដំបូងមកម្ល៉េះ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ការលើកស្ទួយគោលការណ៍នីត្យានុកូលភាពឱ្យបានពេញលេញ មិនរារាំងមិនឱ្យតុលាការធ្វើការបញ្ជាក់ ឬការបកស្រាយធាតុផ្សំនៃបទល្មើសនោះទេ។ ដូចដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY និងបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក៖

> *គោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង* (the principle of nullum crimen sine lege) *មិនហាមឃាត់ដល់អង្គជំនុំជម្រះ ទាំងនៅថ្នាក់ជាតិ ឬថ្នាក់អន្តរជាតិ ក្នុងការកំណត់លើបញ្ហាណាមួយ តាមរយៈដំណើរការនៃការបកស្រាយ និងការបញ្ជាក់លើធាតុផ្សំនៃបទល្មើសណាមួយនោះទេ។ ហើយគោលការណ៍នេះក៏មិនហាមឃាត់មិនឱ្យអង្គជំនុំជម្រះមិនឱ្យផ្អែកលើសេចក្តីសម្រេចមុនៗ ដែលសេចក្តីសម្រេចនោះបកស្រាយអំពីធាតុផ្សំជាក់លាក់នៃបទល្មើសណាមួយនោះដែរ*[១២៧]។

៩៩- ផ្នែកមុនៗបានបង្ហាញយ៉ាងគ្រប់គ្រាន់ថា ការធ្វើវិសោធនកម្ម និងការកែប្រែប្រភេទបទល្មើស ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ស្របទៅនឹងច្បាប់អន្តរជាតិដែលមានអត្ថិភាពក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក និងមិនរំលោភលើការហាមឃាត់ចំពោះការអនុវត្តច្បាប់ដោយមានប្រតិសកម្មនោះទេ។

១០០- ជាការពិតហើយ គោលការណ៍នីត្យានុកូលភាព ដែលបានគោរពនៅ អ.វ.ត.ក ក៏តម្រូវដែរថា ច្បាប់ដែលចែងអំពីការផ្តន្ទាទោសជនណាម្នាក់ចំពោះបទល្មើសណាមួយត្រូវតែ "អាចប្រមើលដឹងជាមុនយ៉ាងគ្រប់គ្រាន់ ហើយច្បាប់ដែលចែងអំពីការទទួលខុសត្រូវបែបនោះ ត្រូវតែមានលទ្ធភាពទទួលបានយ៉ាងគ្រប់គ្រាន់ដល់ជនជាប់ចោទ នៅក្នុងពេលវេលាដែលពាក់ព័ន្ធនោះ"[១២៨]។ ទាក់ទងនឹងភាព

---

[១២៧] *រដ្ឋអាជ្ញា តទល់នឹង* *Zlatko Aleksovski* សំណុំរឿងលេខ IT-95-14/1-A ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០០០ កថាខណ្ឌ ១២៧។ ឯកសារ **E188** សាលក្រមរបស់ ឌុច លេខយោង ២១ *ខាងលើ* កថាខណ្ឌ ៣៤។

[១២៨] ឯកសារ **E188** សាលក្រមរបស់ ឌុច លេខយោង ២១ *ខាងលើ* កថាខណ្ឌ ២៨ ដល់ ២៩។ ឯកសារ **D427/2/15** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ លេខយោងជើងទំព័រ ២៣ *ខាងលើ* កថាខណ្ឌ ១០៦។

អាចព្យាករណ៍បានជាមុន ជនជាប់ចោទ "ត្រូវតែមានលទ្ធភាពយល់ថា ទង្វើនោះគឺជាអំពើព្រហ្មទណ្ឌ នៅក្នុងន័យមួយដែលត្រូវបានគេយល់ជាទូទៅ ដោយមិនចាំបាច់យោងទៅលើបទ ប្បញ្ញត្តិជាក់លាក់ណាមួយនោះឡើយ"[១២៩]។ ទាក់ទងទៅនឹងលទ្ធភាពទទួលបានវិញ ទាំងអង្គបុរេជំនុំជម្រះ និងទាំងអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានអះអាងយ៉ាងស្របគ្នាថា ច្បាប់ដែល "មានមូលដ្ឋានទៅលើទំនៀមទម្លាប់" តាមអង្គហេតុរបស់វាផ្ទាល់ (*ipso facto*) ជនជាប់ចោទត្រូវតែ "មានលទ្ធភាពគ្រប់គ្រាន់ដឹងថាមានច្បាប់"[១៣០]។

១០១- ទាក់ទងនឹងលទ្ធភាពដឹងថាមានច្បាប់ សហព្រះរាជអាជ្ញាស្នើថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិចារណាថា មិនមានទំនាក់ទំនងជម្លោះប្រដាប់អាវុធជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ថាអង្គហេតុពាក់ព័ន្ធនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស៊ីសង្វាក់គ្នាយ៉ាងខ្លាំងបំផុតទៅនឹងនិយមន័យនៃបទរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយថាទម្រង់នៃការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន អាចត្រូវបានកំណត់យ៉ាងសមស្របបំផុត តាមរយៈទម្រង់នៃការទទួលខុសត្រូវក្នុង JCE III នោះឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវទាំងនេះ ដែលសុទ្ធតែត្រូវបានទទួលស្គាល់នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងពេលវេលាដែលពាក់ព័ន្ធពិតជានឹងត្រូវជនជាប់ចោទ "អាចមានលទ្ធភាពគ្រប់គ្រាន់ដឹងថាមានច្បាប់"។

១០២- ទាក់ទងនឹងភាពអាចព្យាករណ៍បាន បើទោះជាច្បាប់កម្ពុជាបានចែងយ៉ាងច្បាស់អំពីគោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង (*nullum crimen sine lege*)[១៣១] ប៉ុន្តែ មិនមានការលើកឡើងរបស់តុលាការពាក់ព័ន្ធទៅនឹងគោលការណ៍នេះនៅកម្រិតជាតិនោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងអាចស្វែងរកការណែនាំពីនិយាមស្តីពីនីតិវិធីនៅកម្រិតអន្តរជាតិ[១៣២]។

---

[១២៩] *ដូចលេខយោងខាងលើនេះ។*

[១៣០] *ដូចលេខយោងខាងលើនេះ។*

[១៣១] មាត្រ ៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ៣១(១) នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។

[១៣២] មាត្រា ១២ នៃកិច្ចព្រមព្រៀង និង មាត្រ ៣៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

១០៣- នៅក្នុងរឿងក្តីថ្មីៗរវាង *Jorgić តទល់នឹង ប្រទេសអាល្លឺម៉ង់* តុលាការសិទ្ធិមនុស្សអឺរ៉ុបបានវាយតម្លៃអំពីវិសាលភាពនៃការពារតាមផ្លូវច្បាប់ដែលបង្កើតឡើងតាមរយៈគោលការណ៍*គ្មានបទល្មើសបើគ្មានច្បាប់ចែង* នៅក្រោមមាត្រា ៧(១) នៃអនុសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ជាពិសេស នៅក្នុងបរិបទនៃច្បាប់ជាតិរបស់ប្រទេសអាល្លឺម៉ង់ ដែលបានកំណត់ការបកស្រាយទូលំទូលាយទៅលើលក្ខខណ្ឌតម្រូវឲ្យមានធាតុចេតនាជាក់លាក់ចំពោះអំពើប្រល័យពូជសាសន៍ ខ្ពស់ជាងលក្ខខណ្ឌតម្រូវដែលអនុវត្តនៅក្រោមច្បាប់អន្តរជាតិទូទៅ[១៣៣]។ ដើម្បីឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យអំពីនីត្យានុកូលភាពនៃភាពអាចប្រមើលដឹងជាមុនបាននៃ តុលាការបានអនុវត្តបទដ្ឋានអន្តរជាតិ(រួមទាំងច្បាប់មិនមានសំណេរផង) ដែលតម្រូវថា "ធាតុផ្សំស្នូលនៃបទល្មើស" អាចត្រូវបាន "ប្រមើលឃើញជាមុនបាន" ពីសំណាក់ជនជាប់ចោទ "ប្រសិនបើចាំបាច់ គឺបន្ទាប់ពីការទទួលបានការផ្តល់យោបល់ផ្នែកច្បាប់រួចមក"[១៣៤]។ សហព្រះរាជអាជ្ញាស្នើថា បទដ្ឋាននៃការប្រមើលដឹងជា មុន ដែលត្រូវបានអនុវត្តពិសេសបំផុតចំពោះអំពើដែលបង្កើតបានជាបទល្មើសអន្តរជាតិសំខាន់ៗ មានភាពជាប់ពាក់ព័ន្ធយ៉ាងខ្លាំងបំផុតទៅនឹងការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងទៅលើវិសាលភាពត្រឹមត្រូវនៃលក្ខខណ្ឌវិនិច្ឆ័យអំពីនីត្យានុកូលភាពនៃភាពអាចប្រមើលឃើញជាមុនបាននេះ។

១០៤- អៀង ធីរិទ្ធ ជំទាស់ទៅនឹងទាំងថាជនជាប់ចោទអាចប្រមើលមើលជាមុនអំពីការផ្តន្ទាទោសបទល្មើសរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអាចដឹងថាមានច្បាប់សម្រាប់ផ្តន្ទាទោសឧក្រិដ្ឋកម្មនេះក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ[១៣៥]។

១០៥- ខៀវ សំផន បានអះអាងថា ដោយហេតុថាអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានច្បាប់ព្រហ្មទណ្ឌជាតិហាមឃាត់ គាត់ពុំអាចដឹងជាមុនឡើយថាគាត់អាចនឹងត្រូវជំនុំជម្រះពីបទចោទមួយ

---

[១៣៣] រឿងក្តីថ្មីៗរវាង *Jorgić តទល់នឹង ប្រទេសអាល្លឺម៉ង់* សំណុំរឿងលេខ 74613/01 ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០០៧។

[១៣៤] *ដូចលេខយោងខាងលើ* កថាខណ្ឌ ១០០ កថាខណ្ឌ ១០១ និង ១១/០។

[១៣៥] លេខឯកសារ **E99/2** ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់ "សហព្រះរាជអាជ្ញា" សុំឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មី ទាក់ទងទៅនឹងអង្គហេតុដែលបង្កើតបានជាអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងថាជា អំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅវិញ, *ដូចឯកសារយោងខាងលើ* ត្រង់ជើង ទំព័រលេខ ៨, កថាខណ្ឌ ២៦-២៧។

ផ្សេងទៀតទេ[១៣៦]។ ខុសស្រឡះពីអំណះអំណាងខាងលើ ការដែលអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានផ្តន្ទាទោសដោយអនុលោម តាមច្បាប់ជាតិ នឹងកាន់តែធ្វើឲ្យជនជាប់ចោទអាចប្រមើលដឹងមុនថា ការប្រព្រឹត្តិបទល្មើសទាំងនោះជាទ្រង់ទ្រាយធំអាចនឹងនាំឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។

១០៦- អៀង សារី បានលើកយកមកបង្ហាញនូវភាពខុសប្លែកគ្នាខាងទស្សនទានរវាង "ការហាមឃាត់" អំពើរំលោភសេពសន្ថវៈក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង "ការកំណត់បទឧក្រិដ្ឋ" ថាជា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមានចែងក្នុងច្បាប់" ដើម្បីបង្ហាញថា ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ អៀង សារី ពុំបានប្រមើលមើលដឹងមុនឡើយថាអំពើរំលោភសេពសន្ថវៈជាបទល្មើស ឬមានច្បាប់ចែងអំពីបទល្មើសមួយនេះទេ[១៣៧]។ ទោះយ៉ាងណាក៏ដោយ ក្នុងចម្លើយតបរបស់ខ្លួន ពាក់ព័ន្ធនឹងបញ្ហានេះ មេធាវីការពារក្តីអនុវត្តភាពខុសគ្នាដោយមិនត្រឹមត្រូវឡើយ។ សហព្រះរាជអាជ្ញាពុំបដិសេធថា គោលការណ៍នីត្យានុកូលភាពតម្រូវឲ្យជនជាប់ចោទរងការចោទប្រកាន់ពីបទដែលច្បាប់អន្តរជាតិបានហាមឃាត់ *ដែលភ្ជាប់មកជាមួយនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ឬការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ*។ ជាឧទាហរណ៍ ទង្វើដែលអាចនាំមកនូវការទទួលខុសត្រូវរបស់ប្រទេសតែម្នាក់ឯង មិនទាន់អាចចាត់ទុកថាបានបំពេញតាម លក្ខខណ្ឌគោលការណ៍នីត្យានុកូលភាព ដែលអាចយកមកអនុវត្តចំពោះកិច្ចនីតិវិធីព្រហ្មទណ្ឌឡើយ។ ទោះយ៉ាងណាក៏ដោយ ទម្លាប់អនុវត្តនីមួយៗខាងលើដែលយើងលើកយកមកធ្វើជា ឧទាហរណ៍ ទាក់ទងនឹងការអនុវត្តការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ឬការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះបទរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

---

[១៣៦] លេខឯកសារ**E95/3**, ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងលុបចោលនូវលក្ខណៈវិនិច្ឆ័យដែលដាក់បញ្ចូលជម្លោះប្រដាប់អាវុធទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, *ដូចឯកសារយោងខាងលើ* ត្រង់ជើងទំព័រលេខ ១០, កថាខណ្ឌ ២៤ (ដោយយោងទៅលើឯកសារ **E46**, អញ្ញត្រកម្មបឋមលើយុត្តាធិការ ,ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ត្រង់កថាខណ្ឌ ១៦)។

[១៣៧] លេខឯកសារ E99/4, ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលា ដំបូងកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សផ្សេងៗទៀត, *ដូចឯកសារយោងខាងលើ* ត្រង់ជើងទំព័រលេខ ៩ ត្រង់កថាខណ្ឌ ១៩។

១០៧- ជនជាប់ចោទជាផ្នែកមួយនៃថ្នាក់ដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យ។ ជនជាប់ចោទម្នាក់ៗមានសិទ្ធិត្រួតពិនិត្យក្បាលម៉ាស៊ីនរដ្ឋ រួមទាំងការផ្តល់ឱវាទផ្នែកច្បាប់ក្នុងករណីចាំបាច់ និងមានសិទ្ធិពិនិត្យមើលធនធានផ្នែកការទូត និងមានមធ្យោបាយក្នុងការប្រាស្រ័យទាក់ទងទូលំទូលាយជាមួយអន្តរជាតិ[១៣៨]។ ជនជាប់ចោទទាំងអស់ពុំមែនជាអនក្ខរជនឡើយ គឺសុទ្ធសឹងតែជាមនុស្សមានការសិក្សាជ្រៅជ្រះ[១៣៩]។ ជនជាប់ចោទទាំងអស់សុទ្ធតែបានដឹងអំពីការថ្កោលទោសជាសាកលចំពោះទង្វើរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យតាមរយៈរបាយការណ៍ជាច្រើនរបស់រដ្ឋ និងអង្គការពុំមែនរដ្ឋាភិបាលនានា ដែលបានដាក់ជូនអនុគណៈកម្មការការពារការរើសអើង និងការពារជនជាតិភាគតិចនៃអង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ ១៩៧៨។ ជាក់ស្តែង របាយការណ៍មួយរបស់ចក្រភពអង់គ្លេសបានលើកឡើងអំពី “ភស្តុតាងដែលបញ្ជាក់ថា ខ្លឹមសារជាសារវ័ន្តបំផុតនៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស បានរងការរំលោភបំពានយ៉ាងកម្រោល” ហើយ “មេដឹកនាំកម្ពុជា...ពុំបានព្យាយាមប្រកែកនឹងការចោទប្រកាន់ទាំងឡាយដែលមានមកលើពួកគេឡើយ”[១៤០]។ របាយការណ៍ទាំងនេះ មិនសំដៅទៅលើរដ្ឋដែលមានសង្គ្រាម ឬឧក្រិដ្ឋកម្មសង្គ្រាមនោះទេ និងក៏មិនបានផ្តោតជាចំបងទៅលើការធ្វើទុកបុកម្នេញជាទូទៅ និងជាប្រព័ន្ធ ទៅលើប្រជាជនស៊ីវិលដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនោះដែរ។ ក្នុងការឆ្លើយតបជាផ្លូវការទៅនឹងរបាយការណ៍ទាំងនោះ អៀង សារី មិនបង្អែរបង្អង់យូរឡើយក្នុងការចាត់ទុកការកាប់សម្លាប់ប្រជាជនកម្ពុជាជាទ្រង់ទ្រាយធំ និងការបំផ្លិចបំផ្លាញបូរណភាពកម្ពុជាពីសំណាក់ភាគីផ្សេងៗ ថាជា “ឧក្រិដ្ឋកម្មធំឥតគណនា”[១៤១]។

---

[១៣៨] លេខឯកសារ D427, ដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, ERN 00604508-909, កថាខណ្ឌ ៨៧៦,៨៩០,៨៩៤ (នួន ជា), កថាខណ្ឌ ១១៣៧,១១៥២ (ខៀវ សំផន), កថាខណ្ឌ ១០៩០-១០៩៣, ១១២២-១១២៥ (អៀង សារី), និងកថាខណ្ឌ ១២២២-២៣, ១២២៦ (អៀង ធីរិទ្ធ) (“ដីកាដំណោះស្រាយ”)។

[១៣៩] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ១៥៩៧ (នួន ជា), ១៥៨៧-៨៨ (អៀង សារី), ១៥៩៩ (ខៀវ សំផន), ១៦០៦ (អៀង ធីរិទ្ធ)។

[១៤០] លេខឯកសារ **D366/7.1.11,** របាយការណ៍រៀបចំឡើងដោយរដ្ឋាភិបាលចក្រភពអង់គ្លេស, ERN00075967-84។

[១៤១] លេខឯកសារ **D366/7.1.821,** ទូរលេខរបស់រដ្ឋមន្ត្រីក្រសួងការបរទេស, ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៨, ERN 00076042-44។

១០៨- ដោយសារមានការដឹងឮជាទូទៅអំពីដំណើរការក្តីប្រឆាំងនឹងមន្ត្រីជាន់ខ្ពស់របស់រដ្ឋនានា នៅចំពោះមុខតុលាការយោធាអន្តរជាតិ និងតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ក៏ដូចជាដំណើរការក្តីក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាត្រួតពិនិត្យ សហព្រះរាជអាជ្ញាសូមស្នើឡើងដោយគោរពថា តាមរយៈតួនាទីរបស់ខ្លួនរៀងៗខ្លួន ជនជាប់ចោទម្នាក់ៗ ដោយទទួលបានការផ្តល់យោបល់ផ្នែកច្បាប់ក្នុងករណីចាំបាច់ ពិតជាអាចប្រមើលមើលដឹងជាមុនដោយមានហេតុផលត្រឹមត្រូវថា៖

(ក) ខ្លួនអាចនឹងត្រូវជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយពុំគិតអំពីអត្ថិភាពនៃស្ថានភាពប្រទេសក្នុងពេលសង្គ្រាមឡើយ

(ខ) បទល្មើសដែលមានក្នុងដីកាដំណោះស្រាយ ដែលរួមមានបទរំលោភសេពសន្ថវៈនៅក្នុងបរិបទគោលនយោបាយរៀបការដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា[១៤២] នឹងបង្កើតបានជាធាតុផ្សំចាំបាច់នៃបទរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពោលគឺជាអំពើរំលោភសេពសន្ថវៈដែលជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធសំដៅមកលើប្រជាជនស៊ីវិល និង

(គ) អាចមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ តាមរយៈការចូលរួមរបស់ខ្លួនក្នុងផែនការរួម ឬសហឧក្រិដ្ឋកម្មរួម ក្នុងចេតនាប្រព្រឹត្តអំពីប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើបំពារបំពានធ្ងន់ធ្ងរ រួមទាំងបទល្មើសទាំងឡាយដែលពុំទាន់ជាផ្នែកមួយនៃផែនការរួមកាលពីដំបូង ប៉ុន្តែបង្កើតបានជាផលវិបាកពិតប្រាកដ និងអាចប្រមើលដឹងជាមុនបាន។

## V. សន្និដ្ឋាន និងសំណូមពរ

១០៩- ផ្អែកតាមអំណះអំណាងខាងលើ សហព្រះរាជអាជ្ញាសូមស្នើឡើងថា អង្គជំនុំជម្រះសាលាដំបូងពិតជាមានអំណាចយល់ព្រមតាមសំណើទាំងនេះ ហើយថា ការយល់ព្រមតាមសំណើទាំងនេះពិតជាពុំរំលោភលើគោលការណ៍នីត្យានុកូលភាពឡើយ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

[១៤២] លេខឯកសារ **D427**, ដីកាដំណោះស្រាយ, *ដូចជើងទំព័រខាងលើ*លេខ ១៣៨, ពិសេសត្រង់កថាខណ្ឌ ២១៦-២២០, ៨៤២-៨៦១។

(ក) ទទួលយកសំណើទាំងនេះ និង

(ខ) យល់ព្រមតាមសំណើទាំងនេះលើផ្នែកអង្គសេចក្តី

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | |